ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 25-Jan-2012, 15:12
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២៤ ខែមករា ឆ្នាំ២០១២**

**ម៉ោង ០៩:០៣ នាទី**

**សវនាការលើកទី២០**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ម៉ាតេអូ គ្រីប៉ា
*(Mr.Matteo CRIPPA)*

លោក ឌុច ផារី

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក ច័ន្ទ តារាស្មី

លោក សេង ប៊ុនឃាង

លោក ពេជ្រ សម្បត្តិ

លោក ថារីក អាប់ឌុលហាក់
*(Mr. Tarik ABDULHAK)*

លោកស្រី សារ៉ាស អេនឌ្រូ
*(Ms.Sarah ANDREWS)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក មិ៉ែខល ផេសមិន

*(Mr. Michiel PESTMAN)*

លោក ហ្សាស្ពើ ប៉ៅ

*(Mr Jasper PAUW)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក ហ្សាក់ វែរហ្សេស

*(Mr. Jacques VERGES)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក មិ៉ែខល កាណាវ៉ាស

*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក បាណាបេ ណេគុី

*(Mr. Barnabé NEKUIE)*

លោក ឡូ ជុនធី

លោក វ៉ែន ពៅ

លោក ហុង គឹមសួន

លោកស្រី ស៊ីន សុវ៉ន

លោក សំ សុគង់

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក កូវ កែវរតនៈ

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍ | បារាំង |
| លោក ច័ន្ទ តារាស្មី | ខ្មែរ |
| លោក ថារីក អាប់ឌុលឡាក់ | អង់គ្លេស |
| លោក ម៉ៃខល ផេសមិន | អង់គ្លេស |
| លោក ហ្សាស្តើ ប៉ៅ | អង់គ្លេស |
| លោក សុន អរុណ | ខ្មែរ |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក អាង ឧត្តម | ខ្មែរ |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| លោក វ៉ាន់ថាន់ ដាវ៉ាពៅ | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅលោក ខាន់ចាន់ ដារ៉ាពៅ** (TCW-766)

សួរដោយលោក ច័ន្ទ តារាស្មី ផ្ដើមពី....................ទំព័រ ២
សួរដោយលោក ពេជ អង្គ ផ្ដើមពី....................ទំព័រ ១៣
សួរដោយលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត ផ្ដើមពី....................ទំព័រ ២០
សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍ ផ្ដើមពី....................ទំព័រ ២៩
សួរដោយលោក សុន អរុណ ផ្ដើមពី....................ទំព័រ ៣៦
សួរដោយលោក ហ្សាស្ដេី ប៉ៅ ផ្ដើមពី....................ទំព័រ ៥៨
សួរដោយលោក ម៉ៃខល កាណាវាស ផ្ដើមពី....................ទំព័រ ៨២

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៣:០៩]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរនីតិវិធីសវនាការ។ មុននឹងបន្តសូមអញ្ជើញមេធាវី នួន ជា មេធាវីអន្តរជាតិក្រោកឈរ!

អង្គជំនុំជម្រះសូមជម្រាបលោកមេធាវីថា ម្សិលមិញអង្គជំនុំជម្រះបានទទួល-- បានស្តាប់នូវសំណើសុំរបស់លោកមេធាវី ការបង្កើនម៉ោងដើម្បីសួរដល់សាក្សី ដែលជាអនុប្រធានមជ្ឈមណ្ឌលឯកសារកម្ពុជាពីមួយម៉ោងកន្លះ ទៅកន្លះថ្ងៃ។ បញ្ហានេះអង្គជំនុំជម្រះរក្សាសិទ្ធិនៅក្នុងការបែងចែកតាមពេលវេលាដែលបានណែនាំរួចហើយ គឺក្នុងមួយក្រុមមេធាវីការពារក្តីមួយម៉ោងកន្លះ។ ដោយសូមរំឭកដល់មេធាវីថា គឺសូមឲ្យអនុវត្តទៅតាមការណែនាំ ដើម្បីកំណត់នៅក្នុងរបៀបវារៈនៃការពិភាក្សាដេញដោល គឺដើម្បីពិនិត្យមើលបញ្ហាទូទៅស្តីពីវិធីសាស្ត្រនៃការទទួលឯកសារ ការបែងចែកប្រភេទឯកសារ ដំណើរការរក្សាឯកសាររបស់មជ្ឈមណ្ឌលឯកសារ និង/ឬ ឯកសារផ្សេងៗមួយចំនួនទៀត ហើយទន្ទឹមនឹងហ្នឹង គឺភាពពាក់ព័ន្ធទៅនឹងការសួរនាំពាក់ព័ន្ធជាមួយនឹងការសួរដេញដោល ហើយទាក់ទងនឹងបញ្ហានេះ។ ហើយអង្គជំនុំជម្រះនឹងពិនិត្យលទ្ធភាពជាក់ស្តែង នៅពេលដែលកិច្ចដំណើរការសួរដេញដោលដែលអង្គជំនុំជម្រះបែងចែកពេលវេលាឲ្យលោក។ ប្រសិនបើភាពចាំបាច់នៅក្នុងការបន្តទៀតនោះ អង្គជំនុំជម្រះនឹងផ្តល់ជូនតាមពេលវេលាសមរម្យ។ ស្តាប់យល់ទេ?

[០៩:០៥:២៧]

**លោក ម៉ៃខល ផេសមិន៖**

ខ្ញុំយល់លោកប្រធាន សូមអរគុណច្រើន។

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលចាត់ការ!

អរុណសួស្តីលោក ដាវ៉ាពៅ ហើយថ្ងៃនេះ អង្គជំនុំជម្រះនឹងបន្តការស្តាប់សក្ខីកម្មរបស់លោក

ដោយមានការតាំងសំណួរពីភាគីផ្សេងៗទៀត នៅក្នុងនោះអង្គជំនុំជម្រះពិនិត្យឃើញថា កាលពីម្សិលមិញខាងតំណាងសហព្រះរាជអាជ្ញានៅមានពេលវេលាកន្លះម៉ោងទៀត ដើម្បីក្នុងការតាំងសំណួរដល់លោកសាក្សី ពាក់ព័ន្ធនឹងបញ្ហាទាំងឡាយនៃទាក់ទិននឹងបញ្ហាឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជា។

ជាបន្តនេះ អង្គជំនុំជម្រះសូមប្រគល់វេទិកាទៅតំណាងសហព្រះរាជអាជ្ញា។

សូមអញ្ជើញ!

[០៩:០៦:៤៥]

**លោក ច័ន្ទ តារាស្មី៖**

បាទសូមគោរពលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រម។ អរុណសួស្តីអស់លោក លោកស្រីទាំងអស់ដែលមានវត្តមាននៅទីនេះ។ ខ្ញុំឈ្មោះ ច័ន្ទ តារាស្មី ជាសហព្រះរាជអាជ្ញារងជាតិនៃ អ.វ.ត.ក នេះ សូមអនុញ្ញាតបន្តសួរសំណួរទៅលោក វ៉ាន់ថាន់ ដារ៉ាពៅ នៅព្រឹកនេះ ទាក់ទងសំណួរមួយចំនួនដែលខ្ញុំត្រៀមនឹងសួរនៅពេលបន្តិចទៀតនេះ។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ច័ន្ទ តារាស្មី៖**

**ស៖** លោក ដារ៉ាពៅ អរុណសួស្តី ហើយខ្ញុំសូមអនុញ្ញាតសួរសំណួរមួយចំនួនដែលជាសំណួរសំខាន់សម្រាប់ខ្ញុំ ក៏ដូចជាសវនាការនៅពេលនេះ។ លោកបានផ្តល់សក្ខីកម្មពាក់ព័ន្ធនឹងទង់បដិវត្ត និងយុវជនបដិវត្ត តើនៅក្នុងសក្ខីកម្មទាំងអស់នោះ លោកសំអាងលើមូលដ្ឋានអ្វីជាចម្បង ដែលនាំឲ្យលោកកំណត់ថា ឯកសារមានការពាក់ព័ន្ធទៅនឹងរបបកម្ពុជាប្រជាធិបតេយ្យ?

**លោក វ៉ាន់ថាន់ ដារ៉ាពៅ៖**

**ឆ៖** អរគុណលោកសហព្រះរាជអាជ្ញាចំពោះសំណួរនេះ។ ទាក់ទងទៅនឹងការកំណត់ថាតើឯកសារនេះ ឯកសារមួយជាដែលនិយាយអំពីរបបកម្ពុជាប្រជាធិបតេយ្យ ឬក៏ពាក់ព័ន្ធនឹង របបកម្ពុជាប្រជាធិបតេយ្យ។ គឺយើង ទីមួយ គឺយើងអានឯកសារនេះដោយយកចិត្តទុកដាក់ យើងពិនិត្យមើលទៅលើខ្លឹមសារនៃឯកសារដែលមាន យើងពិនិត្យមើលទៅលើភាសាដែលប្រើប្រាស់នៅក្នុងឯកសារហ្នឹង យើងមើលអំពីកាលបរិច្ឆេទដែលមាននៅក្នុងឯកសារ ដើម្បីកំណត់ថាតើឯកសារហ្នឹងនិយាយអំពីរបបកម្ពុជាប្រជាធិបតេយ្យ ឬក៏យ៉ាងណា។

**ស៖** បាទអរគុណ។ តើពាក្យអ្វី ឬក៏ឃ្លាអ្វីដែលជាឃ្លា ជាពាក្យសំខាន់ៗដែលលោកបានកត់សម្គាល់ឃើញថា ជាពាក្យដែលគេបានប្រើប្រាស់នៅក្នុងឯកសារទង់បដិវត្ត និងទង់យុវជន យុវនារីបដិវត្តនាពេលនោះ?

[០៩:០៨:៤៣]

**ឆ៖** ដោយសារមានទំហំធំធេង ខ្ញុំមិនអាចនឹងចងចាំអស់អំពីខ្លឹមសារនៅក្នុងទង់បដិវត្តទេ ប៉ុន្តែខ្ញុំអាចឲ្យជាឧទាហរណ៍មួយ ដែលនិយាយអំពីការៗវាយកម្ទេចខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង ដែលជាភាសាប្រើប្រាស់នៅក្នុងទង់បដិវត្ត ហើយភាសានេះបានប្រើប្រាស់ច្រើន ហើយញឹកញាប់នៅក្នុងឯកសារបែបនេះ។

**ស៖** បាទអរគុណ។ តើលោកបានប្រើវិធីសាស្ត្រអ្វីខ្លះបន្ថែមទៀតនៅក្នុងការកត់សម្គាល់ទៅលើឯកសារទង់បដិវត្ត និងទង់យុវជន យុវនាទីបដិវត្តនាសម័យកាលនោះ?

**ឆ៖** ដូចខ្ញុំបាទជម្រាបពីខាងដើម គឺថាដើម្បីដឹងអំពីឯកសារនេះ គឺយើងត្រូវអានវា យើងត្រូវអានដោយយកចិត្តទុកដាក់ យើងត្រូវកំណត់-- យើងត្រូវអង្កេតមើលអំពីខ្លឹមសារ អំពីពាក្យពេចន៍ប្រើនៅក្នុងខ្លឹមសារ ជាភាសា ជាកាលបរិច្ឆេទអីជាដើម។

[០៩:១០:០០]

**ស៖** ខ្ញុំសូមសួរបន្តទៀត តើ ឌី.ស៊ី.ខេម មានរក្សាទុកឯកសារពាក់ព័ន្ធទៅនឹងរណសិរ្សបង្រួបបង្រួមជាតិកម្ពុជា និងរដ្ឋាភិបាលបង្រួបបង្រួមកម្ពុជាដែរឬទេ?

**ឆ៖** ចំពោះបញ្ហានេះ លោកសហព្រះរាជអាជ្ញាត្រូវដឹងថាមជ្ឈមណ្ឌលឯកសារកម្ពុជាមានអាណត្តិរបស់ខ្លួន ដែលត្រូវធ្វើការស្រាវជ្រាវ និងចងក្រងឯកសារសម្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជា។ ដូច្នេះ នៅក្នុងឯកសារនេះ គឺយើងសំដៅទៅលើឯកសារដែលពាក់ព័ន្ធទៅនឹងរបបកម្ពុជាប្រជាធិបតេយ្យ និងឯកសារអំពីរបបកម្ពុជាប្រជាធិបេតយ្យ ដែលជាផ្លូវការ គឺយើងកំណត់យកពីឆ្នាំ៧៥ ដល់ឆ្នាំ៧៩។

**ស៖** អរគុណ។ ខ្ញុំសូមបន្តទៅសំណួរផ្សេងទៀត សំណួរដែលខ្ញុំសួរបន្តនេះ គឺសំណួរដែលទាក់ទិនទៅនឹង *ប៊ីប្លូក្រាហ្វិក*(Bibliographic) ទាក់ទិងទៅនឹងសំណួរដែលទាក់ទិននឹងទិន្នន័យដែលមានជារូបថត ទាក់ទិនទៅនឹងទិន្នន័យដែលទាក់ទិននឹងភូមិសាស្ត្រ *ជីអូក្រាហ្វិក* (Geographic)។ ទិន្នន័យដែលទាក់ទិនទៅនឹង អាចនិយាយថា ជាការចងក្រងលក្ខណៈជាបណ្ណាល័យឯកសារ *ប៊ីប្លូក្រាហ្វិក* ឬក៏ឯកសារដែលពាក់ព័ន្ធទៅនឹងប្រវត្តិសាស្ត្រសំខាន់ៗនៅក្នុងរបបកម្ពុជាប្រជាធិបេតយ្យ។

ខ្ញុំចូលទៅនឹងសំណួរទីមួយ ជាសំណួរដែលទាក់ទិនទៅនឹង *ប៊ីប្លូក្រាហ្វិក ដេតាបេស*។ ខ្ញុំចង់ឲ្យលោកបញ្ជាក់ថា តើ *ប៊ីប្លូក្រាហ្វិក ដេតាបេស*ហ្នឹង មានអត្ថន័យយ៉ាងដូចម៉េច?

[០៩:១១:៤២]

**ឆ៖** នៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានទិន្នន័យ ដែលជាប្រព័ន្ធ*ដេតាបេស*នៅក្នុងកុំព្យូទ័រមានបួនប្រភេទគឺ ទីមួយ *ប៊ីប្លូក្រាហ្វិក ដេតាបេស* គឺជាទិន្នន័យដែលសំដៅទៅលើឯកសារជាប្រវត្តិរូបរបស់អតីតយុទ្ធជនខ្មែរក្រហម ក៏ដូចជាជនរងគ្រោះនៅក្នុងសម័យខ្មែរក្រហម។ នេះ គឺជាអត្ថន័យដែលសំដៅទៅលើ *ប៊ីប្លូក្រាហ្វិក ដេតាបេស*។

**ស៖** បាទ បំណងសំខាន់ក្រៅពីអាហ្នឹង មានអ្វីទៀតដែរឬទេ ចំពោះ*ប៊ីប្លូក្រាហ្វិក ដេតាបេស?*

**ឆ៖** គឺគោលបំណង-- ការសំដៅដែលចម្បងបំផុត គឺទាក់ទងទៅនឹងប្រវត្តិរូបរបស់អតីតយុទ្ធជនកម្មាភិបាលខ្មែរក្រហម ដែលឯកសារហ្នឹង នៅមជ្ឈមណ្ឌលឯកសារកម្ពុជាយើងហៅថា ឯកសារប្រវត្តិរូប ដែលមានលេខសម្គាល់របស់វា ផ្ដើមដោយអក្សរ “I” ឬអក្សរ “K”។

**ស៖** លោកអាចបញ្ជាក់បន្ថែមទេ ថាតើកម្មាភិបាលយុវជន អតីតយុទ្ធជនបដិវត្តន៍នាសម័យនោះ តើយើងគិតត្រឹមកម្រិតថ្នាក់ណាដែរ?

**ឆ៖** វាអាស្រ័យទៅលើឯកសារដែលយើងមាន មិនកំណត់ថាថ្នាក់ណា ឬក៏ថ្នាក់ណា ឲ្យតែឯកសារដែលមាននៅហ្នឹង នៅដែររបស់យើងដែលយើងប្រមូលបាន គឺយើងធ្វើការចងក្រងចូលទៅក្នុងប្រព័ន្ធទិន្នន័យបែបនេះ។

[០៩:១៣:១២]

**ស៖** ហើយបានចងក្រងចំនួនទិន្នន័យសរុបប៉ុន្មានដែរ ចំពោះទិន្នន័យប្រភេទនេះ?

**ឆ៖** លោកអាចរកមើលចំនួនពិតប្រាកដបាន នៅក្នុងប្រព័ន្ធទិន្នទ័យ នៅក្នុងកុំព្យូទ័របាន។

**ស៖** អរគុណ។ តើឯកសារប្រភេទអ្វីដែលត្រូវបានកត់ត្រានៅក្នុង*ប៊ីប្លូក្រាហ្វិក ដេតាបេស*ហ្នឹងពាក់ព័ន្ធទៅនឹងឯកសារដែលខ្ញុំបានឃើញជាង ១លានឯកសារនោះ លោកអាចបញ្ជាក់ជាចំណុចសំខាន់ៗដកស្រង់បានជូនអង្គសវនាការនៅពេលនេះ បានជ្រាបដែរឬទេ?

**ឆ៖** ខ្ញុំគិតថា សំណួររបស់លោកសហព្រះរាជអាជ្ញាមានភាពទូលំទូលាយបន្តិច ហើយបើសិនអាច សូមលោកមេត្តាសួរឲ្យចំចំណុច ហើយខ្លី ហើយមានលក្ខណៈងាយស្រួលយល់។

**ស៖** បាទ អរគុណ។ ខ្ញុំចង់ដឹងច្បាស់អំពីប្រភេទ-- ឯកសារប្រភេទអ្វីខ្លះដែលជាឯកសារគន្លឹះ

សំខាន់ដែលខាង ឌី.ស៊ី.ខេម បានបញ្ចូលទៅក្នុង *ប៊ីប្បូក្រាហ្វិក ដេតាបេស* ហើយលោកដាក់ជាចំណាត់ថ្នាក់មានចំណងជើងសំខាន់ៗអ្វីខ្លះ ខ្ញុំចង់ឲ្យលោកបញ្ជាក់ចំណុចសំខាន់ៗតែប៉ុណ្ណោះ ជូនអង្គសវនាការនៅពេលនេះ ដើម្បីឲ្យបានជ្រាប បាទ។

[០៩:១៤:២៣]

**ឆៈ** ដូចខ្ញុំបានជម្រាបពីខាងដើម គឺថាមជ្ឈមណ្ឌលឯកសារកម្ពុជាមិនធ្វើការវិភាគទៅលើឯកសារទេ មិនធ្វើការវិភាគទៅលើឯកសារណាមួយ ថាជាឯកសារសំខាន់ ឬចម្បងនោះទេ គឺមជ្ឈមណ្ឌលឯកសារកម្ពុជាធ្វើការចងក្រងឯកសារទៅតាម ភាពជាឯកសារដែលយើងទទួលបាននេះតែម្តង។ ចំពោះសំណួរទាក់ទងទៅនឹង ថាតើនៅក្នុងប្រព័ន្ធទិន្នន័យទាក់ទងនឹងប្រវត្តិរូបនេះ គឺយើងមានបង្កើតជាទម្រង់បំពេញនូវព័ត៌មានដែលទម្រង់បំពេញនូវព័ត៌មាននេះ មានចំណុច មាន យើងហៅថា "*ហ្វៀល*" ជាច្រើនដែលត្រូវបំពេញព័ត៌មាននៅក្នុងនោះ។ ហើយព័ត៌មានទាំងអស់នេះ គឺជាព័ត៌មានដែលមានលក្ខណៈទូទៅ ដែលអាចឲ្យអ្នកសិក្សាស្រាវជ្រាវ សាធារណជន ឬក៏ជនទាំងឡាយដែលចង់ស្វែងរកសាច់ញាតិក្រុមគ្រួសារដែលបានស្លាប់ ឬបាត់បង់ជីវិត ឬក៏បាត់ខ្លួននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

**សៈ** បាទអរគុណលោក ដារ៉ាពៅ-- លោកវ៉ាន់ថាន់ ដារ៉ាពៅ។ តើមានរបាយការណ៍ ឬឯកសារចំនួនប៉ុន្មានដែលស្ថិតនៅក្នុងប្រភេទ *ប៊ីប្បូក្រាហ្វិក ដេតាបេស* ដែលខ្ញុំលើកឧទាហរណ៍ដូចជាទាក់ទិនទៅនឹងអត្ថបទ សៀវភៅ ដែលលោកបានចងក្រងហ្នឹង សូមលោកបញ្ជាក់អំពីទិន្នន័យដែលលោកអាចដឹង ដែលលោកបានឃើញកន្លងមក?

**ឆៈ** បាទ ចំពោះ-- ទាក់ទងទៅនឹងចំនួន យើងមានការពិបាកនៅក្នុងការផ្តល់នូវចំនួនពិតប្រាកដនៅក្នុងទីនេះ ប៉ុន្តែលោកសហព្រះរាជអាជ្ញាប្រហែលជានឹងអាចទទួលនូវចំនួនពិតប្រាកដ បើសិនជាលោកសហព្រះរាជអាជ្ញាចូលទៅក្នុងគេហទំព័រ ហើយពិនិត្យមើលទៅលើប្រព័ន្ធទិន្នន័យហ្នឹង ប៉ុន្តែខ្ញុំសូមបញ្ជាក់ថាប្រព័ន្ធទិន្នន័យទាក់ទងទៅនឹង *ប៊ីប្បូក្រាហ្វិក* នេះគឺឲ្យតែឯកសារណាដែលមិនមែនជាឯកសារទាក់ទងទៅនឹងប្រវត្តិរូប គឺយើងដាក់បញ្ចូលនៅក្នុងប្រព័ន្ធទិន្នន័យ *ប៊ីប្បូក្រាហ្វិក*ទាំងអស់។

[០៩:១៦:៤៧]

**សៈ** អរគុណ។ សំណួរមួយទៀត ថាតើដំណើរការក្នុងការដាក់ឯកសារមួយចូលទៅក្នុង *ប៊ីប្បូក្រាហ្វិក ដេតាបេស* ហ្នឹង ត្រូវធ្វើឡើងដោយរបៀបណាដែរ?

**ឆៈ** យើង នៅមជ្ឈមណ្ឌលឯកសារកម្ពុជា យើងមានក្បួនក្នុងការធ្វើបញ្ចូលប្រព័ន្ធទិន្នន័យនេះ

នៅក្នុងប្រព័ន្ធកុំព្យូទ័រ ដែលនៅក្នុងនោះភាសាអង់គ្លេសហៅថា *មេនញូ (Menu)*។ ហើយ *មេនញូ* នេះ យើងបានដាក់បង្ហោះនៅលើគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ហើយយើងបានគោរពទៅតាម *មេនញូ* នេះនៅក្នុង-- នៅពេលដែលយើងធ្វើការចងក្រងប្រព័ន្ធទិន្នន័យចូលទៅក្នុងប្រព័ន្ធកុំព្យូទ័រ។

**ស៖** អរគុណលោក ដារ៉ា។ តើប្រព័ន្ធ *ហ្វៀល* អ្វីដែលត្រូវបានកត់ត្រាសម្រាប់ឯកសារនីមួយៗ ដាក់ក្នុង *ដេតាបេស* នោះ? ឧទាហរណ៍ថាតើលោកបានកត់ត្រាចូលក្នុងដូចជាចំណងជើង អ្នកនិពន្ធ ប្រភពនៃឯកសារ ស្ថានភាពនៃឯកសារ សង្ខេបអត្ថន័យ ជនរងគ្រោះដែលបានអះអាង ចារីដែលបាន អះអាង និងទីកន្លែងប្រជុំដែរឬទេ នៅក្នុងឯកសារ*ដេតាបេស* ដែលជាប្រភេទ *ហ្វៀល* ដែលលោកបាន កត់ត្រាចូលនោះ?

**ឆ៖** ជាការត្រឹមត្រូវនៅក្នុងប្រព័ន្ធទិន្នន័យនីមួយៗ គឺយើងមានទម្រង់ យើងហៅថា *រឹកស៊ីត* ដែលយើងកំណត់ *ហ្វៀល* នៅក្នុងហ្នឹង។ ហើយក្នុងទម្រង់មួយៗហ្នឹងមាន *ហ្វៀល*រហូតដល់ទៅជិត ១០០ *ហ្វៀល*ណោះ ឯណោះ បាទ ដែលនៅក្នុងហ្នឹងមានការបំពេញឈ្មោះ ថ្ងៃខែឆ្នាំកំណើត បើទាក់ទង ទៅនឹងប្រវត្តិរូប ពីមុខងារដែលជននោះធ្វើពីមុនមក ហើយពីសង្ខេបអំពីខ្លឹមសារនៅក្នុងឯកសារ ហើយ ដាក់បញ្ចូលនៅក្នុងប្រព័ន្ធទិន្នន័យនេះ។ នៅក្នុងការធ្វើប្រព័ន្ធទិន្នន័យនេះ ខ្ញុំបាទសូមជម្រាបបញ្ជាក់បន្ថែម ទៀត គឺថាយើងបានមើលទៅលើឯកសារ ដែលជាឯកសារនៅលើសន្លឹកក្រដាសនេះ ហើយយើងបាន យកព័ត៌មានចេញពីឯកសារហ្នឹង ដាក់បញ្ចូលទៅក្នុងទម្រង់ជាក្រដាសមួយ ដែលមានទុកចន្លោះឲ្យ បំពេញ រួចបន្ទាប់មកបានយើងយកព័ត៌មានដែលយើងបំពេញនៅលើទម្រង់ហ្នឹង យកទៅវាយបញ្ចូលនៅ ក្នុងប្រព័ន្ធកុំព្យូទ័រ។ ហើយរាល់ឯកសារ-- រាល់ទម្រង់ដែលយើងបំពេញហ្នឹង គឺយើងមានទុក*កូពី* ជា *ហាតកូពី* នៅមជ្ឈមណ្ឌលឯកសារកម្ពុជាទៀត។

**ស៖** បាទ អរគុណ។ តើអ្នកណាជាអ្នកធ្វើការងារនេះ ហើយតើពួកគេមានការគ្រប់គ្រង ត្រួត ត្រាមើលលើការងារនោះ ដើម្បីធានាពីភាពជាក់លាក់របស់ទិន្នន័យនេះដែរឬទេ? ហើយអ្នកដែលទទួល ខុសត្រូវនោះ គឺជាអ្នកណា?

[០៩:១៩:៥៦]

**ឆ៖** អ្នកទទួលខុសត្រូវលើការងារនេះគឺ ខ្ញុំបាទផ្ទាល់។ ហើយខ្ញុំមានសហការីប្អូនប្រាំនាក់ដែល ធ្វើការងារនេះ ហើយការងារបញ្ចូលប្រព័ន្ធទិន្នន័យនេះគឺ មានជាជំហានៗរបស់វា ដូចជា ទីមួយយើង ត្រូវមើលទៅលើឯកសារជាក់ស្តែង បន្ទាប់មកយើងយកព័ត៌មានពីឯកសារជាក់ស្តែង ដាក់ចូលទៅក្នុង

ទម្រង់ជាក្រដាសរបស់យើងហ្នឹង បន្ទាប់មកយើងធ្វើការបញ្ចូលព័ត៌មានហ្នឹង ចូលទៅក្នុងប្រព័ន្ធកុំព្យូទ័រ ដោយផ្អែកទៅលើព័ត៌មានដែលយើងបញ្ចូលនៅក្នុង*ហ្វៀល* ជាក្រដាស ព្រោះ*ហ្វៀល* ជាក្រដាសនេះ វាស៊ីគ្នាទៅហ្នឹង *ហ្វៀល*ដែលមាននៅក្នុងប្រព័ន្ធកុំព្យូទ័រ។ នៅពេលដែលយើងបញ្ចូលហើយ យើងមានសហការីផ្សេងទៀតពិនិត្យមើលអំពីភាពសុក្រឹតនៃការបញ្ចូលប្រព័ន្ធទិន្នន័យនេះ ដូចជា របៀប-- ដូចជាការសរសេរពាក្យពេចន៍ ហើយនិងខ្លឹមសារដែលយើងបានបញ្ចូល ធៀបជាមួយនឹងឯកសារជាក់ស្តែង។

[០៩:២១:០៧]

យើងមានក្រុម-- ជំហានបន្ទាប់ទៀតគឺយើងមានក្រុមពិនិត្យមើលមួយសាទៀត ក្រែងលោថាប្រព័ន្ធកុំព្យូទ័រវាមានលក្ខណៈភ័ន្តច្រឡំអីយ៉ាងម៉េច គឺយើងបានមើលមួយសាទៀត ដើម្បីធ្វើការកែតម្រូវឲ្យធ្វើយ៉ាងម៉េចទិន្នន័យនៅក្នុងប្រព័ន្ធកុំព្យូទ័រនេះ គឺវាមានលក្ខណៈសុក្រឹតដូចដែលព័ត៌មានមាននៅលើក្រដាស។

**សៈ** អរគុណ។ លោកបានបញ្ជាក់ថា លោកដែលទទួលខុសត្រូវលើកិច្ចការទិន្នន័យនេះដោយផ្ទាល់ តើលោកចាប់ផ្តើមទទួលខុសត្រូវលើការងារនេះចាប់ពីពេលណាមក?

**ឆះ** ដូចខ្ញុំបាន-- ខ្ញុំធ្វើការងារនេះនៅមជ្ឈមណ្ឌលឯកសារកម្ពុជាពីឆ្នាំ១៩៩៥ ហើយការងារនេះគឺ ខ្ញុំធ្វើតាំងពីពេលដែលខ្ញុំចូលធ្វើការងារនៅមជ្ឈមណ្ឌលឯកសារកម្ពុជា រហូតមកដល់ពេលបច្ចុប្បន្ន។

**សៈ** អរគុណបាទ។ ខ្ញុំសូមអនុញ្ញាតតទៅសួរចំណុចទីពីរ ដែលទាក់ទងទៅនឹង*ប៊ីប្លូក្រាហ្វិក ដេតាបេស*។ *ប៊ីប្លូក្រាហ្វិក ដេតាបេស* តើបំណងរបស់លោក ឬក៏ ឌី.ស៊ី.ខេម បង្កើតឡើងក្នុងបំណងអ្វីចំពោះ *ប៊ីប្លូក្រាហ្វិក ដេតាបេស*ហ្នឹង?

[០៩:២២:២៤]

**ឆះ** នៅក្នុងការបង្កើតជាប្រព័ន្ធទិន្នន័យនេះមិនថា*ប៊ីប្លូក្រាហ្វិក* មិនថា*បាយអូក្រាហ្វិក ដេតាបេស*ទេ គឺទីមួយ គឺយើងធ្វើយើងចង់សម្រួលដល់ការមកធ្វើការស្រាវជ្រាវនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ដោយអ្នកសិក្សាស្រាវជ្រាវ អាចនឹងទទួលបានព័ត៌មាននេះតាមរយៈអ៊ីនធឺណេតអីបាន ដោយមិនបាច់ចាំមកផ្ទាល់ដល់មជ្ឈមណ្ឌលឯកសារកម្ពុជា។ នេះគឺជាការសម្រួលដល់ការសិក្សាស្រាវជ្រាវ។ ជាពិសេសទាក់ទងទៅនឹង *ប៊ីប្លូក្រាហ្វិក ដេតាបេស*នេះ គឺសំខាន់ទាក់ទងទៅនឹងការស្វែងរកក្រុមគ្រួសារសាច់ញាតិមិត្តភក្តិ ដែលបានបាត់បង់ ដែលបានបាត់ខ្លួន ឬបាត់បង់ជីវិតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

[០៩:២៣:២១]

បាទ នៅក្នុងន័យនេះគឺថា ដោយសារក្រោយរបបកម្ពុជាប្រជាធិបតេយ្យដួលរលំទៅគឺថា ក្រុមគ្រួសារសាច់ញាតិនីមួយៗមានការបែកខ្ញែក មានការបាត់បង់ ឬបាត់ខ្លួន។ ដូច្នេះប្រព័ន្ធទិន្នន័យបែបនេះអាចនឹងជួយដល់អ្នករស់រានមានជីវិត អាចនឹងធ្វើការស្វែងរកក្រុមគ្រួសាររបស់ខ្លួន ហើយជា-- ស្ទើរតែជារៀងរាល់ថ្ងៃដែលមានអ៊ំពូមីង មកពីតាមបណ្តាខេត្តគាត់មកធ្វើការស្វែងរកក្រុមគ្រួសាររបស់គាត់ដែលបានបាត់ខ្លួនដែលបានស្លាប់ ទោះបីជា បើស្លាប់ក៏ត្រូវដឹងអំពីថាតើស្លាប់នៅទីណា ស្លាប់ដោយមូលហេតុអី ថាតើយើងមានឯកសារអីពាក់ព័ន្ធទៅនឹងសាច់ញាតិរបស់គាត់ដែរឬអត់។

**សៈ** អរគុណលោក ដារ៉ា។ ខ្ញុំសូមបញ្ជាក់កន្លែងហ្នឹងបន្តិច តើ*ប៊ីប្លូក្រាហ្វិក ដេតាបេស*ហ្នឹងមានបញ្ចូលនូវទិន្នន័យសំខាន់ ដូចជា ប្រវត្តិរបស់មេដឹកនាំមជ្ឈិមបក្ស ភូមិភាគ តំបន់ ថ្នាក់ស្រុក ថ្នាក់ឃុំ និងភូមិភាគខ្លះទៀតដែរឬទេ? ហើយថាតើមានប្រវត្តិរបស់សមាជិកខ្មែរក្រហមបញ្ចូលក្នុងហ្នឹងដែរឬទេ? ហើយថាតើមានស្វ័យជីវប្រវត្តិលម្អិត ដែលកម្មាភិបាលរបស់បក្សត្រូវបានតម្រូវឲ្យសរសេរបញ្ចូលទៅក្នុងហ្នឹងដែរឬទេ? ហើយថាតើមាននិយាយអំពីរបបនយោបាយខ្មែរក្រហម ការរៀបចំយោធាដែលបានកត់ត្រាដោយបុគ្គលម្នាក់ៗ នៃសមាជិកខ្មែរក្រហមហ្នឹងបញ្ចូលទៅក្នុង*ប៊ីប្លូក្រាហ្វិក ដេតាបេស*ដែរឬទេ?

[០៩:២៥:០០]

**ធៈ** ទាក់ទងនឹងសំណួរនេះ ដើម្បីឲ្យបានច្បាស់លាស់ទៅទាំងអស់គ្នានៅក្នុងបន្ទប់សវនាការនេះ ខ្ញុំស្នើសុំលោកសហព្រះរាជអាជ្ញាមើលទៅលើគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ហើយបើកមើល *ដេតាបេស* នេះទាំងអស់គ្នា ដើម្បីឲ្យឃើញថាតើក្នុងឯកសារនីមួយៗ គឺមាន*ហ្វៀល*អីខ្លះ បំពេញព័ត៌មានអីខ្លះ លោកសហព្រះរាជអាជ្ញាអាចនឹងមើលបាន។

**សៈ** អរគុណលោក។ សំណួរមួយទៀត ជាសំណួរបន្ទាប់ពីរចំណុចពីរហ្នឹង គឺតើមានឯកសាររបាយការណ៍ចំនួនប៉ុន្មានស្ថិតនៅក្នុង*ប៊ីប្លូក្រាហ្វិក ដេតាបេស* កន្លងមក?

**ធៈ** ជាថ្មីម្តងទៀត ទាក់ទងទៅនឹងចំនួនជាក់លាក់ ខ្ញុំស្នើសុំសហព្រះរាជអាជ្ញាមើលទៅលើ *ដេតាបេស* ទាំងអស់នោះ។

**សៈ** បាទអរគុណ។ តើលោកធានាថាព័ត៌មានទាំងអស់ដែលមាននៅក្នុងនោះ មានភាពត្រឹមត្រូវជាក់លាក់ ហើយលោកគិតថា ការត្រឹមត្រូវជាក់លាក់ហ្នឹង គឺលោកសំអាងទៅលើវិធីណាដែលលោកបានអះអាងថា ត្រឹមត្រូវជាក់លាក់?

[០៩:២៦:០៦]

**ឆ៖** ខ្ញុំគិតថា ខ្ញុំបានបញ្ជាក់បញ្ហានេះច្បាស់លាស់ហើយ ទាក់ទងទៅនឹងការពិនិត្យ ការផ្ទៀងផ្ទាត់ទៅលើព័ត៌មានដែលបានបញ្ចូលនៅក្នុងប្រព័ន្ធទិន្នន័យជាមួយនឹងព័ត៌មាន ដែលមាននៅលើឯកសារជាក់ស្តែង ដែលធ្វើទៅតាមជំហានទីមួយៗ ដើម្បីឲ្យដឹងថាព័ត៌មានដែលបញ្ចូលទៅនៅក្នុងប្រព័ន្ធទិន្នន័យ និងព័ត៌មាននៅក្នុងឯកសារជាក់ស្តែងហ្នឹងមានភាពសុក្រឹត ដែរឬក៏អត់។

**ស៖** អរគុណលោកដារ៉ា។ តើមានព័ត៌មានដែលទាក់ទិនទៅនឹងការរំលោភសិទ្ធិមនុស្សដែលកើតមាននៅក្នុងរបបនុ៎ង ដែលទាក់ទិនទៅនឹងសមាជិកមួយរូបៗ ឬក៏ក្នុងតំបន់ណាមួយ បានបញ្ចូលទៅក្នុង*ដេតាបេស*នុ៎ងដែរឬទេ?

**ឆ៖** ចំពោះសំណួរនេះ ខ្ញុំស្នើសុំលោកសហព្រះរាជអាជ្ញាមើលជាថ្មីម្តងទៀត គឺថា សូមមើលប្រព័ន្ធទិន្នន័យនេះឲ្យបានច្បាស់លាស់ ដើម្បីធ្វើការស្វែងយល់ថាតើព័ត៌មានអ្វីខ្លះដែលយើងបញ្ចូលនៅក្នុងប្រព័ន្ធទិន្នន័យ។ ព្រោះឯកសារនេះយើងដាក់ជាសាធារណៈ ប្រព័ន្ធទិន្នន័យនេះ យើងបង្ហោះលើ*វេបសាយ* សាធារណជនអាចរកមើលបានទាំងអស់ ដោយអត់មានលាក់លៀមអ្វីទាំងអស់។

**ស៖** អរគុណលោក ដារ៉ាពៅ។ តាមពិតយើងខ្ញុំបានដឹងពីបញ្ហានេះ ប៉ុន្តែចង់ឲ្យលោក ដារ៉ាពៅមេត្តាឆ្លើយ ប្រសិនជាអាចឆ្លើយបាន នៅក្នុងអង្គសវនាការ ដើម្បីជ្រាបទាំងអស់គ្នា ព្រោះពេលខ្លះសាធារណជនគាត់មិនបានបើកមើល ឬក៏គាត់មិនអាចបើកមើលបាន។ អ៊ីចឹងការឆ្លើយរបស់លោកនៅពេលនេះពិតជាមានសារៈសំខាន់។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ខ្ញុំព្យាយាមមិនសួរសំណួរនេះតទៅទៀតទេ។

សូមអរគុណហើយលោកចៅក្រម លោកប្រធានបើសិនជាអនុញ្ញាតខ្ញុំសូមសួរបន្តទៀតបាទ។

[០៩:២៧:៥០]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ លោកមានពេលដប់នាទីទៀត ប៉ុន្តែគប្បីប្រើប្រាស់ពេលវេលាឲ្យមានប្រសិទ្ធភាពដើម្បីក្នុងការសួរ ដែលពាក់ព័ន្ធទៅនឹងឯកសារ ដែលគ្រោងនឹងដាក់ ឬក៏បានដាក់រួចហើយ នៅចំពោះមុខអង្គជំនុំជម្រះ ដែលជាឯកសារភស្តុតាងក្នុងសំណុំរឿង ដែលនឹងមានប្រយោជន៍នៅក្នុងការវិភាគពិចារណាវាយតម្លៃនាពេលបញ្ចប់កិច្ចដំណើរការពិភាក្សាដេញដោលលើរឿងក្តីនេះ។

**លោក ច័ន្ទ តារាស្មី៖**

(មិនឮសំឡេងនិយាយ)

**ប្រធានអង្គជំនុំ៖**

បើកៗក្បាលមីក្រូ!

**លោក ច័ន្ទ តារាស្មី៖**

**ស៖** សូមលោកមេត្តាឆ្លើយបញ្ជាក់ជូនអង្គសវនាការជាតិ អំពី *ហ្វូតូក្រាហ្វ ដេតាបេស* តើការបង្កើត *ហ្វូតូក្រាហ្វ ដេតាបេស* នេះក្នុងបំណងអ្វីបាទ?

**លោក វ៉ាន់ថាន់ ដាវ៉ាពៅ៖**

**ឆ៖** *ហ្វូតូក្រាហ្វ ដេតាបេស* នេះគឺលោកជ្រាបហើយថា ក្រោយពីរបបកម្ពុជាប្រជាធិបតេយ្យដួលរលំទៅនេះ គឺយើងបានប្រមែប្រមូលបានរូបថតជាច្រើន ហើយរូបថតទាំងនេះមិនមាន ភាគច្រើនគឺមិនមានព័ត៌មាននៅលើរូបថតនេះទេ។ អ៊ីចឹងការបង្កើតប្រព័ន្ធទិន្នន័យរូបថតនេះ គឺយើងមានបំណងយល់ថា មានសាធារណជននឹងអាចមើល ចូលទៅមើលនៅក្នុងប្រព័ន្ធទិន្នន័យនេះ អាចនឹងទទួលស្គាល់នូវរូបថតណាមួយ ដែលយើងបានដាក់បង្ហោះនេះ។ ហើយនៅពេលដែលមានការទទួលស្គាល់បែបនេះ អ្នកមើលនឹងផ្តល់ព័ត៌មានមកមជ្ឈមណ្ឌលឯកសារកម្ពុជាវិញ ថារូបថតនេះជារូបថតអ្នកណា រូបថតយ៉ាងម៉េច ផ្តល់ព័ត៌មានបន្ថែមអំពីរូបថតហ្នឹងតែម្តង ហើយយើងនឹងបញ្ចូលបន្ថែមទៅលើប្រព័ន្ធទិន្នន័យបែបនេះ។

**ស៖** អរគុណលោក តើក្នុង *ហ្វូតូក្រាហ្វ ដេតាបេស* ហ្នឹងមានវីដេអូ មានខ្សែភាពយន្តបញ្ចូលក្នុងហ្នឹងដែរឬទេ?

[០៩:៣០:០០]

**ឆ៖** ទាក់ទងទៅនឹងរូបថត គឺៗរូបថតតែម្តង អត់មានខ្សែភាពយន្តនៅក្នុងហ្នឹងទេ។

**ស៖** វីដេអូក៏អត់ដែរបាទ?

**ឆ៖** បាទ ខ្សែភាពយន្ត គឺវីដេអូហ្នឹងឯង។

**ស៖** អរគុណ ទាក់ទងនឹងបញ្ហានេះ តើ *ដេតាបេស* ដែលជាឯកសារទិន្នន័យសំខាន់ លោកអាចបញ្ជាក់បានទេ ជាកម្មសិទ្ធិរបស់អ្នកណាដែរ? របស់រូបវន្តបុគ្គល ឬនីតិបុគ្គលណា ទិន្នន័យទាំងអស់ដែលមាននៅក្នុង ឌី.ស៊ី.ខេម តើជាកម្មសិទ្ធិរបស់បុគ្គលណា សូមបញ្ជាក់បន្តិចបាទ?

[០៩:៣០:២៧]

**ឆ៖** ដូចយើងបានថា ជម្រាបជូនអង្គសវនាការពីម្សិលមិញអ៊ីចឹង គឺថាប្រភពនៃឯកសារមាន

មកជាច្រើនប្រភព មានមកពីរដ្ឋាភិបាល មានមកជាបុគ្គល មានមកជាស្ថាប័នឯកជន។ ហើយទាល់តែលោកសហព្រះរាជអាជ្ញាបង្ហាញអំពីឯកសារណាមួយជាក់លាក់ទើបយើងអាចដឹងថា តើឯកសារហ្នឹងបុគ្គលណាជាអ្នកផ្តល់ជូន។ ប៉ុន្តែខ្ញុំសូមបញ្ជាក់បន្ថែមថា រាល់ការទទួលឯកសារគឺយើងបានធ្វើយថាភាពឯកសារនេះច្បាស់លាស់ ដោយបានសួរនាំអំពីព័ត៌មានអ្នកដែលបានផ្តល់ឲ្យយើង ៗបានកត់នូវអាសយដ្ឋាននូវលេខទូរស័ព្ទ បើសិនជាមាននៅក្នុងការធ្វើទំនាក់ទំនងនៅពេលក្រោយ បើសិនជាអ្នកសិក្សាស្រាវជ្រាវឬក៏សាធារណជនណាចង់ដឹងបន្ថែមអំពីព័ត៌មាននេះ។

**ស៖** អរគុណលោកប្រធាន ខ្ញុំមានបីសំណួរចុងក្រោយសួរទៅលោក ដារ៉ា នៅពេលនេះបាទ។ សំណួរទីមួយ តើលោកបានដឹងថានៅពេលដែលលោក មុនពេលដែលលោកអញ្ជើញមកទីនេះដើម្បីផ្តល់ជាសក្ខីកម្មជូនអង្គសវនាការនៅពេលនេះ។ តើលោកអាចប្រាប់បានទេ ថាតើលោកមានបំណងថា នឹងត្រូវសួរពីប្រធានបទអ្វីនៅពេលផ្តល់សក្ខីកម្មនៅពេលនេះ? តើលោកបានដឹងទេថា នៅពេលដែលលោកមកដល់ទីនេះ គេនឹងសួរលោកនូវសំណួរអ្វីខ្លះ ក្នុងពេលផ្តល់សក្ខីកម្មនៅពេលនេះ? តើលោកបានដឹងសំណួរមុន ឬក៏លោកអាចដឹងមុនទេពីបញ្ហាហ្នឹង?

[០៩:៣១:៥៧]

**ឆ៖** ខ្ញុំត្រូវបានអង្គជំនុំជម្រះបញ្ជូនដីកាកោះ ហើយក្នុងដីកាកោះនោះ ត្រូវឲ្យមកឆ្លើយបំភ្លឺនៅចំពោះមុខអង្គសវនាការ អំពីឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។

**ស៖** តើលោកបានដឹងសំណួរលម្អិត ឬក៏បញ្ជីសំណួរដែលគេនឹងសួរលោក គ្រោងៗនឹងសួរលោកនៅពេលនេះដែរទេ?

**ប្រធានអង្គជំនុំ៖**

សំណួរនេះមិនពាក់ព័ន្ធនឹងការដេញដោល គោលបំណងនៃសួរដេញដោលឯកសារទេ។ មិនបាច់ឆ្លើយទេ!

**សួរដោយលោក ច័ន្ទ តារាស្មី៖**

**ស៖** ខ្ញុំសូមសួរសំណួរទីពីរ តើលោកបានផ្តល់សក្ខីកម្មពីម្សិលមិញនេះ លោកបានបញ្ជាក់ថា ឌី.ស៊ី.ខេម បានទទួលឯកសារនានាពីប្រភពផ្សេងៗក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ តើលោកអាចជម្រាបជូនដល់តុលាការបានទេថា តើអ្នកណាដែលអាចផ្តល់ព័ត៌មានច្រើនបំផុតពីឯកសារនានាដែល ឌី.ស៊ី.ខេម បានទទួលពីដើមដំបូង? តើលោកខ្លួនឯងផ្ទាល់ ឬក៏នាយករបស់លោកជាអ្នកទទួលឯកសារ

ទាំងអស់នោះ?

**ឆះ** នៅក្នុងការប្រមែប្រមូលចងក្រងឯកសារគឺមិនមែនមានតែរូបខ្ញុំ ឬមិនមែនមានតែលោកប្រធានមជ្ឈមណ្ឌលឯកសារកម្ពុជា គឺមានការចូលរួមពីសហការី ពីបុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាច្រើននាក់។ ហើយបើទោះបីជាបានទទួលតាមរយៈបុគ្គលិក តាមរយៈលោកប្រធាន ឬក៏ខ្ញុំផ្ទាល់ក៏ដោយ គឺឯកសារនោះត្រូវបានធ្លាក់មកដៃរបស់ខ្ញុំ ដើម្បីខ្ញុំធ្វើការចងក្រង ធ្វើការចុះលេខ ធ្វើការថែរក្សាទុក ទុកដាក់ឲ្យបានត្រឹមត្រូវ។

[០៩:៣៣:៣៨]

**សះ** អរគុណលោកប្រធាន ខ្ញុំសួរសំណួរចុងក្រោយបាទ។ នេះជាសំណួរចុងក្រោយរបស់ខ្ញុំលោក ដារ៉ា។ សំណួរចុងក្រោយរបស់ខ្ញុំគឺថា ក្នុងចំណោមឯកសារនានាដែល អូ.ស៊ី.ភី ដែលការិយាល័យសហព្រះរាជអាជ្ញាបានទទួលពីលោក គឺការិយាល័សហព្រះរាជអាជ្ញាបានទទួលជាវីដេអូមួយចំនួន ហើយភាគច្រើនវីដេអូទាំងនោះគឺជាខ្សែវីដេអូដែល ឯកសារដែលបានទទួលហ្នឹងពីលោកផ្ទាល់ពី ឌី.ស៊ី.ខេម ផ្ទាល់។ តើលោកអាចជម្រាបជូនតុលាការបានទេថា វីដេអូទាំងនោះត្រូវបានធ្វើជាកាតាឡុក ដោយឌី.ស៊ី.ខេម យ៉ាងដូចម្ដេច? ឧទាហរណ៍ថា តើលោកប្រើអក្សរ “D” ជាលេខ អក្សរ “D” ហើយលេខ ឬក៏ប្រើវិធីផ្សេងទៀត ដើម្បីចុះលេខវីដេអូទាំងនោះ ព្រោះកន្លងមកលោកអត់បានបញ្ជាក់អំពីចំណុចនេះទេ តើ-- ឯកសារផ្សេងៗ លោកបានប្រើអក្សរកាត់ ហើយដាក់លេខ ដើម្បីសម្គាល់ប្រភេទឯកសារ។ ក៏ប៉ុន្តែឯកសារដែលការិយាល័យសហព្រះរាជអាជ្ញាបានទទួលគឺឯកសារជាវីដេអូហ្នឹង អត់មានចុះលេខសម្គាល់ជាអក្សរជាអ្វីទេ។ អ៊ីចឹង ខាងខ្ញុំចង់ដឹងច្បាស់ថា តើលោកធ្វើការគ្រប់គ្រងឯកសារបែបនេះយ៉ាងដូចម្ដេច? បាទ សូមអរគុណ។

[០៩:៣៤:៣៧]

**ឆះ** នៅក្នុងការរៀបចំខ្សែភាពយន្តឯកសារ ដែលមជ្ឈមណ្ឌលឯកសារបានទទួលបាននេះ គឺមជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើជាបញ្ជីកុន។ នៅក្នុងបញ្ជីកុននីមួយៗ គឺបានបង្ហាញអំពីចំណងជើងនៃខ្សែភាពយន្តឯកសារ បានបង្ហាញអំពីប្រភពដែលទទួលបាននេះ។ អ៊ីចឹងបញ្ជីខ្សែភាពយន្តឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជានេះ អាចរកបានដោយទូលំទូលាយនៅលើគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។

**លោក ច័ន្ទ តាវារស្មី៖**

អរគុណ លោកប្រធានខ្ញុំអស់សំណួរ។ អរគុណលោក វ៉ាន់ថាន់ ដាវ៉ាពៅ ដែលបានឆ្លើយសំណួររបស់ខ្ញុំ ហើយសូមអរគុណលោកដែលបានផ្តល់វត្តមាននៅទីនេះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណតំណាងសហព្រះរាជអាជ្ញាជាតិ។ ជាបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកាទៅសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីមានឱកាសនៅក្នុងការតាំងសំណួរចំពោះសាក្សីរូបនេះ ហើយសហមេធាវីនាំមុខមានរយៈពេលមួយម៉ោងក្នុងការតាំងសំណួរចំពោះសាក្សីរូបនេះ។

សូមអញ្ជើញ!

[០៩:៣៥:៥៩]

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោក ពេជ អង្គ៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងសវនាការទាំងមូល។ ខ្ញុំនឹងលើកសំណួរមួយចំនួន បន្ទាប់មកលោកស្រីមេធាវីនាំមុខអន្តរជាតិ អេលីហ្សាបេត ស៊ីម៉ូនណូហ្វត នឹងលើកសំណួរបន្តជូនទៅលោក វ៉ាន់ថាន់ ដាវ៉ាពៅ។

**ស៖** សំណួររបស់ខ្ញុំគឺព្យាយាមមិនសួរច្រំដែលទៅលើសំណួរដែលបានលើកមកហើយទេ ក៏ប៉ុន្តែក៏អាចមានការបញ្ជាក់បន្ថែមទៅលើចំណុចលម្អិតមួយចំនួន ហើយនិងមានសំណួរថ្មីមួយចំនួន។ ជាបឋមចង់ជម្រាបសួរ សូមជម្រាបសួរលោក ដាវ៉ាពៅ ខ្ញុំចង់សុំសួរលោកថា នៅឆ្នាំ១៩៩៧ ឌី.ស៊ី.ខេម ត្រូវបានបង្កើតជាអង្គការមួយឯករាជ្យដោយខ្លួនឯង ផ្តាច់ចេញពីសាកលវិទ្យាល័យយ៉ែល នៅសហរដ្ឋអាមេរិក។ តើលោកអាចពន្យល់បានទេថា តើអង្គការនេះមានលក្ខណៈឯករាជ្យយ៉ាងដូចម្តេចខ្លះពីសាកលវិទ្យាល័យនោះ បន្ទាប់ពីការផ្តាច់ចេញពីសាកលវិទ្យាល័យនោះ។

[០៩:៣៧:១០]

**ឆ៖** អរគុណចំពោះសំណួរ។ សាកលវិទ្យាល័យយ៉ែល បានមានគម្រោងកម្មវិធីសិក្សាអំពីរបបកម្ពុជាប្រជាធិបតេយ្យនេះ មានរយៈពេលតែពីរឆ្នាំទេ។ គឺពីឆ្នាំ៩៥ ដល់ឆ្នាំ៩៧។ អ៊ីចឹងនៅពេលដែលថវិការបស់កម្មវិធីនេះត្រូវបានបញ្ចប់ គឺកម្មវិធីនេះត្រូវបានបញ្ចប់ ហើយលោកនាយករបស់មជ្ឈមណ្ឌលឯកសារកម្ពុជានាពេលបច្ចុប្បន្ន បន្តកិច្ចការងារនេះតទៅមុខទៀត ដោយអត់មានទទួល *ហ្វាន់* តាមរយៈ

ទទួលថវិកាតាមរយៈសាលកវិទ្យាល័យយ៉ែលទេ។

**ស៖** តើនៅក្នុងពេលចន្លោះឆ្នាំ១៩៩៥ ដល់ឆ្នាំ១៩៩៧ លោកបាននិយាយថា ឌី.ស៊ី.ខេម គឺជាផ្នែកមួយនៃសាកលវិទ្យាល័យយ៉ែល ថាតើពេលនោះទំនាក់ទំនងផ្នែករដ្ឋបាលមានលក្ខណៈយ៉ាងម៉េចរវាង ឌី.ស៊ី.ខេម ហើយនិងសាកលវិទ្យាល័យយ៉ែល?

[០៩:៣៨:២៥]

**ឆ៖** ខ្ញុំសូមបញ្ជាក់ម្តងទៀតទាក់ទងរយៈពេលចន្លោះឆ្នាំ។ សូម--

**ស៖** ចង់និយាយថានៅក្នុងរយៈពេល៩៥ ដល់៩៧ តើទំនាក់ទំនងរដ្ឋបាលរវាង យ៉ែល ហើយនិង ឌី.ស៊ី.ខេម មានទំនាក់ទំនងយ៉ាងដូចម្តេច? ចង់និយាយថា តើ ឌី.ស៊ី.ខេម មានសិទ្ធិនៅក្នុងការសម្រេចខ្លួនឯងទៅលើកិច្ចការរដ្ឋបាល ឬក៏ដំណើរការងារខ្លួនឯងទេ នៅក្នុងរយៈពេល៩៥ និង៩៧ នេះ?

**ឆ៖** បាទ នៅក្នុងអំឡុងពេលដែល ឌី.ស៊ី.ខេម មានប្រតិបត្តិការពីឆ្នាំ៩៥ ដល់ឆ្នាំ៩៧ នេះ គឺ ឌី.ស៊ី.ខេម នេះ ជាការិយាល័យមួយរបស់កម្មវិធីសិក្សាអំពីរបបកម្ពុជាប្រជាធិបតេយ្យនេះតែប៉ុណ្ណោះមិនមែនជា-- មិនទាន់មែនជាអង្គការក្រៅរដ្ឋាភិបាលនោះទេ ជាការិយាល័យធ្វើការងាររបស់កម្មវិធីមួយនៃសាកលវិទ្យាល័យយ៉ែល។

**ស៖** តើ ឌី.ស៊ី.ខេម ពេលនោះមានស្វ័យភាពនៅក្នុងដំណើរការរបស់ខ្លួនដែរឬទេ?

**ឆ៖** ខ្ញុំគិតថាលោកមេធាវីអាចប្រមើលមើល៍ហើយថា មជ្ឈមណ្ឌលឯកសារកម្ពុជានៅពេលនោះមិនទាន់បង្កើតជាអង្គការឯករាជ្យ និងអង្គការក្រៅរដ្ឋាភិបាលនៅឡើយទេ។ វាជាការិយាល័យមួយធ្វើការងាររបស់កម្មវិធីនៃសាកលវិទ្យាល័យយ៉ែល។

**ស៖** សំណួរបន្ទាប់ ប៉ុន្តែទាក់ទងគ្នាដែរ។ ចំពោះទិដ្ឋភាពទាំងផ្នែកថវិកា ទាំងផ្នែករដ្ឋបាល តើមានភាពខុសគ្នាយ៉ាងណា បន្ទាប់ពីឆ្នាំ១៩៩៧ ចំពោះដំណើរការរបស់ ឌី.ស៊ី.ខេម?

**ឆ៖** មុននឹងឆ្លើយនឹងសំណួរនេះ ខ្ញុំបាទសូមទាញការចាប់អារម្មណ៍លោកមេធាវី លោកប្រធានអង្គជំនុំជម្រះបានរំឮកហើយថា ការអញ្ជើញ កោះអញ្ជើញមកឆ្លើយបំភ្លឺនៅទីនេះគឺទាក់ទងនឹងបញ្ហាឯកសារ។ អ៊ីចឹងខ្ញុំគិតថា លោកមេធាវីគួរតែសួរខ្ញុំបាទអំពីជំនាញ អំពីទាក់ទងទៅនឹងការគ្រប់គ្រងឯកសារ។

[០៩:៤១:០៤]

**ស៖** សូមគោរពលោកប្រធាន ដោយសារថាមានបញ្ហាមួយចំនួនទាក់ទងទៅនឹងការជឿជាក់

ទៅលើឯករាជ្យភាពរបស់ ឌី.ស៊ី.ខេម ដូច្នេះហើយបានជាខ្ញុំលើកពីសំណួរទាំងនេះ ដើម្បីបញ្ជាក់ថា តើ ឌី.ស៊ី.ខេម មានឯករាជ្យភាពនៅក្នុងដំណើរការរបស់ខ្លួនឬទេ? ហើយតើឯកសារដែលខ្លួនបានធ្វើការងាររបស់ខ្លួន អាចទទួលយកបានទេ ប្រសិនបើខ្លួនគ្មានលក្ខណៈឯករាជ្យ ឬមិនឯករាជ្យនោះ?

**ប្រធានអង្គជំនុំ៖**

សំណួរទាំងឡាយគឺបានឆ្លើយរួចហើយកាលពីម្សិលមិញ ហើយអម្បាញ់មិញនេះគឺសាក្សីបានឆ្លើយបញ្ជាក់រួចហើយអំពីភាពពាក់ព័ន្ធទៅនឹងសាកលវិទ្យាល័យយ៉ែល នៅក្នុងអំឡុងពេល៩៥-៩៧។ ជាផ្នែកមួយអនុវត្តកម្មវិធី កាលណាតែអនុវត្តកម្មវិធីរបស់គេ ហើយជាផ្នែកមួយរបស់អង្គភាព ឬរបស់ស្ថាប័នណាមួយ អង្គភាពចំណុះហ្នឹងគឺត្រូវប្រព្រឹត្តិទៅៗតាមស្ថាប័នចម្បង ស្ថាប័នដែលអាណាព្យាបាលហើយ។

អ៊ីចឹងវាច្រើនលើកច្រើនសាហើយ គេបានបញ្ជាក់រួចហើយបញ្ហានេះ ហើយមេធាវីតាំងសំណួរផ្សេងទៀតដែលមានអត្ថន័យខ្លឹមសារទៅតាមការណែនាំរបស់អង្គជំនុំជម្រះសាលាដំបូង ដែលអង្គជំនុំជម្រះបានជម្រាបជូនតាមលិខិតកាលពីសប្តាហ៍មុន ហើយបានរំឭកមុនជូនដល់មេធាវីការពារក្តី នួន ជា ក៏ដូចជាភាគីទាំងអស់ដែលពាក់ព័ន្ធ។

សូមចំណាយពេលវេលាដែលបានបែងចែកឲ្យ ឲ្យមានប្រសិទ្ធភាព។

[០៩:៤៣:០៣]

**សួរដោយលោក ពេជ អង្គ៖**

បាទសូមអរគុណលោកប្រធានចំពោះការណែនាំ។ ខ្ញុំនឹងខំប្រឹងធ្វើតាមការណែនាំរបស់លោកប្រធាន។

**ស៖** ចំពោះដំណើរការរបស់ ឌី.ស៊ី.ខេម ខ្ញុំចង់លើកសំណួរមួយចំនួន នៅក្នុងនោះគឺមានសំណួរចង់សួរថា តើ ឌី.ស៊ី.ខេម ខ្លួនឯងចាត់ទុកថាខ្លួនឯងជាអង្គភាពដែលមានតួនាទីនៅក្នុងការស៊ើបអង្កេតពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដែលកើតឡើងនៅក្នុងសម័យខ្មែរក្រហមដែរឬទេ?

**ឆ៖** សូមជម្រាបលោកមេធាវី មជ្ឈមណ្ឌលឯកសារកម្ពុជាមិនដែលបានប្រើពាក្យ“ស៊ើបអង្កេត” ទេ។

**ស៖** តើ ឌី.ស៊ី.ខេម មានបំណងប្រមូលនូវរាល់ឯកសារទាំងអស់ដែលពាក់ព័ន្ធទៅនឹងខ្មែរក្រហម និងឯកសាររបស់ខ្មែរក្រហមដែរឬទេ?

**ឆ៖** បាទ នេះជាអាណត្តិការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាតែម្តង។

**ស៖** សំណួរមួយពាក់ព័ន្ធទៅនឹងការសិក្សារបស់លោក ដែលលោកបាននិយាយពាក់ព័ន្ធទៅនឹងសាកលវិទ្យាល័យ ញូវសៅវែល តើលោកអាចបញ្ជាក់បានទេ ថាតើអ្វីខ្លះដែលជាខ្លឹមសារនៃការសិក្សារបស់លោកនៅសាកលវិទ្យាល័យនោះ? លោកអាចរៀបរាប់ត្រួសៗបានអំពីខ្លឹមសារនៃការសិក្សានោះបានឬទេ?

**ឆ៖** បាទ នៅពេលដែលខ្ញុំធ្វើការសិក្សានៅសាកលវិទ្យាល័យយែលនេះ គឺនៅក្នុងមហាវិទ្យាល័យទាក់ទងទៅនឹងការចងក្រងឯកសារនេះតែម្តង។

**ស៖** តើនៅក្នុងការចងក្រងឯកសារនោះមានខ្លឹមសារស្អីខ្លះដែលនៅក្នុងជំនាញចងក្រងឯកសារនោះ?

[០៩:៤៥:១៧]

**ឆ៖** ជាពិសេស គឺទាក់ទងទៅនឹងប្រព័ន្ធនៃការគ្រប់គ្រងឯកសារ និងការចងក្រងឯកសារដែលធ្វើយ៉ាងណាឲ្យមានលក្ខណៈងាយស្រួលនៅក្នុងការស្វែងរកព័ត៌មាននៅលើឯកសារ សម្រាប់ការសិក្សាស្រាវជ្រាវក៏ដូចជាសម្រាប់ការស្វែងរកព័ត៌មានផ្សេងៗចេញពីឯកសារនោះ។

**ស៖** លោកបានបញ្ជាក់ម្សិលមិញថា ឌី.ស៊ី.ខេម មិនធ្វើការវិភាគទៅលើឯកសារទេ ខ្ញុំមិនយល់ច្បាស់ថា តើលោកមានន័យយ៉ាងដូចម្តេចចំពោះអ្វីដែលលោកនិយាយថា ឌី.ស៊ី.ខេម មិនធ្វើការវិភាគទៅលើឯកសារទេ។ ដូច្នេះតើលោកអាចពន្យល់បានទេ ថាតើអ្វីដែលលោកនិយាយថា ឌី.ស៊ី.ខេម មិនធ្វើការវិភាគឯកសារនោះមានន័យថាដូចម្តេច?

[០៩:៤៦:១២]

**ឆ៖** ការដែលមិនធ្វើការវិភាគទៅលើឯកសារមានន័យថាយើងមិនបានធ្វើវិភាគដើម្បី-- ទៅលើឯកសារដើម្បីឲ្យដឹងថាឯកសារហ្នឹង ជាឯកសារសំខាន់វាត្រូវយកមកធ្វើការទម្លាក់កំហុសទៅលើបុគ្គលណា នេះជាឧទាហរណ៍តូចមួយសម្រាប់លោកមេធាវីធ្វើការស្វែងយល់អំពីពាក្យថា “ធ្វើការវិភាគទៅលើឯកសារ”។

**ស៖** នៅក្នុងដំណើរការរបស់ខ្លួន ថាតើ ឌី.ស៊ី.ខេម មានបានគិតហើយជាស្រេចទេថា ក្នុងអំឡុងពេល៧៥-៧៩ ហ្នឹង មានឧក្រិដ្ឋកម្មបានកើតឡើង ហើយលោកក៏ប្រមូលឯកសារដើម្បីបញ្ជាក់ថាពិតជាមានឧក្រិដ្ឋកម្មកើតឡើងក្នុងពេលនោះមែន តើអ៊ីចឹងមែនឬទេ?

**ឆ៖** ខ្ញុំបាទជម្រាបយ៉ាងច្បាស់លាស់អំពីគោលបំណងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ហើយខ្ញុំសូមរក្សាសិទ្ធិមិននិយាយម្តងទៀតអំពីបញ្ហានេះ។

**សៈ** ពីម្សិលមិញលោកបាននិយាយច្រើនអំពីបញ្ហានៅក្នុងការគ្រប់គ្រងឯកសារ ការប្រមូលឯកសារ ក៏ប៉ុន្តែនៅចំណុចមួយហាក់ដូចជាលោកពុំទាន់បាននិយាយឲ្យបានច្រើនដើម្បីឲ្យមានការយល់ដឹងកាន់តែទូលំទូលាយ។ ថាតើច្បាប់ដើមដែលលោកបានប្រមូលដាក់នៅក្នុងទូសុវត្ថិភាពនោះ ថាតើលោក*ក្លាសេ* ឯកសារយ៉ាងដូចម្តេច ដើម្បីឲ្យងាយស្រួលរកច្បាប់ដើមនៅក្នុងទូឯកសាររបស់លោក-- របស់ ឌី.ស៊ី.ខេម?

**ឆ៖** ម្សិលមិញ គឺខ្ញុំបាននិយាយយ៉ាងច្បាស់អំពីរបៀបនៃការចុះលេខឯកសារ របៀបនៃការរកឯកសារ ពីឯកសារថតចម្លងទៅឯកសារដើម ដូចជាយើងបានចុះលេខនៅក្រោមលេខ យើងបានដាក់ប្រភពឯកសារនោះ ដើម្បីឲ្យដឹងថាឯកសារថតចម្លងនេះវាចេញពីឯកសារដើមយ៉ាងដូចម្តេច។ ហើយខ្ញុំបាននិយាយរហូតទៅដល់ក្នុងវង់ក្រចកដែលលោកសហព្រះរាជអាជ្ញាបាននិយាយថា នៅក្នុងវង់ក្រចកគឺមានលេខ "9 បបក"។ នេះគឺជាលេខសម្គាល់ដែលយើង-- មជ្ឈមណ្ឌលឯកសារកម្ពុជាដឹងភ្លាមថាឯកសារដើមស្ថិតនៅក្នុងទូណា ស្ថិតនៅក្នុងដុំមួយណា បើសិនជាមានការផ្ទៀងផ្ទាត់ទៅលើឯកសារថតចម្លង។

**សៈ** សូមអរគុណចំពោះការឆ្លើយបំភ្លឺនេះ។ សំណួរមួយទៀតពាក់ព័ន្ធទៅនឹងវិធីសាស្ត្រនៅក្នុងការពិនិត្យយថាភាពនៃឯកសារដែលបានទទួលបាន។ តើលោកអាចជម្រាបបានទេថា តើលោកមានវិធីសាស្ត្រជាក់លាក់ ឬក៏ចរិតលក្ខណៈជាក់លាក់ ដោយមានការរៀបចំឡើងដោយមានលក្ខណៈវិទ្យាសាស្ត្រអំពីវិធីសាស្ត្រនៅក្នុងការពិនិត្យយថាភាពនៃឯកសារដែរឬទេ? សំដៅទៅលើលក្ខណៈវិទ្យាសាស្ត្រ។

**ឆ៖** បើសិនជាសំដៅទៅលើលក្ខណៈវិទ្យាសាស្ត្រ លុះត្រាតែមជ្ឈមណ្ឌលឯកសារកម្ពុជានេះមានការធ្វើកោសល្យវិច័យទៅលើៗប្រភេទក្រដាសនៃឯកសារនីមួយៗ អ៊ីចឹងមជ្ឈមណ្ឌលឯកសារកម្ពុជាអត់មានលទ្ធភាពធ្វើទេ។

[០៩:៤៩:៥៨]

**សៈ** នៅក្នុងការគិតគូរពីបែបបទនៅក្នុងធ្វើយថាភាពរបស់ខ្លួន ថាតើបែបបទវាយតម្លៃអំពីយថាភាពនេះ លោកមានបានពិភាក្សាជាមួយអ្នកដែលនៅខាងក្រៅ ឌី.ស៊ី.ខេម ដែរឬទេ? ឌី.ស៊ី.ខេម មានបានពិភាក្សាជាមួយអ្នកនៅខាងក្រៅ ឌី.ស៊ី.ខេម ដែលជាអ្នកជំនាញផ្សេងៗដែរឬទេ អំពីការ

*ឌីហ្សាញ*បែបបទនៅក្នុងការវាយតម្លៃពីយថាភាពនៃឯកសារ?

**ឆ៖** ជាទូទៅ នៅពេលដែលមានភាពមិនច្បាស់លាស់ណាមួយ គឺយើងបានធ្វើការសួរនាំជាមួយនឹងអ្នកជំនាញផ្នែកឯកសារ ផ្នែកប្រវត្តិសាស្ត្រទាក់ទងទៅនឹងរបបកម្ពុជាប្រជាធិបតេយ្យ ហើយខ្ញុំបានឲ្យឧទាហរណ៍មួយយ៉ាងច្បាស់លាស់ហើយ គឺទាក់ទងទៅនឹងការសួរនាំលោកសាស្ត្រាចារ្យ ដេវីដ ឆេនដ៍ល័រ ទាក់ទងទៅនឹងឯកសារមួយដែលជាឯកសារថតចម្លងដែលវាអត់មានច្បាប់ដើម។ អ៊ីចឹង យើងបានធ្វើការសួរ និងពិភាក្សាឲ្យបានច្បាស់លាស់លើបញ្ហានេះ។

**ស៖** អ៊ីចឹង មានន័យថា ទាល់តែក្នុងករណីដែលមិនច្បាស់ បានយើងទៅទាក់ទងអ្នកជំនាញផ្សេងទៀត?

**ឆ៖** ជាការត្រឹមត្រូវ។

**ស៖** លោកបាននិយាយពីម្សិលមិញអំពីទស្សនាវដ្ដីរបស់ខ្មែរក្រហមចំនួនពីរ គឺទង់បដិវត្ត និងទង់យុវជន យុវនារី ថាតើ ឌី.ស៊ី.ខេម មានទស្សនាវដ្ដីផ្សេងទៀត ក្រៅពីទស្សនាវដ្ដីទាំងពីរនេះដែរឬទេរបស់ខ្មែរក្រហម?

[០៩:៥១:៥៨]

**ឆ៖** នៅក្នុងនោះ មជ្ឈមណ្ឌលឯកសារកម្ពុជាក៏មាននូវកំណត់ហេតុផ្ទាល់ខ្លួនរបស់បុគ្គលដែលជាយុវជន ឬកម្មាភិបាលខ្មែរក្រហមផងដែរ។

**ស៖** តែចំពោះទស្សនាវដ្ដីអត់មានទេ? អត់មានផ្សេងទៀត?

**ឆ៖** ទស្សនាវដ្ដី គឺសំដៅទៅលើទង់បដិវត្តនេះឯង។

**ស៖** ខ្ញុំមានសំណួរនៅមិនច្រើនទេ ខ្ញុំចង់សួរបន្ថែមចំពោះលោកសម្រាប់ជូនលោកបំភ្លឺបន្ថែម។ នៅក្នុងការគ្រប់គ្រងឯកសាររបស់ខ្លួន ថាតើ ឌី.ស៊ី.ខេម មានវិធីសាស្ត្រយ៉ាងណា ដើម្បីធានាថាឯកសារដែលត្រូវបានពិគ្រោះដោយសាធារណជននៅក្នុងបរិវេណរបស់ ឌី.ស៊ី.ខេម នោះមិនត្រូវបានកែប្រែដោយ អ្នកម្នាក់ដែលបានមកពិគ្រោះនោះ?

**ឆ៖** ខ្ញុំសូមលោកមេធាវីសួរសំណួរម្ដងទៀត បញ្ជាក់ឲ្យបានច្បាស់លាស់លើបញ្ហានេះ។

**ស៖** ចង់និយាយ នៅពេលដែលមាន-- អ្នកដែលមកពិគ្រោះឯកសារនៅ ឌី.ស៊ី.ខេម នៅក្នុងបរិវេណ ឌី.ស៊ី.ខេម ថាតើ ឌី.ស៊ី.ខេម មានវិធីផ្ទាល់ខ្លួនដើម្បីធានាថា គ្មានឯកសារណាមួយមិនត្រូវបានកែប្រែ ឬក៏សរសេរពីលើឯកសារនោះ ដោយអ្នកមកពិគ្រោះនោះ ថាតើ ឌី.ស៊ី.ខេម មានវិធីដើម្បីត្រួត

ពិនិត្យដែរឬទេ?

[០៩:៥៣:៤២]

**ឆ៖** បាទ នៅក្នុងការដែលអ្នកសិក្សាស្រាវជ្រាវ ឬអ្នកផ្សេងដែលមិនមែនជាបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជានោះ គឺនៅពេលដែលមកធ្វើការស្រាវជ្រាវ ឬការអានឯកសារ គឺយើងមានទីកន្លែងមួយច្បាស់លាស់ សម្រាប់ឱ្យអ្នកមកធ្វើការសិក្សាស្រាវជ្រាវនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយយើងមិនអនុញ្ញាតឱ្យអ្នកដែលមិនមែនធ្វើការងារនៅមជ្ឈមណ្ឌលឯកសារកម្ពុជា គឺជាពិសេសអ្នកដែលធ្វើការទាក់ទងទៅនឹងឯកសារនេះ ទៅប៉ះពាល់ឯកសារហ្នឹងផ្ទាល់ ឬក៏ទៅយកឯកសារហ្នឹងផ្ទាល់ចេញពីទូនោះទេ គឺយើងមានបុគ្គលិករបស់យើងធ្វើកិច្ចការងារនេះផ្ទាល់ ហើយយកទៅឱ្យអ្នកដែលមកសិក្សាស្រាវជ្រាវ មកអាននេះ អាននៅទីកន្លែងមួយច្បាស់លាស់។ ហើយនៅពេលដែលប្រគល់ឯកសារនេះមកវិញ គឺយើងបានធ្វើការត្រួតពិនិត្យមើល ថាតើការប្រគល់មកនេះ មានឯកសារហ្នឹង គ្រប់គ្រាន់តាមអ្វីដែលយើងបានផ្តល់ជូន ហើយមានការ-- មានលក្ខណៈដូចដើមរបស់វាដែលយើងផ្តល់ជូនទៅអានដែរឬអត់។ ហើយនៅក្នុងនោះ យើងបានប្រាប់ បានជម្រាបជូនជាមុនថាឯកសារនេះមិនត្រូវអនុញ្ញាតឱ្យធ្វើការសរសេរ ឬក៏*ណូត* អីនៅលើហ្នឹងទេ ហើយមិនអាចអនុញ្ញាតឱ្យយកឯកសារនេះចេញពីបរិវេណនៃមជ្ឈមណ្ឌលឯកសារកម្ពុជាទេ។ បើសិនជាត្រូវការថតចម្លង ឬក៏យ៉ាងណានោះ គឺយើងខ្ញុំជាអ្នកសម្រេចឱ្យបុគ្គលិកមួយណាជាអ្នកធ្វើការថតចម្លងជូន ព្រោះឯកសារនេះជាឯកសារអាចនឹងប្រើប្រាស់បានដោយសាធារណជន មិនថានៅក្នុងស្រុក ឬក្រៅស្រុក។

**ស៖** ម្សិលមិញ លោកបាននិយាយថា ខាងមេធាវីការពារក្តីបានទៅពិគ្រោះឯកសារនៅ ឌី.ស៊ី.ខេម ហើយលោកថែមទាំង បាននិយាយថាលោកអាចផ្តល់ទាំងចំនួនឯកសារដែលត្រូវបានកូពីចម្លងចេញផង តើអ៊ីចឹងមែនឬទេ?

**ឆ៖** ត្រឹមត្រូវ។

[០៩:៥៦:០៨]

**ស៖** តើលោកអាចបញ្ជាក់ទេ ថាតើខាងមេធាវីការពារក្តី គាត់បានចម្លងឯកសារប៉ុន្មានហើយរហូតដល់ពេលនេះ?

**ឆ៖** ដូចខ្ញុំបានជម្រាបអ៊ីចឹង ថាចំនួនខ្ញុំមិនអាចជូនច្បាស់លាស់នៅពេលនេះ ប៉ុន្តែបើសិនជាចង់បាន ខ្ញុំនឹងផ្តល់ជូនបាន អាចនឹងប្រាប់សហការីរបស់ខ្ញុំផ្តល់ឯកសារនេះជូនបាន។

**ស៖** លោកបាននិយាយថា លោកគឺជាអ្នកចាត់ចែងផ្ទាល់នៅក្នុងការកូពីឯកសារ ទាំងឯកសារផ្តល់មកផ្នែកផ្សេងៗនៃសាលាក្តីផងដែរ ពីខាង ឌី.ស៊ី.ខេម តើលោកអាចធានាបានទេថា ឯកសារទាំងអស់សុទ្ធតែកូពីបានត្រឹមត្រូវពីច្បាប់ដើមដែលមាននៅ ឌី.ស៊ី.ខេម?

**ឆ៖** រាល់ការផ្តល់ជូនឯកសារ ជាពិសេស គឺមកអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និយាយជារួម គឺយើងមានការ មានការបញ្ជាក់ មានលិខិតបញ្ជាក់ប្រគល់ និងទទួលយ៉ាងច្បាស់លាស់ ដែលនៅក្នុងលិខិតនោះបានបញ្ជាក់ថា តើឯកសារដែលយើងថតចម្លង ឬក៏ស្កេននេះចេញពីឯកសារដើម ឬក៏ឯកសារថតចម្លងដែលនៅមជ្ឈមណ្ឌលឯកសារកម្ពុជា។

**ស៖** សំណួរចុងក្រោយរបស់ខ្ញុំ តើលោកអាចបញ្ជាក់បានទេ ថាតើចំពោះឯកសារដែលលោកមានទាំងអស់នៅ ឌី.ស៊ី.ខេម ឯកសារទាំងអស់នោះសុទ្ធតែមានការធ្វើយថាភាព ឬយ៉ាងណា? បើមាន មានប៉ុន្មាន ប្រហែលជាប៉ុន្មានភាគរយ?

**ឆ៖** ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាទាំងអស់ សុទ្ធតែត្រូវបានធ្វើយថាភាព។

**លោក ពេជ អង្គ៖**

សូមគោរពលោកប្រធាន ខ្ញុំអស់សំណួរហើយ។ សូមអរគុណ។

[០៩:៥៨:០៣]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញ!

**សួរដោយលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

សូមគោរពលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រម សូមគោរពភាគីទាំងអស់។

**ស៖** ខ្ញុំនឹងសួរសំណួរមួយចំនួនទៅកាន់លោក ហើយខ្ញុំសុំទោសជាមុនប្រសិនបើសំណួរខ្ញុំសួរទៅមានលក្ខណៈមិនច្បាស់លាស់ ហើយចម្លើយរបស់លោក វាអាចមានលក្ខណៈច្បាស់លាស់ជាង។ ប៉ុន្តែខ្ញុំគិតថាអ្វីៗគួរតែត្រូវបានឆ្លើយ ឲ្យបានមានលក្ខណៈច្បាស់លាស់ នៅចំពោះមុខអង្គជំនុំជម្រះ។ លោកបានពន្យល់ថានៅពេលដំបូងឡើង គឺការងាររបស់ ឌី.ស៊ី.ខេម ហ្នឹងគឺត្រូវបានធ្វើឡើងក្នុងក្របខ័ណ្ឌជាការិយាល័យសិក្សា។ អ៊ីចឹងថាតើ ឌី.ស៊ី.ខេម នៅតែបន្តអនុវត្តនូវវិធីសាស្ត្រតាមរបៀបសិក្សានេះដែរឬទេ នៅពេលដែល ឌី.ស៊ី.ខេម បានក្លាយទៅជាស្ថាប័នឯករាជ្យនោះ?

[០៩:៥៩:១៨]

**ឆ៖** នៅពេលដែលមជ្ឈមណ្ឌលឯកសារកម្ពុជា បានក្លាយទៅជាស្ថាប័នឯករាជ្យនេះ គឺយើងបានពង្រីកការងាររបស់យើង មិនត្រឹមតែប្រមែប្រមូលចងក្រង ប៉ុន្តែយើងបានពង្រីកការងារនេះរហូតទៅដល់ការបង្រៀន ការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនេះ ទៅដល់សិស្សានុសិស្សថែមទៀតផង។

**ស៖** ខ្ញុំចង់សង្កត់ធ្ងន់បន្តិច ខ្ញុំចង់និយាយអំពីវិធីសាស្ត្រនៃការធ្វើការរបស់លោក ថាតើវិធីសាស្ត្រហ្នឹងមានលក្ខណៈតឹងតែង ឬក៏តឹងរ៉ឹងដែរឬទេ?

**ឆ៖** ខ្ញុំគិតថា បើនិយាយអំពីវិធីសាស្ត្រធ្វើការងារ តើលោកស្រីចង់សំដៅលើការងារមួយណាបាទ?

**ស៖** ខ្ញុំនិយាយទៅលើការងារវិទ្យាសាស្ត្រ ដែលលោកបានចាប់ផ្តើមធ្វើការក្នុងក្របខ័ណ្ឌ នៃការសិក្សា ហើយខ្ញុំចង់ដឹងថា តើលោកនៅតែបន្តធ្វើការតាមរបៀបវិធីសាស្ត្រនេះដដែល ដោយពង្រីកនៃដែននៃការស្រាវជ្រាវរបស់លោក? តើអ៊ីចឹងមែនទេ?

**ឆ៖** បាទដូចបានជម្រាបរួចមកហើយថាមជ្ឈមណ្ឌលឯកសារកម្ពុជា បានទទួលការអនុញ្ញាតអំពីរាជរដ្ឋាភិបាលកម្ពុជានៅក្នុងការធ្វើការស្រាវជ្រាវ និងចងក្រងឯកសារ។ អ៊ីចឹងនៅក្នុងការស្រាវជ្រាវចងក្រងឯកសារនេះ គឺយើងធ្វើបាន-- អាចធ្វើបានដោយទូលំទូលាយ ទាំងនៅក្នុងប្រទេស និងក្រៅប្រទេស ហើយការធ្វើការងារនេះ គឺនឹងបន្តរហូតតទៅមុខទៀត ដែលបច្ចុប្បន្ននេះមជ្ឈមណ្ឌលឯកសារកម្ពុជា មានគម្រោងនឹងបង្កើតទៅជាវិទ្យាស្ថានស្រាវជ្រាវអចិន្ត្រៃយ៍ ទាក់ទងទៅនឹងរបបកម្ពុជាប្រជាធិបតេយ្យដែលវិទ្យាស្ថាននេះ យើងឲ្យឈ្មោះថា "វិទ្យាស្ថានស្លឹករឹត"។

**ស៖** សូមអរគុណ។ តើយើងអាចនិយាយបានទេថា ការងាររបស់ ឌី.ស៊ី.ខេម គឺជាការងារវិទ្យាសាស្ត្រក្នុងការស្រាវជ្រាវប្រវត្តិសាស្ត្រនោះ?

**ឆ៖** តើ-- ខ្ញុំហាក់បីដូចជាមិនយល់ត្រង់ភាសាដែលបកប្រែថា ការងារជាការងារវិទ្យាសាស្ត្របាទ។ សូមលោកស្រីមេត្តាបញ្ជាក់ឲ្យបានច្បាស់ជាងនេះបន្តិច ថាតើការងារវិទ្យាសាស្ត្រហ្នឹងវាស្ថិតទៅលើការចងក្រងឯកសារ ឬក៏យ៉ាងម៉េចបាទ? សូមលោកស្រីមេត្តាបញ្ជាក់ឲ្យបានច្បាស់លាស់។

[១០:០២:៣៩]

**ស៖** គឺខ្ញុំសំដៅទៅដល់វិធីសាស្ត្រការងាររបស់លោកដែលលោកបានរៀននៅសាកលវិទ្យាល័យនោះ។

**ឆ៖** បាទ ត្រឹមត្រូវហើយបាទ។

**ស៖** នៅក្នុងដំណើរការនៃការស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រ នៅក្នុងសាកលវិទ្យាល័យនោះ តើយើងមានវិធាននៃវិធីសាស្ត្រ ពាក់ព័ន្ធទៅនឹងការប្រមូល និងការចាត់ថ្នាក់ឯកសារប្រវត្តិសាស្ត្រដែរឬទេ? ហើយតើថាវិធាននៃវិធីសាស្ត្រហ្នឹង ដែលលោកអនុវត្តនៅពេលដែលលោកពិពណ៌នាយ៉ាងច្បាស់លាស់អំពីរបៀបដែល ឌី.ស៊ី.ខេម ប្រមូលឯកសារ ចំណាត់ថ្នាក់ ហើយនិងថែរក្សាឯកសារទាំងអស់នេះ?

[១០:០៣:៣២]

**ឆ៖** បាទជាការត្រឹមត្រូវ គឺការដែលយល់ ការដែលដឹង ការដែលធ្វើការងារបច្ចុប្បន្នគឺវាទាក់ទង ទៅនឹងអ្វីដែលយើងបានសិក្សារៀនសូត្រនេះឯង។

**ស៖** តើក្រៅពីវិធាននៃវិធីសាស្ត្រទាំងអស់នេះ ហើយនៅក្នុងការងារស្រាវជ្រាវរបស់លោកហ្នឹង គឺមានក្រមសីលធម៌វិជ្ជាជីវៈដែរឬទេ?

**ឆ៖** បាទ ជាការត្រឹមត្រូវ គឺមានក្រមសីលធម៌ មុននឹងចូល-- មុននឹងចុះទៅធ្វើការសិក្សាស្រាវជ្រាវតាមបណ្ដាខេត្ត តាមកន្លែងផ្សេងៗ គឺយើងមានក្រមសីលធម៌មួយច្បាស់លាស់បាទ ដើម្បីធ្វើយ៉ាងណាឲ្យបុគ្គលិក ឬក៏ខ្លួនខ្ញុំផ្ទាល់ គឺថាចុះធ្វើការងារឲ្យមានវិន័យត្រឹមត្រូវ ឲ្យមានក្រមសីលធម៌ត្រឹមត្រូវ នៅពេលដែលយើងចុះធ្វើការងារ។

[១០:០៤:៤៩]

**ស៖** សូមអរគុណ។ ពាក់ព័ន្ធទៅនឹងការសម្ភាសមនុស្ស ដែលយើងបាននិយាយ តើនៅក្នុងដំណើរការ ឬក៏លក្ខណៈវិទ្យាសាស្ត្រ ក៏សាកលវិទ្យាល័យនោះ តើយើងមានវិធានវិធីសាស្ត្រ ហើយនិងក្រមសីលធម៌សម្រាប់ការសម្ភាសមនុស្សដែរឬទេ?

**ឆ៖** ទាក់ទងទៅនឹងការសម្ភាស យើងមានជាកម្រងសំណួរដើម្បីសួរទៅអ្នកផ្ដល់សម្ភាស ហើយកម្រងសំណួរនេះ ត្រូវបានពិនិត្យដោយទីប្រឹក្សាច្បាប់ជាន់ខ្ពស់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ហើយកម្រងសំណួរនេះក៏ត្រូវបានផ្ដល់ជូនទៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែរ គឺជាពិសេស គឺដល់អង្គភាព ការិយាល័យសហចៅក្រមស៊ើបអង្កេត។

**ស៖** តើរបៀបដែលធ្វើនេះគឺវាដូចគ្នាទៅនឹងនៅពេល ដែលលោកទទួលបានការបណ្ដុះបណ្ដាលដែរឬទេ?

[១០:០៦:១៤]

**ឆ៖** ការចងក្រងឯកសារ ដែលយើងបណ្តុះបណ្តាល-- ទទួលបានការបណ្តុះបណ្តាលនេះគឺវាទាក់ទងទៅនឹងការរៀបចំចងក្រងឯកសារ។ ឯរឿងធ្វើការ ធ្វើសម្ភាស គឺជារឿងមួយដាច់ដោយឡែកផ្សេងទៀត។

**ស៖** សូមអរគុណ។ តើយើងអាចនិយាយបានទេថា លោកមានឯកទេសខាងការស្រាវជ្រាវឯកសារប្រវត្តិសាស្ត្រហ្នឹង?

**ឆ៖** សូមលោកស្រីមេធាវីមេត្តាបញ្ជាក់ម្តងទៀត ថាតើសំណួរនេះយ៉ាងម៉េច? សូមបញ្ជាក់ម្តងទៀត។

**ស៖** ខ្ញុំនឹងនិយាយម្តងទៀត។ តើយើងអាចនិយាយបានថា លោកជាអ្នកឯកទេសខាងការស្រាវជ្រាវឯកសារប្រវត្តិសាស្ត្រដែរឬទេ?

**ឆ៖** បាទ ខ្ញុំធ្វើការងារនេះរយៈពេល១៧ឆ្នាំ ខ្ញុំគិតថា វាល្មមគ្រប់គ្រាន់ ដែលខ្ញុំអាចនឹងធ្វើការសិក្សាស្រាវជ្រាវលើឯកសារទាំងអស់នេះ។

**ស៖** តើឥឡូវនេះ ឌី.ស៊ី.ខេម នៅតែបន្តសហការជាមួយនឹងសាកលវិទ្យាបរទេស ក្រៅពីសាកលវិទ្យាល័យ យ៉េល ដែរឬទេទៅលើការងារស្រាវជ្រាវនេះ?

**ឆ៖** ជាការត្រឹមត្រូវណាស់ មជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើការងារជាមួយសាកលវិទ្យាល័យជាច្រើន មិនតែ ត្រឹមតែសាកលវិទ្យាល័យយ៉េលទេ។ ខ្ញុំអាចរៀបរាប់បានដូចជា សាកលវិទ្យាល័យសាន់តា ក្លារ៉ា, សាកលវិទ្យាល័យ រ៉ាត់ហ្គ័រ និងសាកលវិទ្យាល័យ ថេមផល មានច្រើនទៀត។

[១០:០៨:៣៥]

**ស៖** តើបើតាមលោក ឌី.ស៊ី.ខេម ហ្នឹងទទួលបានកេរ្តិ៍ឈ្មោះល្អ ចំពោះសាកលវិទ្យាល័យ អ្នកស្រាវជ្រាវ ឬក៏អ្នកជំនាញការបរទេសដែរឬទេ?

**ឆ៖** សូមឲ្យសាធារណជនជាអ្នកវាយតម្លៃចុះបាទ ឆ្លើយដោយខ្លួនឯង ហាក់បីដូចជាការសរសើរខ្លួនឯងអ៊ីចឹង។

**ស៖** ពាក់ព័ន្ធទៅនឹងការស្រាវជ្រាវឯកសារ តើបទពិសោធន៍វិជ្ជាជីវៈរបស់លោក ហើយនិងចំណេះដឹងរបស់លោកទៅលើប្រវត្តិសាស្ត្រនៃរបបកម្ពុជាប្រជាធិបតេយ្យ អាចឲ្យលោកដឹងអំពីកន្លែងដែលខ្មែរក្រហមកាន់កាប់ ឬរក្សាទុកឯកសារដែរឬទេ?

**ឆ៖** បាទ វាជាការត្រឹមត្រូវណាស់ ព្រោះបើយើងពិនិត្យមើលអំពីស្ថានភាពនៅពេលដែលរបបកម្ពុជាប្រជាធិបតេយ្យដួលរលំទៅ គឺថាម្នាក់ៗគឺស្វែងរកការរស់ដែលមិនបានគិតអំពីឯកសារអំពីឯកសារប្រវត្តិសាស្ត្រនោះទេ។ អ៊ីចឹង នៅពេលដែលយើងមានការរៀនសូត្រ មានការបណ្តុះបណ្តាល គឺយើងបានដឹងអំពីតម្លៃនៃឯកសារ អំពីតម្លៃនៃប្រវត្តិសាស្ត្រ។ ហើយយើងបានដឹងអំពីថា តើការទៅស្វែងរកឯកសារនេះ គឺអាចបានដឹងទៅទីកន្លែងណាអាចមានឯកសារ ទីកន្លែងណាអាចមាន-- ហើយដោយសារថា មានអនុញ្ញាតដោយត្រឹមត្រូវដោយរដ្ឋាភិបាល គឺមជ្ឈមណ្ឌលឯកសារម្ពុជាអាចចុះទៅធ្វើការសិក្សាស្រាវជ្រាវបានគ្រប់ទីកន្លែងទាំងអស់នៅក្នុងព្រះរាជណាចក្រកម្ពុជា ក៏ដូចជាក្រៅប្រទេសដែរ។

**ស៖** ក្នុងករណីនេះ តើការប្រមូលឯកសាររបស់លោកហ្នឹង គឺវាស៊ីសង្វាក់គ្នាទៅនឹងអ្វីដែលលោកធ្លាប់បានគិតនេះទេ? និយាយម្យ៉ាងទៀត គឺបានន័យថាតើមានភាពស៊ីសង្វាក់គ្នារវាងប្រភពនៃឯកសារមួយចំនួនដែលលោកបានរក្សាទុក ហើយនិងកន្លែងដែលខ្មែរក្រហមត្រូវបានសន្មតថារក្សាឯកសារនៅកន្លែងនោះ?

[១០:១១:២៥]

**ឆ៖** ចំពោះបញ្ហានេះ ខ្ញុំសូមផ្តល់ជាឧទាហរណ៍មួយ គឺកំណត់ហេតុរបស់បុគ្គលម្នាក់ដែលនិយាយអំពីការសិក្សារៀន ការហ្វឹកហ្វឺន ទាក់ទងទៅនឹងវិជ្ជាពេទ្យ។ ឯកសារនេះត្រូវបានរកឃើញនៅទួលស្លែង។ អ៊ីចឹងមានន័យថាឯកសារនេះត្រូវបានទុកដាក់ដោយបុគ្គលនោះឯងនៅពេលដែលបុគ្គលនោះត្រូវបានបញ្ជូនមកទួលស្លែង ឯកសារនេះវាមកជាមួយនឹងបុគ្គលដែលជាម្ចាស់ឯកសារនេះ។ ហើយដូច្នេះហើយ បានជាឯកសារមួយនេះត្រូវបានរកឃើញនៅទួលស្លែងទៅវិញ ដែលមិនមែនរកឃើញនៅក្រសួងសុខាភិបាល។

**ស៖** សូមអរគុណ។ ខ្ញុំមានសំណួរមួយចំនួនតូចទៀត ពាក់ព័ន្ធទៅនឹងការប្រើប្រាស់ឯកសាររបស់ ឌី.ស៊ី.ខេម ដោយភាគីដែលមានវត្តមាននៅទីនេះ។ លោកបានបញ្ជាក់ជូនយើងថាលោកបានផ្តល់ជូនឯកសារទៅមនុស្សមួយចំនួនមានដូចជាអ្នកជំនាញការ អ្នកស្រាវជ្រាវ សិស្ស និស្សិត ហើយនិងបុគ្គលដែលធ្វើការនៅ អ.វ.ត.ក ហើយជាពិសេសគឺសហព្រះរាជអាជ្ញា ដើមបណ្តឹងរដ្ឋប្បវេណី ហើយនិងមេធាវីការពារក្តី។ ហើយលោកបាននិយាយផងដែរថា ឌី.ស៊ី.ខេម បានស្នើឲ្យភាគីទាំងអស់មកការិយាល័យរបស់លោក។ ឧទាហរណ៍ ដូចជាខាងសហមេធាវីការពារក្តីបានទៅកន្លែងរបស់លោកមួយសប្តាហ៍ម្តង។

[១០:១៣:១៦]

ខ្ញុំនិយាយពីការទៅរបស់ភាគីទាំងអស់។ តើនៅពេលដែលទៅមើលឯកសារទាំងអស់ហ្នឹង តើបុគ្គលិករបស់ ឌី.ស៊ី.ខេម ហ្នឹងគាត់តម្រង់ទិស ឬក៏ណែនាំដល់ភាគីក្នុងការស្រាវជ្រាវ ឬក៏ស្វែងរកឯកសារ ហើយផ្តល់ការពន្យល់អីដែរឬទេ?

**ឆ៖** ទាក់ទងនឹងបញ្ហានេះ គឺយើងបាន-- ព្រោះថាជួនកាលអ្នកដែលទៅធ្វើការសិក្សាស្រាវជ្រាវមិនថា តែមន្ត្រីមកពីអង្គជំនុំជម្រះវិសាមញ្ញទេ មន្ត្រី-- អ្នកផ្សេងទៀតក៏ដោយ ឲ្យតែទៅដល់មជ្ឈមណ្ឌលឯកសារកម្ពុជា គឺយើងបានណែនាំ យើងបានផ្តល់ជាការណែនាំមួយ អំពីរបៀបនៃការស្វែងរកឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ព្រោះឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជា មានច្រើនមានច្រើនប្រភេទ។ ដូច្នេះ យើងមានការណែនាំអំពីការទទួលបាននូវឯកសារ ការដែលអាចថា ប្រភេទនៃឯកសារដែលយើងបានផ្តល់ជូន ដែលជាព័ត៌មានទូទៅមួយដែលធ្វើឲ្យអ្នកទៅធ្វើការស្រាវជ្រាវ ធ្វើការនៅ-- ទៅអានមានលក្ខណៈងាយស្រួល។

[១០:១៥:០១]

**ស៖** តើលោកមានអារម្មណ៍ថា បានជួយដល់ភាគីដែលមានវត្តមាននៅទីនេះដោយយុត្តិធម៌ដែរឬទេ នៅពេលដែលគេត្រូវការជំនួយពីលោកនោះ?

**ឆ៖** មជ្ឈមណ្ឌលឯកសារកម្ពុជាបានទទួលនូវ ការទទួលស្គាល់ពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ជាអ្នកដែលផ្តល់ឯកសារជូនដល់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ហើយជារៀងរាល់ថ្ងៃដែរ គឺថាមានអ្នកស្រាវជ្រាវដទៃទៀតបានផ្ញើជាសារអ៊ីម៉ែលមកថ្លែងអំណរគុណចំពោះការផ្តល់ជូនឯកសារដល់ខ្លួន ដែលយកទៅធ្វើការសិក្សាស្រាវជ្រាវ។

**ស៖** សំណួរគឺថាយ៉ាងម៉េច គឺសំបុត្រពីភាគី?

**ឆ៖** បាទ លិខិតចេញពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាតែម្តង។

**ស៖** តើមានម្តងណានោះ ឌី.ស៊ី.ខេម ត្រូវបានទទួលការរិះគន់ពាក់ព័ន្ធទៅនឹងវិធីសាស្ត្រប្រមូលឯកសារដោយភាគីដែលមានវត្តមាននៅទីនេះដែរឬទេ?

**ឆ៖** សូមលោកស្រីមេធាវីបញ្ជាក់ពេលវេលាឲ្យបានច្បាស់លាស់ ដើម្បីខ្ញុំអាចនឹងដឹងបាន ឬចងចាំបានអំពីបញ្ហានេះ។

[១០:១៧:០១២]

**ស៖** ខ្ញុំមិនបញ្ជាក់អំពីកាលបរិច្ឆេទទេ។ ខ្ញុំចង់សួរជាលក្ខណៈទូទៅថា តើ ឌី.ស៊ី.ខេម ហ្នឹងធ្លាប់បានទទួលនូវការរិះគន់ពីភាគីណាមួយនៃអង្គជំនុំជម្រះដែរឬទេ ពាក់ព័ន្ធទៅនឹងការប្រមូលឯកសារទាំងអស់នេះ?

**ឆ៖** ចំពោះការផ្តល់ឯកសារជូនមកអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺយើងផ្តល់ជូនតាមការស្នើសុំ បើសិនគ្មានការស្នើសុំ យើងមិនផ្តល់ជូន។

**ស៖** ខ្ញុំនឹងសួរសំណួរនេះតាមរបៀបផ្សេងវិញ។ តើភាគីដែលទៅពិគ្រោះឯកសារនៅកន្លែងរបស់លោកនោះ មានធ្លាប់រិះគន់ខាងលោកពាក់ព័ន្ធទៅនឹងគុណភាពនៃការងារស្រាវស្រាវឯកសាររបស់លោកដែរឬទេ?

[១០:១៨:២៦]

**ឆ៖** លោកស្រីចង់សំដៅទៅលើភាគីនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬក៏យ៉ាងម៉េចបាទ? សូមលោកស្រីបញ្ជាក់ឲ្យបានច្បាស់លាស់បន្តិចលើបញ្ហានេះ។

**ស៖** បាទ ពិតហើយ គឺភាគីនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

**ឆ៖** ដូចខ្ញុំបានជម្រាបរួចមកហើយថា រាល់ការផ្តល់ជូនឯកសារមកគ្រប់ភាគីទាំងអស់ គឺលុះត្រាតែមានការស្នើសុំ ហើយយើងបានផ្តល់ទៅតាមការស្នើសុំតាមពេលវេលាមួយដែលលឿន ដែលអាចទទួលយកបាន ហើយការផ្តល់នេះដោយអត់មានៗគិតជាៗលុយជាកាក់អីទេ។ មានន័យថាយើងផ្តល់ដោយឥតគិតថ្លៃតែម្តង។

**ស៖** ដូច្នេះខ្ញុំសន្និដ្ឋានថា គឺលោកអត់ធ្លាប់ជូននូវការជំទាស់តវ៉ា ឬក៏ការមិនពេញចិត្ត ការខឹងសម្បាអីពីភាគីទេ តើមានទេ?

**ឆ៖** លោកស្រីអាចនិយាយបែបនេះបានបាទ។

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

សូមអរគុណលោកប្រធាន ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណសាក្សី។ ឥឡូវនេះដល់ពេលសមល្មមនឹងសម្រាកហើយដែរ ដូច្នេះអង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយខ្វះម្ភៃនាទី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ ហើយមន្ត្រីច្បាប់សម្របសម្រួលដល់សាក្សី ដើម្បីរកកន្លែងសម្រាក

សមរម្យ ហើយនិងឲ្យអញ្ជើញគាត់មកកាន់ទីកន្លែងដែលគាត់ត្រូវផ្តល់សក្ខីកម្មនេះឲ្យបានមុនអង្គជំនុំជម្រះចូលមកកាន់អាសនៈ។

សូមអញ្ជើញ!

**លោក អាង ឧត្តម៖**

សូមគោរពលោកប្រធាន។ ខ្ញុំបាទសូមលោកប្រធានមេត្តាអនុញ្ញាតឲ្យលោក អៀង សារី ចូលរួមសវនាការនៅបន្ទប់រង់ចាំខាងក្រោមសម្រាប់ថ្ងៃនេះ ដោយសារមូលហេតុសុខភាពរបស់គាត់ គឺគាត់ពិបាកក្នុងការទ្រាំទ្រអង្គុយ ហើយពាក្យសុំយើងខ្ញុំបាទ នឹងដាក់មកតាមតម្រូវ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បានន័យថា គាត់លះបង់សិទ្ធិក្នុងការចូលរួមផ្ទាល់នៅក្នុងបន្ទប់សវនាការនេះ ឬក៏យ៉ាងម៉េច? ដូចជាអាចវិលងមួយនៅក្នុងការលះបង់សិទ្ធិនៅទីនេះ អ៊ីចឹងការសម្រេច គឺសម្រេចពាក់ព័ន្ធនឹងបញ្ហាពីរ ទីមួយ ទទួលយល់ព្រមតាមការលះបង់សិទ្ធិ នៅក្នុងការចូលរួមផ្ទាល់។ ហើយទីពីរ គឺអនុញ្ញាតឲ្យដកខ្លួនថយទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។ យើងបានរៀបហើយថា បើធ្វើពាក្យ ធ្វើសំណើសុំ គឺសូមធ្វើឲ្យបានក្បោះក្បាយ ច្បាស់លាស់ទៅតាមអ្វីដែលបានណែនាំរួចហើយអំពីការដែលលះបង់សិទ្ធិនេះ។

[១០:២១:៥០]

**លោក អាង ឧត្តម៖**

បាទ ខ្ញុំបាទចង់មានន័យថា យកជម្រើសទីពីរ គឺសូមចូលរួមសវនាការពីចម្ងាយនៅបន្ទប់ជាន់ក្រោមសម្រាប់ថ្ងៃនេះ។

**ប្រធានអង្គជំនុំ៖**

សិទ្ធិនៅក្នុងការចូលរួមផ្ទាល់ទេ អ៊ីចឹង? លះបង់សិទ្ធិចូលរួមផ្ទាល់ទេ ឥឡូវនេះ?

**លោក អាង ឧត្តម៖**

សូមលះបង់សិទ្ធិចូលរួមផ្ទាល់ ប៉ុន្តែសុំចូលរួមសវនាការដោយប្រយោល និងពីចម្ងាយនៅបន្ទប់ជាន់ក្រោម។ សូមអរគុណ សម្រាប់ថ្ងៃនេះ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះយល់ព្រមតាមសំណើសុំរបស់មេធាវី អៀង សារី ដែលបានស្នើសុំតាមរយៈ

មេធាវីរបស់គាត់ក្នុងការលះបង់សិទ្ធិចូលរួមនៅក្នុង តាមដានកិច្ចដំណើរការសវនាការដោយផ្ទាល់នៅក្នុងបន្ទប់សវនាការ ដោយទៅចូលរួម-- អនុញ្ញាតឲ្យទៅចូលរួមនូវកិច្ចដំណើរការសវនាការពីចម្ងាយតាមមធ្យោបាយសោតទស្សន៍នៅបន្ទប់ខាងក្រោមនៃបន្ទប់សវនាការនេះ។

ហើយអនុរក្សមន្ទីរឃុំឃាំងឲ្យនាំខ្លួនគាត់ទៅកាន់បន្ទប់រង់ចាំ ដែលមានឧបករណ៍សោតទស្សន៍រៀបចំសម្រាប់គាត់នៅខាងក្រោម ហើយសម្រាប់ថ្ងៃនេះ ហើយបង្គាប់ឲ្យមន្ត្រីខាងសោតទស្សន៍ សូមភ្ជាប់រូបភាព ប្រព័ន្ធសោតទស្សន៍សំឡេងសម្រាប់លោក អៀង សារី នៅក្នុងអំឡុងពេលដំណើរការសវនាការ។

សូមសម្រាកចុះ!

*(សវនាការសម្រាកនៅម៉ោង ១០:២៣ នាទី ដល់ម៉ោង១០:៤២នាទី)*

[១០:៤២:៣០]

**ប្រធានអង្គជំនុំ៖**

សូមអង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយមុននឹងផ្តល់វេទិកាទៅក្រុមមេធាវីការពារក្តី សូមសួរទៅអស់លោក លោកស្រីចៅក្រម តើមានសំណួរអ្វីត្រូវសួរបន្ថែមដល់សាក្សីរូបនេះទេ? ប្រសិនបើមានសូមអញ្ជើញ។

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក់ ឡាវែន៍។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។ កាលពីម្សិលមិញខ្ញុំបានបញ្ជាក់ថា មានឯកសារផ្សេងទៀតដែលត្រូវបង្ហាញជូនសាក្សី ហើយឥឡូវនេះខ្ញុំឆ្លៀតឱកាសនូវវត្តមានរបស់គាត់នេះ ដើម្បីសួរសំណួរមួយចំនួនពាក់ព័ន្ធទៅនឹងទូរលេខ ដើម្បីឲ្យគាត់ផ្តល់ទៅតាមលទ្ធភាពដែលគាត់ដឹង ផ្តល់នូវការពន្យល់ពាក់ព័ន្ធទៅនឹងព័ត៌មាន ឬក៏ការចង្អុលបង្ហាញមួយចំនួនទៅលើឯកសារទាំងអស់នេះ។

ឯកសារទីមួយដែលខ្ញុំចង់បង្ហាញនៅលើអេក្រង់ គឺជាឯកសារដែលមានលេខដូចទៅនេះ គទៅនេះគឺ IS21.3 លេខERNជាភាសាបារាំង 00386260 ជាភាសាអង់គ្លេស 00185064 រហូតដល់ 00185065។ ជាភាសាខ្មែរ 00024 ទៅដល់ 84-- ទៅដល់ 0002084 ដល់ 95 សូមឲ្យក្រឡាបញ្ជី

បង្ហាញឯកសារនេះនៅលើអេក្រង់។

[១០:៤៤:៥២]

**ប្រធានអង្គជំនុំ៖**

មន្ត្រីតុលាការអាចបង្ហាញឯកសារ នៅលើអេក្រង់ទូរទស្សន៍។

*(ការបញ្ចាំងឯកសារនៅលើអេក្រង់ទូរទស្សន៍)*

យកឯកសារដើមមួយទៅជូនគាត់ទៅ! អត់ទេ ឯកសារជាក្រដាស!

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** សំណួរទីមួយពាក់ព័ន្ធទៅនឹងចំណារ ដែលយើងឃើញនៅខាងលើ ខាងស្តាំនៃឯកសារនេះ។ កាលពីម្សិលមិញ លោកបានចង្អុលបង្ហាញរួចមកហើយ។ ដូច្នេះ ថ្ងៃនេះខ្ញុំចង់ឲ្យលោកបញ្ជាក់ថា តើលោកអាចបញ្ជាក់បានទេ អំពីចំណារ គឺយើងឃើញមាន “LM” ឬក៏ “NM” ខ្ញុំមិនច្បាស់ទេ ហើយបន្ទាប់មកមានលេខមួយចំនួន។ តើលោកអាចពន្យល់បានទេ ថាតើអក្សរ ហើយនិងលេខនេះ វាមានន័យថាម៉េចដែរ?

**លោក វ៉ាន់ថាន់ ដាវ៉ាពៅ៖**

**ឆ៖** សូមអរគុណលោកចៅក្រម។ នៅក្នុងឯកសារមួយនេះ តាមដែលខ្ញុំអាចចាំច្បាស់បាន គឺថាជាឯកសារដែលមាននៅក្នុងបណ្តុំឯកសារ លន់ នល់ *ដូស្សេ* ហើយដែលឯកសារនេះត្រូវបានចុះលេខដោយភ័ន្តច្រឡំដាក់ថា “N” ពីខាងដើម។ ព្រោះដោយសារថាយើងកំណត់យកឯកសារ នល់ នល់ *ដូស្សេ* ចុះលេខដោយអក្សរ “L” ជាអក្សរសម្គាល់សម្រាប់ឯកសារលន់ នល់ “*ដូស្សេ*”នេះ ទើបយើងកែមកពី “N” ដាក់មក “L” វិញ។ ហើយលេខនៅខាងក្រោម ដែលដាក់នៅក្នុងរង់ក្រចក ដាក់ថា “01” ហើយ “ប.ប.ក” នេះគឺដាក់ដើម្បីចង្អុលបង្ហាញបន្ថែមអំពីប្រភពឯកសារ ដែលអាចយើងទៅរកឯកសារដើមបានឃើញដោយងាយស្រួល។

[១០:៤៧:៥៦]

**ស៖** តើប្រភពនេះវាចេញមកពីក្រសួងមហាផ្ទៃមែនទេ?

**ឆ៖** ជាការត្រឹមត្រូវលោកចៅក្រម។

**ស៖** តើព័ត៌មាននេះអាចឲ្យយើងគិតបានថា លោកក៏មានច្បាប់ដើមនៃឯកសារនេះដែរមែនទេ

នៅក្នុងបណ្ណសាររបស់លោកនៅ ឌី.ស៊ី.ខេម នោះ?

**ឆ៖** បាទ។

**ស៖** សូមអរគុណ។ លោកបានបញ្ជាក់ថា ឯកសារនោះត្រូវបានដាក់នៅក្នុងប្រភេទឯកសារ លន់ នល់។ តើលោកអាចបញ្ជាក់ជូនបានទេថា តើអក្សរ “N” នុំងពាក់ព័ន្ធទៅនឹងឯកសារ នួន ជា ឬក៏យ៉ាងណា?

**ឆ៖** វាមិនមានន័យដូច្នេះទេបាទ។ គ្រាន់តែជាការសម្គាល់លើប្រភេទឯកសារ ដែលយើងបានបែងចែកតែប៉ុណ្ណោះ។

**ស៖** ខ្លឹមសារនៃទូរលេខនេះនឹងត្រូវពិនិត្យនៅពេលក្រោយ ប៉ុន្តែអ្វីដែលខ្ញុំចង់ដឹងនៅពេលនេះ គឺចង់ដឹងអំពីរចនាសម្ព័ន្ធនៃទូរលេខនេះ គឺទូរលេខនេះ គឺលេខ១៥ តើលោកដឹងទេថា តើលេខ១៥នេះមានន័យថាម៉េច? គឺថាទូរលេខទី១៥ប្រចាំថ្ងៃ ឬក៏យ៉ាងម៉េចដែរ? លោកអាចពន្យល់អំពីលេខ១៥នេះបានទេ?

[១០:៥០:00]

**ឆ៖** ខ្ញុំបាទគ្រាន់តែដឹងថា ទូរលេខនេះមានលេខ១៥ ប៉ុន្តែន័យថា១៥នេះយ៉ាងម៉េច យើងអត់ដឹងទេ។

**ស៖** ខ្ញុំចង់ឲ្យលោកបំភ្លឺចំណុចមួយទៀត គឺចំណុចនៅខាងក្រោម នៅខាងឆ្វេង។ តើលោកអាចអានអានបានទេនៅខាងក្រោមខាងឆ្វេង?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រ ខ្ញុំអាចអានបាន។ គឺពាក្យសរសេរថា “ចម្លងជូន បង នួន, បង ឌឿន, បង យ៉ែម ទុកឯកសារ”។

**ស៖** បើតាមដែលលោកដឹងនោះ តើលោកអាចបញ្ជាក់ជូនអង្គជំនុំជម្រះបានទេថាតើឈ្មោះ នួន, ឌឿន, យ៉ែម នោះជាឈ្មោះអ្នកណាដែរ?

**ឆ៖** បាទអឺ! តាមការចំណាំនៅក្នុងការអានឯកសារជាច្រើននៅមជ្ឈមណ្ឌលឯកសារកម្ពុជា ជាពិសេសគឺឯកសាររបស់របបកម្ពុជាប្រជាធិបតេយ្យនេះតែម្តង គឺយើងតែងតែសម្គាល់ឃើញមានដាក់ឈ្មោះយ៉ាងដូច្នេះ “ចម្លងជូន” ពាក្យថា “បង នួន, បង ឌឿន, បង យ៉ែម” ហើយតាមការយល់ដឹងរបស់ខ្ញុំគឺនៅក្នុងការប្រើពាក្យបងនេះ គឺមានន័យថាអ្នកដែលមានឋានៈខ្ពស់ជាង អ្នកដែលធ្វើ ដែលមានឈ្មោះនៅក្នុងឯកសារនេះ ហើយគឺមានឋានៈខ្ពស់ជាង ហើយឈ្មោះ បងនួន នេះ តាមការអានទៅលើឯកសារច្រើន គឺចង់សំដៅទៅលើលោក នួន ជា។

[១០:៥២:២៨]

**ស៖** តើ ឌឹម ហើយនិង-- ហ្នឹង តើលោកដឹងទេថាជាអ្នកណាដែរ?

**ឆ៖** ខ្ញុំបាទមិនច្បាស់លាស់ទេអំពីឈ្មោះពីរទៀត។

**ស៖** សូមអរគុណ។ បើតាមលោកដឹងតើព័ត៌មានពាក់ព័ន្ធទៅនឹងអ្នកដែលត្រូវទទួលឯកសារនេះ តើត្រូវដាក់នៅពេលផ្ញើឯកសារ ឬក៏នៅពេលដែលមានដាក់នៅពេលដែលទទួលទូរលេខ?

**ឆ៖** ខ្ញុំបាទគ្រាន់តែដឹងថាឯកសារវាមកយ៉ាងដូច្នេះតែប៉ុណ្ណោះ។

**ស៖** សូមអរគុណ។ យើងនឹងពិនិត្យឯកសារមួយទៀត ឯកសារនោះគឺមានចំណងជើងថា "ទូរលេខ៥៤" គឺជាឯកសារដែលមានលេខ D175/6.14 ហើយលេខយើងអាចរកបាននៅក្នុង IS21.113 ហើយលេខ ERNជាភាសាបារាំង 00531910, ERNជាភាសាអង់គ្លេស 00296220, ERN ជាភាសាខ្មែរ00017027។

សូមឲ្យក្រឡាបញ្ជីបង្ហាញឯកសារនេះនៅលើអេក្រង់។

សូមឲ្យបញ្ចាំងទាំងពីរភាសាដើម្បីឲ្យយើងអាចយល់បានច្បាស់ ដើម្បីឲ្យដឹងថា ច្បាប់ដើមនៃឯកសារនេះ គឺអត់មានចំណារទេ គឺថាមានតែនៅលើឯកសារថតចម្លងទេបានមានចំណារ។ អ្វីដែលយើងឃើញនៅលើអេក្រង់នេះ គឺជាឯកសារថតចម្លងស្កេននៅក្នុងកុំព្យូទ័រជាពណ៌ វាជាឯកសារចម្លងដែលធ្វើឡើងនៅក្នុងក្របខ័ណ្ឌនៃដីកាចាត់ឲ្យស៊ើបសួរជំនួសរបស់សហចៅក្រមស៊ើបអង្កេត ហើយឯកសារនេះគឺមាននៅក្នុងលេខ IS21.113 ។ សូមបង្ហាញឯកសារនេះនៅលើអេក្រងផងដែរ។

នៅលើឯកសារថ្មីនេះ ដែលជាឯកសារថតចម្លង យើងមើលឃើញនៅខាងលើមានលេខយោងដែលជាលេខដែលចុះដោយ ឌី.ស៊ី.ខេម។ តើលោកអាចបញ្ជាក់ទេថា វាដូចនឹងអ្វីដែលលោកនិយាយកាលពីម្សិលមិញទេ? សូមលោកបញ្ជាក់ពីចំណុចនេះ។

[១០:៥៧:១១]

**ឆ៖** បាទ សូមជម្រាបប្រសាសន៍លោកចៅក្រម នៅក្នុងឯកសារបង្ហាញពីដំបូង គឺជាឯកសារដែលធ្វើការស្កេនចេញពីឯកសារដើម។ ដូច្នេះ ឯកសារនោះមិនមានឃើញលេខសម្គាល់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា នៅទីនោះទេ ប៉ុន្តែឯកសារដែលបង្ហាញក្រោយនេះ គឺជាឯកសារថតចម្លងដែលយើងយកទៅធ្វើការចងក្រង ដាក់លេខសម្គាល់ដើម្បីងាយស្រួលនៅក្នុងការសិក្សាស្រាវជ្រាវ ក្នុងការប្រើប្រាស់ដែលឯកសារថតចម្លងនេះ មានលេខសម្គាល់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា គឺលេខ D02118 នៅពី

ក្រោមលេខនេះគឺយើងបានដាក់នៅក្នុងវង់ក្រចកដាក់ថា "15 បបក" ដែលជាការសម្គាល់ប្រាប់ពីប្រភពដើមរបស់ឯកសារ ដែលងាយស្រួលនៅពេលដែលមានការស្នើសុំទៅ-- ស្នើសុំឯកសារដើមនោះ យើងងាយស្រួលនៅក្នុងការទៅរកឃើញឯកសារនេះភ្លាម នៅក្នុងសំណុំឯកសារដែលមានលេខ15 បបក នេះ។

[១០:៥៨:៣៧]

**ស៖** ដូច្នេះនៅទីនេះ យើងអាចនិយាយបានថា ច្បាប់ដើមដែលលោកកាន់កាប់នោះគឺចេញមកពីបណ្ណសារដ្ឋានរបស់ក្រសួងមហាផ្ទៃ។ គឺបើយើងយោងទៅលើលេខយោងដែលមាននៅក្នុងឯកសារថតចម្លងនេះ តើមែនទេ?

**ឆ៖** ដើម្បីច្បាស់លោកចៅក្រម គឺយើងអាចមើលនៅក្នុងប្រព័ន្ធទិន្នន័យដែលប្រាប់អំពីប្រភពឯកសារមកពីណាច្បាស់លាស់។ សូមអរគុណ។

**ស៖** យើងទៅមើលចំណារដែលសរសេរនៅខាងឆ្វេង នៅខាងលើបង្អស់នៃឯកសារនេះ មានចំណារសរសេរដៃមួយ តើលោកអាចបញ្ជាក់ជូនអង្គជំនុំជម្រះបានទេ សូមឲ្យលោកអានចំណារនេះ។

**ឆ៖** បាទ ខ្ញុំបាទអាចអានបានគឺ មានសរសេរថា "អ៊ំ នួន"។

[១១:០០:០០]

**ស៖** ដូច្នេះ ពាក់ព័ន្ធនឹងចំណារនេះ តើលោកអាចបញ្ជាក់បានទេថា នៅពេលដែលគេប្រគល់ឯកសារច្បាប់ដើម ឬក៏ពេលដែលលោកទទួលហ្នឹង តើមានចំណារនៅលើឯកសារហ្នឹងទេ? ហើយតើលោកអាចបញ្ជាក់បានទេថា ចំណារនេះគឺមិនមានចារដោយខាងបុគ្គលិក ឌី.ស៊ី.ខេម ឬក៏អ្នកណាផ្សេងទៀត ក្រោយពេលទទួលឯកសារនេះ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម នៅក្នុងឯកសារនេះគឺមានចំណាររបស់មជ្ឈមណ្ឌលឯកសារតែម្យ៉ាងគត់ គឺការចុះលេខនេះតែម្តង។ ក្រៅពីនោះគឺជាចំណារដែលមានស្រាប់ជាប់នៅលើឯកសារដើមហ្នឹងតែម្តង។

**ស៖** នៅខាងក្រោមចំណារដែលមានអក្សរថា "អ៊ំ នួន" នោះ នៅខាងក្រោមនោះមានលេខមួយខ្ញុំគិតថា ប្រហែលជាលេខ២៣ តើលោកអាចដឹងទេថា លេខ២៣ហ្នឹងមានន័យថាម៉េចដែរ?

**ឆ៖** លេខនេះគឺជាលេខដែលមានភ្ជាប់មកជាមួយនូវឯកសារដើម ដែលមកពីឯកសារដើមយ៉ាងដូច្នេះតែម្តង។ ដូច្នេះលេខនេះមិនមែនជាលេខដែលមជ្ឈមណ្ឌលឯកសារកម្ពុជាសរសេរទេ។

[១១:០១:៤៥]

**ស៖** ខាងលើ ខាងឆ្វេងដដែល ប្រសិនបើខ្ញុំអានការបកប្រែនោះគឺ ខ្ញុំឃើញគេសរសេរថា ទូរលេខ៥៤ ហើយនៅខាងក្រោមពាក្យនេះ សរសេរថា ២៩០ ខ្ទង់។ តើលោកមានបានអានឃ្លាទាំងពីរបន្ទាត់នេះទេ? លោកឃើញទេ? ហើយលោកអាចបញ្ជាក់បានទេ បើតាមលោកដឹងនោះថា តើព័ត៌មានដែលបញ្ជាក់ថាលេខ ២៩០ នេះ មានន័យថាយ៉ាងម៉េចដែរ?

**លោក ម៉ៃខល ផេសមិន៖**

សូមអភ័យទោស! ថាតើ សូមឲ្យចាក់ឯកសារដែលវាជាឯកសារស្កេនឯកសារដើមដែរឬទេ? ដោយសារតែឯកសារនេះវាពិបាកមើលបន្តិច។

**ប្រធានអង្គជំនុំ៖**

អរគុណ។ មន្ត្រីច្បាប់បញ្ចាំងឯកសារដើមលើអេក្រង់ទូរទស្សន៍!

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** ខ្ញុំគិតថា ភាគីគឺអាចអានឯកសារចម្លងបានងាយស្រួលហើយ មិនមានពិបាកអីទេ។ ពីព្រោះថា ឯកសារស្កេនច្បាប់ដើមនេះដូចជាពិបាកអានជាងឯកសារថតចម្លងទៅទៀត។ ហើយលេខនេះឯកសារនេះគឺមាននៅលេខ 21.113។ អ៊ីចឹងបើបើកមើលឯកសារនេះវិញ គឺវាស្រួលអានជាង។ ប្រសិនបើមិនអាចដាក់ឯកសារនេះនៅលើអេក្រង់បានទេ គឺខ្ញុំគិតថាវាមិនអីទេ។

[១១:០៥:០០]

**ស៖** អ៊ីចឹងគឺថាយើងអាចអានបាន អ្វីដែលថាអានដាច់។ តើលោកអាចបញ្ជាក់ជូនអង្គជំនុំជម្រះបានទេថា តើការចង្អុលបង្ហាញ ព័ត៌មាន២៩០ខ្ទង់នេះមានន័យថាយ៉ាងម៉េចដែរ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម តាមដែលខ្ញុំបាទបានអាន បានធ្វើការសម្គាល់លើឯកសារគឺឲ្យតែ គឺថាឯកសារទូរលេខគឺតែងតែមានលេខភ្ជាប់មកជាមួយយ៉ាងដូច្នេះ ហើយជាលេខដែលដើមរបស់វាមកយ៉ាងដូច្នេះ ហើយខ្ញុំមិនដឹងថា តើ២៩០ខ្ទងហ្នឹងមានន័យយ៉ាងដូចម្ដេច? ខ្ញុំមិនបានដឹងទេ។

**ស៖** នៅខាងលើ ហើយនៅខាងស្ដាំម្ដង គឺមានលេខប្រហែលជា១៧៧ ហើយមានបន្ទាត់ធំមួយនៅលើឯកសារស្កេននោះ គឺយើងឃើញបន្ទាត់មួយពណ៌ក្រហម។ អ៊ីចឹងតើលោកអាចបញ្ជាក់បានទេថា គឺលេខ ហើយនិងបន្ទាត់នេះមិនមានទេនៅពេលដែល-- អំមាននៅពេលដែលគេប្រគល់ជូនឲ្យលោកនោះ ហើយតើវាមានន័យថាយ៉ាងម៉េចដែរ បន្ទាត់ហើយនិងលេខនេះ?

[១១:០៦:៣៨]

**ឆ៖** បើតាមដែលខ្ញុំចាំបាន គឺថាឯកសារនេះមកពី ប្រភពមកពីឯកសារទួលស្លែង ដែលឆ្នូតពណ៌ក្រហម បើសិនជាក្នុងច្បាប់ដើម ខ្ញុំបានឃើញ គឺជាឆ្នូតមួយដែលមាននៅលើឯកសារពីដំបូងមកតែម្តង។ ឯចំណែកលេខ១៧៧ នេះ នៅខាងស្តាំដៃនៅខាងលើ គឺបុគ្គលិករបស់ទួលស្លែងបានចុះលេខនេះ ព្រោះ ឯកសារនេះមកជាសំណុំ ដើម្បីចុះលេខនេះ គឺដើម្បីបង្ហាញអំពីចំនួនទំព័រដែលមានក្នុងឯកសារមួយដុំ។ មិនមែនជាលេខដែលមានមកជាឯកសារដើមរបស់វាទេ។

**ស៖** ឥឡូវនេះ ខ្ញុំចង់ឲ្យយើងពិនិត្យមើលនៅបន្ទាត់ចុងក្រោយនៃឯកសារនេះ។ ប្រសិនបើលោកអាចអានបាន តើលោកអាចអានបានទេនូវអ្វីដែលលោកបានឃើញ ដែលគេសរសេរនេះ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម នៅក្នុងបន្ទាត់ចុងក្រោយនៃឯកសារនៅខាងក្រោមនេះគឺបានសរសេរថា "ចម្លងជូនៈ អ៊ំ, អ៊ំ នួន, អ៊ំ វ៉ាន់, អ៊ំ វន, មន្ទីរឯកសារ"។

[១១:០៨:៥០]

**ស៖** តើលោកអាចកំណត់អត្តសញ្ញាណបុគ្គលដែលមានឈ្មោះនៅក្នុងហ្នឹង ដូចជា នួន, វ៉ាន់, វន ថាតើលោកដឹងទេ ថាតើជាអ្នកណាដែរ?

**ឆ៖** តាមការអាននិងកត់សម្គាល់ឯកសារជាច្រើនមក គឺពាក្យហៅថា "អ៊ំ" ពីខាងមុននេះ គឺសំដៅទៅលើអ្នកដែលមានតួនាទីខ្ពស់ ហើយដែលក្នុងពាក្យថា "អ៊ំ នួន" នេះ គឺខ្ញុំជឿជាក់ថាសំដៅទៅលើអ៊ំ សំដៅទៅលើលោក នួន ជា។

**ស៖** ចុះ អ៊ំ វ៉ាន់ ហើយនិង អ៊ំ វន បើតាមលោកដឹង តើពួកគាត់ទាំងពីរនេះជាអ្នកណាដែរ?

**ឆ៖** ចំពោះអ៊ំ ពាក្យថា "អ៊ំ វ៉ាន់" នេះគឺតាមដែលខ្ញុំកត់សម្គាល់ច្រើនដែរ នៅក្នុងឯកសារគឺសំដៅទៅលើឈ្មោះហៅក្រៅរបស់លោក អៀង សារី ហើយ អ៊ំ វន នេះគឺសំដៅទៅលើ វន វ៉េត។

**ស៖** សូមអរគុណ។ យើងនឹងទៅពិនិត្យមើលឯកសារចុងក្រោយ គឺឯកសារដែលជាទូរលេខ ០៨ គឺឯកសារលេខ D175/6.13 លេខERN ជាភាសាបារាំង 00335196 ទៅដល់ 00335197 ERNជាភាសាអង់គ្លេស 00348086 ទៅដល់ 00348087 ERNជាភាសាខ្មែរ 00021011។

សូមឲ្យខាងក្រឡាបញ្ជីបង្ហាញឯកសារនេះនៅលើអេក្រង់។ បាទ ហើយយើងអាចប្រគល់ឯកសារក្រដាសជូនសាក្សីផងដែរ។

[១១:១២:៥១]

*(មន្ត្រីតុលាការយកឯកសារជូនសាក្សី)*

**ស៖** នៅខាងលើ ខាងស្តាំយើងឃើញមានលេខ១៧៥ តើដូចឯកសារមុនដែរទេ ថាលេខនេះគឺជាចំណារដែលធ្វើឡើងដោយ ឌី.ស៊ី.ខេម ដើម្បីកំណត់អត្តសញ្ញាណនៃឯកសារនេះក្នុងចំណោមឯកសារផ្សេងៗទៀតដែលសំខាន់នោះ?

**ឆ៖** តាមការពិនិត្យគឺឯកសារនេះ ជាឯកសារដែលស្កេនចេញពីឯកសារដើម។ ដូច្នេះមិនមានឃើញលេខឯកសារចុះសម្គាល់លេខឯកសារដោយមជ្ឈមណ្ឌលឯកសារទេ។

**ស៖** លេខ១៧៥ ដែលយើងឃើញខាងលើខាងស្តាំនៅក្នុងឯកសារនេះ ថាតើជាការចុះដោយខាងបុគ្គលិក ឌី.ស៊ី.ខេម ឬក៏មិនមែន? ខាងលើខាងស្តាំ។

**ឆ៖** លេខខាងលើខាងស្តាំមានលេខ១៧៥ នេះ មិនមែនជាលេខដែលដើមមាននៅលើឯកសារដើមទេ គឺជាការចុះលេខដែលសម្គាល់ចំនួនទំព័រដែលមាននៅក្នុងមួយសំណុំនៃឯកសារដើម។

**ស៖** យើងមើលទៅលើឯកសារនេះដដែល។ នៅខាងលើខាងឆ្វេងយើងឃើញអក្សរសរសេរដៃ។ អ៊ីចឹងសូមមើលនៅលើអេក្រង់នេះ តើលោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេ ថាលោកបានឃើញអក្សរអ្វីដែរនៅខាងលើខាងឆ្វេង?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម នៅខាងលើខាងឆ្វេងដៃនៃឯកសារនោះ គឺមានសរសេរថា បង វ៉ាន់ ហើយគូសបន្ទាត់ពីក្រោមបន្តិច។

[១១:១៥:០៥]

**ស៖** សំណួរដដែលដូចអម្បាញ់មិញនេះ គឺពាក់ព័ន្ធនឹងលេខ២១ ថាតើលេខ២០ នេះមាននៅលើឯកសារដើមដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម គឺលេខ២១នេះ មាននៅលើឯកសារដើមរបស់វាផ្ទាល់តែម្តង។

**ស៖** ឥឡូវខ្ញុំចង់ឲ្យយើងពិនិត្យមើលខាងក្រោមម្តង។ តើលោកអាចអានបានទេនៅផ្នែកខាងក្រោមនៃឯកសារនោះ គឺជាចំណារសរសេរដៃនៅខាងក្រោម?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម នៅចំណារនៅខាងក្រោមនេះសរសេរថា៖ “ទទួលថ្ងៃ ២១/៤/ ៧៨ ម៉ោងដប់ប្រាំ ដប់ប្រាំនាទី។ ចម្លងជូន: អ៊ំ, អ៊ំ នួន, អ៊ំ វ៉ាន់។ នៅពីក្រោមឈ្មោះ អ៊ំ វ៉ាន់ មានគូសបន្ទាត់ អ៊ំ វន មន្ទីរឯកសារ”។

[១១:១៦:៤៣]

**សៈ** ជាថ្មីម្តងទៀត តើលោកអាចបញ្ជាក់ ឬក៏ជម្រាបអង្គជំនុំជម្រះបានទេថា ចំណារនេះគឺមាននៅលើឯកសារដើមនៅពេលដែលគេប្រគល់ជូនទៅលោក ហើយបានរក្សាទុកនៅក្នុងបណ្ណសាររបស់ ឌី.ស៊ី.ខេម នោះ?

**ឆៈ** ជម្រាបប្រសាសន៍ចៅក្រម គឺជាចំណារដែលមាននៅជាប់ជាមួយនឹងឯកសារដើម របស់វាមកយ៉ាងដូច្នេះតែម្តង។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

លោក វ៉ាន់ ពៅដារ៉ា សូមអរគុណ ដែលបានផ្តល់ជូននូវព័ត៌មានជូនអង្គជំនុំជម្រះ។ ហើយខ្ញុំមិនមានសំណួរអី ដែលត្រូវចោទសួរទៀតទេលោកប្រធាន។

[១១:១៧:៣៣]

**ប្រធានអង្គជំនុំ៖**

បាទអរគុណលោកចៅក្រម។ ជាកិច្ចបន្តអង្គជំនុំជម្រះសូមវេទិកាទៅមេធាវីការពារក្តី ដើម្បីមានឱកាសនៅក្នុងការតាំងសំណួរចំពោះសាក្សីរូបនេះ។ ជាដំបូងនេះ សូមប្រគល់វេទិកាទៅក្រុមមេធាវីការពារក្តីលោក នួន ជា។

សូមអញ្ជើញ!

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក សុន អរុណ៖**

សូមគោរពតុលាការ សូមគោរពលោកប្រធាន។ ខ្ញុំមានសំណួរប្រហែលជាជាងដប់ ប្រហែលជាប្រើប្រហែលជា២០មីនុតប៉ុណ្ណឹងទេ។

**សៈ** ចំពោះឯកសារដែល ឌី.ស៊ី.ខេម បានផ្តល់ដល់តុលាការនោះ តាំងពីមានទំនាក់ទំនងជាមួយតុលាការ អ.វ.ត.ក នោះ បានផ្តល់មកតុលាការប្រមាណហើយ? សូមលោកជម្រាបតុលាការ បើសិនជាអាចនិយាយបាន។

**លោក វ៉ាន់ថាន់ ដារ៉ាពៅ៖**

**ឆៈ** ខ្ញុំអាចជម្រាបជូនលោកមេធាវីបានថា ចំនួនឯកសារដែលផ្តល់ជូនមកអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ជារួមហ្នឹង គឺមានចំនួនអាចក្នុងចំនួនប្រហាក់ប្រហែល៥សែនទំព័រ។ ហើយលោក--សូមបន្ថែមបន្តិច-- ហើយលោកមេធាវីអាចរកបានចំនួនពិតប្រាកដ នៅក្នុងលិខិតដែលទទួល និង

ប្រគល់ឯកសារជូនមកដល់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ជាពិសេសទៅគ្រប់ភាគី នៅក្នុងគ្រប់ការិយាល័យ នៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

[១១:១៩:២៨]

**ស៖** អរគុណ។ ចំពោះ ឌី.ស៊ី.ខេម មុននឹងផ្ដល់ឯកសារមកតុលាការ អ.វ.ត.ក តើ ឌី.ស៊ី.ខេម មានធ្វើជាកិច្ចសន្យា ឬលិខិតអ្វីជាយថាភូតជាមួយ អ.វ.ត.ក មុនដំបូងទេ? មុននឹងបានផ្ដល់អីមកមានធ្វើកិច្ចសន្យាអ្វីជាមួយគ្នាទេ?

**ឆ៖** មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតជាអនុស្សរណៈមួយដែល-- នៅក្នុងការផ្ដល់ការឯកសារនេះ។ ប៉ុន្តែអនុស្សរណៈនេះមិនទាន់បានទាន់សម្រេចជាការចុះហត្ថលេខារវាងអង្គជំនុំជម្រះ និងមជ្ឈមណ្ឌលឯកសារកម្ពុជាទេ។ ហើយសំណុំនៃឯកសារអនុស្សរណៈនេះ អាចមាននៅមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយប្រសិនជាលោកមេធាវីត្រូវការយើងអាចផ្ដល់ជូនបានភ្លាម។

**ស៖** លោកមិនយល់ថា បើការណាមិនមានកិច្ចសន្យា ឬក៏អនុស្សរណៈអីជាមួយគ្នា ហើយលោកផ្ដល់ឯកសារមកតុលាការ លោកអត់យល់ថានេះជាការខុសច្បាប់ ឬក៏ត្រូវច្បាប់ទេ។

**ឆ៖** បាទលោកមេធាវី ខ្ញុំបានបញ្ជាក់នៅក្នុងអង្គសវនាការនេះយ៉ាងច្បាស់ថា រាល់ឯកសារដែលផ្ដល់ជូនមកអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺផ្ដល់តាមការស្នើសុំរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ ជាពិសេស ខ្ញុំឲ្យឧទាហរណ៍ឲ្យបានច្បាស់លាស់ គឺសម្រាប់ការិយាល័យសហព្រះរាជអាជ្ញា គឺយើងបានទទួលនូវសំណើនូវការស្នើសុំនូវឯកសារនេះ ហើយយើងបានផ្ដល់ឯកសារទៅតាមការស្នើសុំឯកសារនេះគ្រប់ចំនួនទៅតាមការស្នើសុំ។

[១១:២១:២៧]

**ស៖** អរគុណ។ ចម្លើយរបស់លោកនៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៩ ដែលមានលេខឯកសារ D204/4 លោកបានឆ្លើយប្រាប់ទៅចៅក្រមស៊ើបអង្កេតថា ឌី.ស៊ី.ខេម បានទទួលឯកសារមួយចំនួន ពីសម្ដេច ហ៊ុន សែន ចំនួន ៤៨ឯកសារ មានចំនួន ៨៥៤ទំព័រនោះ តើទទួលនៅពេលណា? តើឯកសារនោះជាឯកសារអ្វីខ្លះ? លោកអាចជម្រាបតុលាការបានទេ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី-- អ្ហឺ! លោកសហព្រះរាជអាជ្ញាអន្តរជាតិ។

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន ខ្ញុំសូមអធ្យាស្រ័យសូមរំខានបន្តិចដោយសារមេធាវីការពារក្តីយោងទៅលើចម្លើយរបស់ម្នាក់ហ្នឹង គឺឯកសារ D204/4 សេចក្តីចម្លើយនេះប្រហែលអាចនឹងមិនមានការជាប់ពាក់ព័ន្ធដោយមិនត្រូវបង្ហាញឈ្មោះសាក្សីនោះទេ។ សូមអរគុណលោកប្រធាន។

[១១:២៣:៥១]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:២៣:៤៧]

**ប្រធានអង្គជំនុំ៖**

លោកមេធាវីបញ្ជាក់ម្តងទៀតមើល ឯកសារ D204/4 ហ្នឹងជាចម្លើយដោយឆ្លើយនៅចំពោះមុខអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតហ្នឹងជាចម្លើយរបស់សាក្សីរូបនេះ ឬក៏ជាចម្លើយសាក្សីអ្នកឈ្មោះផ្សេងដែលលោកសំអាង ហើយយកមកដេញដោលចំពោះសាក្សីរូបនេះ។

**លោក សុន អរុណ៖**

ខ្ញុំសូមបញ្ជាក់ជម្រាបតុលាការថា សំណួរនេះដោយខ្ញុំយល់ឃើញថា លោក ដារ៉ា មកថ្ងៃនេះដោយតាមរយៈដីកាកោះ ក្នុងនាមជាតំណាង ឌី.ស៊ី.ខេម ចម្លើយនេះជាចម្លើយរបស់លោក ឆាំង យុ។ ប៉ុន្តែខ្ញុំយល់ថា តំណាងរបស់លោក ឆាំង យុ គឺលោក ដារ៉ា។ ហើយបើសិនជាតុលាការមិនអនុញ្ញាតឲ្យខ្ញុំនឹងសួរទេ ខ្ញុំសូមលុបសំណួរហ្នឹងមួយចោល។

[១១:២៤:៥៦]

**ប្រធានអង្គជំនុំ៖**

បាទ ដោយការយោងទៅឯកសារនេះ គឺមិនមែនជាការយោងនូវឯកសារកំណត់ហេតុសួរសាក្សីរូបនេះទេ។ ហេតុដូច្នេះ ការដែលផ្អែកលើឯកសារអ្នកដទៃនោះ គឺគប្បីសួរសាក្សីរូបណាដែលឆ្លើយពាក់ព័ន្ធព្រោះយើងយកចម្លើយពីមុនយកមកសួរដេញដោលសម្រាប់សាក្សី។ អ៊ីចឹងសំណួរនេះ គឺមិនឲ្យសួរទេ អាចសួរសំណួរផ្សេងទៀត។

**លោក សុន អរុណ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក សុន អរុណ៖**

**ស៖** បើតាមចម្លើយរបស់លោកប្រាប់ទៅចៅក្រមស៊ើបអង្កេតថា ពាក្យសារភាពនៅទួលស្លែងទាំងអស់ បើតាមរកឃើញ គឺរើសបាននៅរប៉ាត់រប៉ាយពេញកន្លែងទួលស្លែង និងឯកសារចម្លើយសារភាពចំនួន៨៣១ ដែលយកមកពីផ្ទះ សុន សេន។ ខ្ញុំសុំ--

**ប្រធានអង្គជំនុំ៖**

ឈប់ៗ សូមអញ្ជើញព្រះរាជអាជ្ញាម៉េចទៅ សហព្រះរាជអាជ្ញា!

[១១:២៦:៣៥]

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន ខ្ញុំគិតថាប្រហែល នេះគឺពាក់ព័ន្ធទៅសាក្សីមួយផ្សេងទៀតហើយ។ ចម្លើយដែលយើងដឹងដែលសាក្សីនេះបានផ្តល់នេះ គឺមាននៅក្នុងD77/6 ហើយឯកសារ D77/6នេះ គឺមិនមានយោងទៅលើឯកសារ ៨៣១នេះទេ គឺៗជា មិនមែនឯកសារ មិនមែនជាចម្លើយរបស់សាក្សីរូបនេះ គឺសាក្សីផ្សេងទៅវិញទេ។

**សួរដោយលោក សុន អរុណ៖**

ខ្ញុំសូមរំលងសំណួរនេះទៀត សុំទោស ដោយសារខ្ញុំមើលឯកសារទៅច្រឡំ ពីព្រោះអីឯកសារហ្នឹងដាក់ជាមួយគ្នា។ ខ្ញុំសូមរំលងទៅសំណួរមួយផ្សេងទៀត។

**ស៖** សូមលោក ដារ៉ា បញ្ជាក់ម្តងទៀត ព្រឹកមិញលោកបានបញ្ជាក់ម្តងហើយថា ឯកសារទង់បដិវត្តមានភាព-- ខ្ញុំសួរថាឯកសារទង់បដិវត្តនោះមានភាពបែបណាទាំងទ្រង់ទ្រាយ ទាំងទំហំ ទាំងលក្ខណៈទូទៅរបស់ឯកសារទង់បដិវត្តនោះ?

**ឆ៖** ខ្ញុំសូមជម្រាបតាមការយល់ដឹងរបស់ខ្ញុំ តាមការបានឃើញ បានទទួលឯកសារទង់បដិវត្តនេះ ដោយរូបខ្ញុំផ្ទាល់ដែរ គឺទង់បដិវត្តនេះមានជាសៀវភៅ បាទ ជាសៀវភៅ ហើយមានកិបជាសៀវភៅ ហើយមានក្របខាងក្រៅមានពណ៌រាងរលោងដែលខុសពីក្រដាសសន្លឹកនៅខាងក្នុង ហើយមានទង់រូបទង់ គឺទង់ពណ៌ក្រហម។

**ស៖** មានយ៉ាងម៉េចទៀត សូមលោកបញ្ជាក់បន្ថែមបន្តិចទៀតមក?

**ឆ៖** ខ្ញុំបានឮការសួរអំពីទំហំ ខ្ញុំមិនបានមានការវាស់វែងពីទំហំថា តើទស្សនាវដ្តីទង់បដិវត្តហ្នឹងមានទទឹងប៉ុន្មាន មានបណ្តោយប៉ុន្មាន មានកម្រាស់ប៉ុន្មានទេ។

**ស៖** លោកបានអានទង់បដិវត្តនោះទេ?

**ឆ៖** ខ្ញុំបានអានទង់បដិវត្តនេះមួយចំនួន។

**ស៖** ទង់បដិវត្តហ្នឹងសរសេរជាអក្សរដៃ ឬក៏សរសេរ ឬវ៉ៃ*ដាក់ទីឡូ*?

**ឆ៖** ទង់បដិវត្តដែលខ្ញុំបានអាន គឺមិនមែនជាៗការសរសេរដោយដៃទេ តាមពុម្ពអក្សរនោះ ហើយប៉ុន្តែពុម្ពអក្សរនោះ ក៏មិនមែនជាពុម្ពអក្សរដូចជាការវាយអង្គុលេខពេលបច្ចុប្បន្នយើងនេះទេ មានលក្ខណៈខុសគ្នា។

**ស៖** លោកបានបញ្ជាក់ថា ពីថ្ងៃមុនបញ្ជាក់ថាទង់នៅហ្នឹង មានដាក់ទង់ប្រាំមិនអីចឹង? នៅលើសៀវភៅ ក្របសៀវភៅ?

**ឆ៖** នៅពេលដែលលោកចៅក្រមបង្ហាញពីទង់នេះ គឺទង់នេះខ្ញុំបានឃើញមានប្រាំ។

**ស៖** ពណ៌អី ដើមបំផុតនោះ ដែលលោកថាមានដើមនោះ? អាដើមបំផុតនោះពណ៌អី?

**ឆ៖** គឺពណ៌ក្រហម។

[១១:៣០:០៥]

**ស៖** ទង់ហ្នឹងពណ៌ក្រហម។ បើតាមការចងចាំរបស់លោក នួន ជា លោក នួន ជាឥឡូវគាត់នៅហ្នឹងដែរ គាត់បាននិយាយប្រាប់ថា ហើយជម្រាបអង្គតុលាការទៀត ហើយបានជម្រាបទៅខាងសហព្រះរាជអាជ្ញាទៀតថា ទង់នោះទង់នោះសរសេរដោយដៃ ដៃគាត់ជាមួយដៃ ប៉ុល ពត ហើយសរសេរហ្នឹងបានសរសេរហើយ បានឱ្យមានអ្នកចម្លង អ្នកចម្លងនោះគឺមនុស្សម្នាក់ដែលគាត់ទុកចិត្ត ហើយបានយកទៅទាញដៃ កាលសម័យហ្នឹងគ្មាន*ដាក់ទីឡូ* វ៉ៃទេ យកទៅទាញរបៀបបុរាណ ទាញមកចេញជាអក្សរដៃដដែល។ រហូតមកដល់នេះ ថ្ងៃនេះ ខ្ញុំចង់សួរបញ្ជាក់ថា លោកបានឃើញសភាពទូទៅនៃទង់បដិវត្តហ្នឹងវាខុសគ្នានឹងលោក នួន ជា បញ្ជាក់ទេ? បើតុលាការអនុញ្ញាត ខ្ញុំសូមឱ្យលោក នួន ជា បញ្ជាក់នៅពេលនេះម្តងទៀត ដើម្បីឱ្យសាក្សីហ្នឹងច្បាស់ ពីរឿងទង់ដែលគាត់បានធ្វើដោយខ្លួនឯង។

[១១:៣១:៣៤]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះមិនអនុញ្ញាតតាមសំណើសុំនេះទេ។ អង្គជម្រះអនុញ្ញាតឱ្យលោកអាចសួរដេញដោលចំពោះសាក្សីរូបនេះបាន ពាក់ព័ន្ធទៅនឹងទង់បដិវត្ត បើតាមប្រតិចារឹក និងកិច្ចដំណើរការសវនាការកន្លងមកទង់បដិវត្តត្រូវបែងចែកចេញជាពីរដំណាក់កាលខុសគ្នា។ ដំណាក់កាលទស្សនាវដ្តីបដិវត្តក្នុងអំឡុងទសវត្សរ៍

ឆ្នាំ៦០នៅសម្ងាត់ នោះហើយតែទំនងជាលោកមេធាវីបានអះអាងអម្បាញ់មិញ។ ចំណែកឯ ទង់បដិវត្ត ដែលបោះពុម្ពផ្សាយនៅក្នុងចន្លោះឆ្នាំ៧៥, ឆ្នាំ៧៨ ទំនងជាមានលក្ខណៈដោយឡែកដោយមានការប្រមូល នូវអ្នកដែលចេះធ្វើការបោះពុម្ពផ្សាយ មានការយឹតយ៉ាវបន្តិច។ អ៊ីចឹងហើយបានជាចន្លោះពីខែមេសា ៧៥ រហូតដល់ខែ៨/៧៥ ទើបមានការបោះពុម្ពផ្សាយទង់បដិវត្តដោយសារបញ្ហាកង្វះខាតអ្នកមានសមត្ថភាពចំណេះដឹងខាងបោះពុម្ពផ្សាយ។ អ៊ីចឹងអាចមានការភ័ន្តច្រឡំ ឬក៏ក្នុងការសួរត្រូវតែបែងឲ្យច្បាស់លាស់រវាងដំណាក់កាលពីរនេះទើបជាក់ច្បាស់ ហើយការសួរដេញដោលគឺពាក់ព័ន្ធជាមួយនឹងឯកសារដែលដាក់ចំពោះមុខអង្គជម្រះដែលកំពុងតែមានបញ្ហានេះ ហើយផលប្រយោជន៍យ៉ាងម៉េចនោះគឺអាស្រ័យទៅលើភាគី ហើយនិងអង្គជម្រះនឹងពិចារណាសម្រេចទៅតាមសត្យានុម័តនៃភស្តុតាងនៅចំពោះមុខខ្លួន។

[១១:៣៣:១២]

**លោក សុន អរុណ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក សុន អរុណ៖**

**ស៖** ខ្ញុំសូមរំលងពីរឿងទង់បដិវត្ត។ ខ្ញុំសូមលោក ដាវ៉ា បន្តទៅទៀត។ លោកអាចបង្ហាញមកមេធាវីការពារ និងលោក នួន ជា ដែលអង្គុយទីនេះឲ្យបានឃើញជាក់នឹងភ្នែក ដើម្បីផ្ទៀងផ្ទាត់ដែលមានឯកសារថតចម្លងនៅតុលាការ អ.វ.ត.ក នេះ តាមរយៈតុលាការសាលាដំបូង ដែលកំពុងសវនាការនេះ បានឬទេ ដើម្បីជម្រះនូវការមន្ទិលសង្ស័យពីលោក នួន ជា នោះតទៅទៀត បើសិនជាអាចធ្វើបានអំពីអត់បដិវត្ត បើសិនជាលោកមានសំណៅដើម?

**ឆ៖** សូមលោកមេធាវី ធ្វើការស្នើសុំតាម-- មានសំណើស្នើសុំមជ្ឈមណ្ឌលឯកសារកម្ពុជានឹងបញ្ជូនឯកសារណាដែលលោកមេធាវីធ្វើការស្នើសុំបាន។

**ស៖** សូមអរគុណណាស់។ សូមសួរសំណួរបន្តទៅទៀត តើលោកបានទទួលឯកសារពីបុគ្គលលោកមានប្រសាសន៍ពីព្រឹកមិញថា លោកទទួលឯកសារពីច្រើនប្រភពណាស់ ប៉ុន្តែចំពោះទទួលឯកសារពីបុគ្គលផ្ទាល់ ភាគច្រើនជាឯកសារប្រភេទអ្វី?

[១១:៣៥:០៥]

**ឆ៖** ខ្ញុំសូមបញ្ជាក់ជូនឲ្យបានច្បាស់ទៅលោកមេធាវី ក៏ដូចអង្គសវនាការជ្រាបថា ឯកសារដែលទទួលបាននេះ គឺមានបុគ្គលិកជាច្រើនចូលរួមទទួលឯកសារនេះដែរ។ រាល់ការទទួលបានឯកសារ

ត្រូវបានប្រគល់មកដល់ដៃរបស់ខ្ញុំដើម្បីធ្វើការចុះលេខនិងកត់ត្រាទុក។ ហើយការដែលប្រគល់ ទទួលបានឯកសារពីបុគ្គលនេះ គឺមានជាឯកសារជាក្រដាស ជាសន្លឹក ហើយមានឯកសារជារូបថត ហើយមានឯកសារជាខ្សែភាពយន្តឯកសារផងដែរ។

**ស៖** ចុះចំពោះឯកសារទាំងនោះ ពេលដែលលោកទទួលបានពីបុគ្គល តើលោកបានសួរថាតើឯកសារហ្នឹងមកពីណា? អ្នកហ្នឹង-- អ្នកប្រគល់ជូនលោកហ្នឹងបានមកពីណា? បានដោយរបៀបណា? ហើយនិងនិយាយអំពីអ្វីៗខ្លះទេ? បានសួរទៅបុគ្គលដែលប្រគល់ឲ្យជូនលោកនោះទេ?

**ឆ៖** បាទគឺ នៅក្នុងបញ្ហាទទួលឯកសារនេះ គឺយើងបានធ្វើយថាភាពឯកសារ គឺដោយតាមរយៈការសួរនាំ ដូចលោកមេធាវីបានសួរនេះតែម្តង។

**ស៖** សូមលោកបញ្ជាក់ម្តងទៀតពីរឿងហ្វីលកុន ឬក៏រូបថត។ ចំពោះរូបថតដែលលោកបានទទួលពីបុគ្គលក្តី ពីក្រុមណាក្តី រូបថតសុទ្ធតែជារូបថតសខ្មៅ ឬក៏មានពណ៌?

[១១:៣៦:៥៦]

**ឆ៖** ជាទូទៅ គឺរូបថតមានលក្ខណៈជាពណ៌ស-ខ្មៅ។

**ស៖** ចុះចំពោះលោកដូចមានប្រសាសន៍ដែរ ក៏មិនដឹង ហើយក៏ខ្ញុំភ្លេច បើសិនភ្លេច បំភ្លេចចោល។ មានបានជាកុន ជាហ្វីលកុន អាហ្នឹងវាពណ៌ ឬស-ខ្មៅដែរ?

**ឆ៖** កុនគឺជាមាន-- បាទ សូមបញ្ជាក់ត្រង់ចំណុចនេះឲ្យបានច្បាស់លាស់ បញ្ជាក់ជូនទៅលោកមេធាវី ក៏ដូចជាអង្គជំនុំជម្រះ អង្គសវនាការទាំងមូលដែរ ឲ្យបានជ្រាបច្បាស់ថា កុននេះគឺមាន-- កុនឯកសារនេះ គឺមានពីរយ៉ាង។ គឺទីមួយ កុនឯកសារដែលផលិតដោយកម្ពុជាប្រជាធិបតេយ្យខ្លួនឯងនេះផ្ទាល់តែម្តង។ ហើយនិងកុនប្រភេទមួយទៀត គឺកុនឯកសារដែលផលិតក្រោយរបបកម្ពុជាប្រជាធិបតេយ្យដែលជាការផលិតជាកុនឯកសារ។

**ស៖** សំណួរបន្តទៅទៀត។ ហេតុអ្វីបានជាលោកយកសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិប-តេយ្យដែលសរសេរដោយ ឌី.ស៊ី.ខេម យកទៅបង្រៀននៅពេល-- នៅសាលាប្រទេសកម្ពុជាយើងនេះនៅពេលនេះ លោកជឿជាក់ថាប្រវត្តិសាស្ត្រនេះត្រឹមត្រូវទេ? ប្រវត្តិសាស្ត្រដែលកំពុងកាត់សេចក្តីនេះសព្វថ្ងៃនេះត្រឹមត្រូវទេ? បើសាលាក្តីនេះ មិនទាន់បានសម្រេច ហើយចេញសាលក្រមសម្រេចជាស្ថាពរផង ថាកម្ពុជាប្រជាធិបតេយ្យជាក្រុមអ្នកខុស ជាក្រុមអ្នកដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មក្នុងរវាងបីឆ្នាំប្រាំបីខែម្ភៃថ្ងៃនេះ។

[១១:៣៨:៥៦]

**ឆ៖** ខ្ញុំសូមមេត្តាឲ្យលោកមេធាវីពិនិត្យពិចារណាម្តងទៀត អំពីកាលដែលអង្គជំនុំជម្រះបានកោះហៅខ្ញុំឲ្យមកឆ្លើយបំភ្លឺនៅចំពោះមុខអង្គជំនុំជម្រះ។ គឺសម្តីរបស់លោកប្រធានចៅក្រម បានបញ្ជាក់ថាឲ្យខ្ញុំមកធ្វើការបង្ហាញ ការសក្ខីកម្មអំពីឯកសារ។

**ស៖** សូមអរគុណ។ ពេលដែលលោកនិងអ្នកដទៃផ្សេងទៀត បានដើរប្រមូលឯកសារមានពេញភ្នំពេញ មានន័យថា នៅស-២១ នៅក្រសួងមហាផ្ទៃ នៅក្រសួងវប្បធម៌ នៅក្រសួងណាៗអ៊ីចឹងទៅ។ ពេញទូទាំងភ្នំពេញ និងមាននៅតាមខេត្តដទៃផ្សេងទៀត។ លោកយល់ លោកថា-- ទាំងអស់នេះ លោកចោទ-- ខ្ញុំមិនប្រើពាក្យចោទទេ។ លោកយល់ថាជាឯកសាររបស់កម្ពុជាប្រជាធិបតេយ្យ ឬក៏ឯកសារទាំងនោះរបស់កម្ពុជាប្រជាធិបតេយ្យមែន ឬក៏ឯកសារខ្លះបានប្រឌិតឡើងដោយអ្នកបុគ្គលណា ឬដោយក្រុមណាមួយ?

[១១:៤០:៤០]

**ឆ៖** ចំពោះការធ្វើកំណត់សម្គាល់ ថាតើឯកសារមួយជាឯកសារដែលជាឯកសារដើម ឬក៏ជាឯកសាររបស់របបកម្ពុជាប្រជាធិបតេយ្យនោះ គឺយើងធ្វើការអានផ្ទាល់ទៅលើឯកសារនេះតែម្តង នៅពេលដែលយើងទទួលបាន ដើម្បីឲ្យដឹងថាតើឯកសារដែលយើងទទួលបាននេះគឺឯកសារនេះមានខ្លឹមសារយ៉ាងម៉េច មានប្រើភាសាយ៉ាងម៉េច មានការចុះកាលបរិច្ឆេទយ៉ាងម៉េច ដើម្បីឲ្យដឹងថាតើឯកសារនេះគឺជាឯកសារដែលបន្សល់ទុកដោយរបបកម្ពុជាប្រជាធិបតេយ្យ ឬក៏ជាឯកសារយ៉ាងម៉េច។

ខ្ញុំឲ្យឧទាហរណ៍មួយ។ បើសិនជាឯកសារដែលចុះក្រោយឆ្នាំ១៩៧៩ នោះយើងដឹងភ្លាមថាឯកសារនោះពិតជាមិនមែនជាឯកសាររបស់របបកម្ពុជាប្រជាធិបតេយ្យដែលមានរយៈកាលឆ្នាំ៧៥-៧៩ទេបាទ។

**ស៖** ខ្ញុំចង់បញ្ជាក់ត្រង់នេះ ខ្ញុំចង់បញ្ជាក់ថា ពេលដែលលោកបានទទួលឯកសារទាំងអស់ហ្នឹងហើយ លោកសន្មត មិនដឹងប៉ុន្មានភាគរយទេ សន្មតថាឯកសារនេះជាឯកសារសំណល់ពីកម្ពុជាប្រជាធិបតេយ្យ។ ខ្ញុំសួរទៅវិញថា ឯកសារនេះលោកអាចយល់បានថា វាអាចទៅជាបុគ្គល ឬក្រុមណាមួយផលិត ប្រឌិតឯកសារហ្នឹងឲ្យទៅជាដូចជាឯកសាររបស់កម្ពុជាប្រជាធិបតេយ្យធ្វើឬទេ?

**ឆ៖** សូមលោកមេធាវីមេត្តាសម្រួលសំណួរនេះឲ្យបានមានលក្ខណៈងាយស្រួលយល់បន្តិច ដើម្បីឲ្យខ្ញុំបានឆ្លើយទៅឲ្យបានច្បាស់ កុំឲ្យលោកមេធាវីមានការសង្ស័យឬមន្ទិលយ៉ាងណានោះ។ សូមអរគុណ។

**ស៖** សូមអរគុណ ខ្ញុំសូមសួរឡើងវិញ។ ពេលដែល ឌី.ស៊ី.ខេម បានប្រមូលឯកសារជាបន្តបន្ទាប់ ក្នុងរយៈពេលយូរ ហើយឃើញឯកសារទាំងអស់ ឌី.ស៊ី.ខេម បានសន្និដ្ឋានថាជាឯកសាររបស់កម្ពុជាប្រជាធិបតេយ្យ ដោយបានពិនិត្យពិច័យពិចារណាច្បាស់លាស់។ ប៉ុន្តែលោកអាចយល់ថា ឯកសារមួយចំនួនៗជាឯកសារប្រឌិតដោយបុគ្គល ឬដោយក្រុមណាបានទេ?

**ឆ៖** ខ្ញុំនៅចងចាំបានថា ខ្ញុំបាននិយាយអំពីឯកសារមួយដែលយើងជឿជាក់ថាមិនមែនជាឯកសាររបស់របបកម្ពុជាប្រជាធិបតេយ្យនោះ កាលពីម្សិលមិញ គឺទាក់ទងទៅនឹងឯកសារមួយដែលវាទាក់ទងទៅនឹងការសម្លាប់ជនជាតិបរទេសនៅក្នុងឆ្នាំ១៩៨៤។

[១១:៤៣:៣៨]

**ស៖** អរគុណណាស់។ លោកឆ្លើយជាមួយនឹងសហព្រះរាជអាជ្ញាពីម្សិលមិញ ពីថ្ងៃ២៣ ខែ១ ឆ្នាំ២០១២ ថា ឌី.ស៊ី.ខេម ដឹងថា ឯកសារជាច្រើនមានប្រភេទខុសៗគ្នានៅស-២១ តើលោកដឹងដោយសារអ្វី? នរណាប្រាប់ ឌី.ស៊ី.ខេម?

**ឆ៖** គឺដឹងតាមរយៈការចុះទៅប្រមូល និងចងក្រងឯកសារនេះតែម្តង គឺយើងបានឃើញផ្ទាល់ភ្នែក បើសិនជាឯកសារមានប្រភេទខុសៗគ្នា យើងដឹងថាឯកសារមានប្រភេទខុសៗគ្នា។ ឧទាហរណ៍ច្បាស់ក្រឡែត គឺថា ទង់បដិវត្តខុសពីឯកសារចម្លើយសារភាព។

[១១:៤៤:២៧]

**ស៖** ខ្ញុំបន្តសំណួរនេះ ខ្ញុំចង់ដឹងថា ដែលលោកបានទៅដឹងថានៅ ឌី.ស៊ី.ខេម មានឯកសារច្រើនហើយខុសៗគ្នា។ ពីព្រោះបើតាមខ្ញុំយល់ ហើយខ្ញុំឮ ហើយតាមខ្ញុំដឹងតាមឯកសារផ្សេងៗ តាមការស្រាវជ្រាវ ប្រទេសកុម្មុយនីស្ត ជាប្រទេសតឹងរ៉ឹង ជាប្រទេសដែលធ្វើការយ៉ាងម៉ឹងម៉ាត់ តឹងរ៉ឹងបំផុត ហើយនៅក្នុង ឌី.ស៊ី.ខេម អ្ហ៎! នៅក្នុងស-២១ ទួលស្លែង ជាក្រុមមួយតូច។ អ្នកហ្នឹងត្រូវតែធ្វើការសម្រាប់តែខ្លួនឯងទេ ដឹងតែខ្លួនឯងទេ ដូច ឌុច អ៊ីចឹង មិនអាចដឹងដល់ថ្នាក់មជ្ឈិមទេ។ អាហ្នឹងបើតាមការស្រាវជ្រាវរបស់ខ្ញុំមក។ ប៉ុន្តែហេតុអីបានជានៅ ឌី.ស៊ី.ខេម មានឯកសាររហូតដល់ប្រជុំអចិន្ត្រៃយ៍ ដែល ឌី.ស៊ី.ខេម បានផ្តល់ឲ្យតុលាការ ប្រជុំមជ្ឈិម និងកិច្ចការងារធំៗតទៅទៀត ដែលថ្នាក់លើបានធ្វើ។ លោកមានឆ្លល់ត្រង់ហ្នឹងទេ?

**ឆ៖** សូមមេត្តាសួរឲ្យបានច្បាប់បាទ តើខ្ញុំឆ្ងល់លើបញ្ហាអី? ឬក៏ខ្ញុំត្រូវឆ្លើយទៅលើអ្វីដែលលោកមេធាវីមានការជឿជាក់រួចហើយ ឬក៏យ៉ាងម៉េច? សូមមេត្តាបញ្ជាក់សំណួរឲ្យបានច្បាស់លាស់បន្តិច។

សូមអរគុណ។

**ស៖** ខ្ញុំសូមបញ្ចាក់សាថ្មី។

**ប្រធានអង្គជំនុំ៖**

លោកមេធាវី សូមលោកខិតខំផ្តង់នូវបញ្ញាញាណដើម្បីតាំងសំណួរ មិនមែនលោកផ្តល់វេទិកាឲ្យលោកពន្យល់ទៅសាក្សីនោះទេ។ លោកមានការតាំងសំណួរៗណាដែលពាក់ព័ន្ធទៅនឹងបញ្ហា ទៅនឹងកម្មវត្ថុដែលផ្តល់វេទិកាឲ្យសួរសាក្សី។ សូមរៀបចំនូវការតាំងសំណួរឲ្យបានច្បាស់លាស់។ បញ្ហាទីពីរការសួររបស់មេធាវី មិនគប្បីប្រើប្រាស់នូវការយល់ដឹងផ្ទាល់ខ្លួនទៅសួរដល់សាក្សីទេ គឺផ្អែកទៅលើឯកសារដែលមាន ដែលពាក់ព័ន្ធនៅក្នុងការដេញដោល នៅក្នុងសំណុំរឿងនេះដើម្បីសួរ។ នេះជាកិច្ចដំណើរការនីតិវិធីតាមផ្លូវតុលាការ។

[១១:៤៧:០៣]

**លោក សុន អរុណ៖**

សូមអរគុណលោកប្រធានដែលបានណែនាំ។

**សួរដោយលោក សុន អរុណ៖**

**ស៖** ពីព្រឹកមិញ ព្រះរាជអាជ្ញាបានសួរលោក ប្រហែលជាព្រះរាជអាជ្ញា ឬក៏ដើមបណ្តឹងរដ្ឋប្បវេណី សួរពីរឿងឯកសារដែលមាន-- លោកមានបានដកស្រង់ បានស្រាវជ្រាវរកឯកសារពីហ្វុង ឬហ្គ្រុងទេ? ហើយលោកបានឆ្លើយទៅវិញថា ឌី.ស៊ី.ខេម បានស្រាវជ្រាវ និងបានទទួលឯកសារតែពីឆ្នាំ១៩៧៥ ដល់៧៩ មានន័យថារយៈកាលកម្ពុជាប្រជាធិបតេយ្យ។ ប៉ុន្តែចំពោះ ហ្វុង ហើយនិង ហ្គ្រុង បានបង្កើតឡើងក្នុងឆ្នាំ១៩៧៥ អ៎! សូមទោស ១៩៧០ រហូតបើតាមខ្ញុំចាំ ប៉ុនមិនមានឯកសារអីបញ្ជាក់ច្បាស់លាស់ទេ រហូតដល់ទៅ១៩៧៦ ប្រហែលជាខែមីនា។ មានន័យថា៧៥ មក-- ខែមេសា ៧៥ មកដល់មីនា ៧៦ មានន័យថានៅក្នុងហ្គ្រុងដែរ។ បើអ៊ីចឹងមានន័យថាឯកសារហ្នឹងវាចូលនៅក្នុងកម្ពុជាប្រជាធិបតេយ្យ ឬក៏នៅក្នុងហ្គ្រុង? ហើយលោកថាទេ ពីឆ្នាំ១៩៧៥ មកដល់៧៩ វាជារបស់កម្ពុជាប្រជាធិបតេយ្យ ខ្ញុំថាដូចជាមិនមែនអ៊ីចឹង។ តើលោកអាចឆ្លើយបានថា ក្នុងរយៈពេលមួយឆ្នាំដែលសម្តេចនរោត្តមសីហនុ លោកកាន់ការហ្នឹង មានឯកសារអ្វីទេ? ព្រោះអីខ្ញុំយល់ថាក្នុងរយៈពេលមួយឆ្នាំហ្នឹង គឺនៅក្នុងហ្គ្រុង ហើយហ្គ្រុងហ្នឹង បើលោកឆ្លើយព្រឹកមិញថា៧៥ ដល់៧៩ គឺកម្ពុជាប្រជាធិបតេយ្យ។

**ប្រធានអង្គជំនុំ៖**

លោកមេធាវី អង្គជំនុំជម្រះបានរម្លឹកហើយមិញថា អង្គជំនុំជម្រះផ្តល់វេទិកាទៅលោក មិនឲ្យលោកពន្យល់សាក្សីទេ។ ឲ្យលោកតាំងសំណួរ ដើម្បីសួរសាក្សី ឲ្យសាក្សីឆ្លើយ។ មិនមែនយកវេទិកាហ្នឹងមកសួរ មកពន្យល់សាក្សីទេ។ ហើយសូមលោករៀបចំនូវផ្គង់នូវគំនិតរបស់លោកដើម្បីតាំងសំណួរច្បាស់លាស់ទៅសាក្សី ដើម្បីសាក្សីងាយនៅក្នុងសារសួរ។ ហើយនៅក្នុងការនេះទៀតសោត យើងបានរម្លឹកច្រើនលើកច្រើនសាហើយ។ តាំងសំណួរគប្បីខ្លី ដែលឲ្យច្បាស់លាស់ ហើយនិយាយយឺតៗដើម្បីឲ្យគោលដៅនៃការស្តាប់នូវសំណួរបាន យល់សំណួររបស់លោកបាន ហើយឆ្លើយចំបញ្ហាតែម្តង។ អាចឆ្លើយបាន ឬក៏ឆ្លើយមិនបាន។ នោះគឺជាបញ្ហាគោលដៅនៃការឆ្លើយតបទៅនឹងសំណួរ។

[១១:៥០:០៧]

**លោក សុន អរុណ៖**

អរគុណលោកប្រធានសាជាថ្មី។

**សួរដោយលោក សុន អរុណ៖**

**ស៖** ប៉ុន្តែសំណួរខ្ញុំអំមិញនេះគឺមេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានសួរមួយកំណាត់រួចមកហើយ។ អ៊ួ! ព្រះរាជអាជ្ញា (សូមទោស) បានសួរមួយកំណាត់រួចមកហើយ ខ្ញុំគ្រាន់តែសួរបន្តហ្នឹង បន្តសំណួរហ្នឹងមួយកំណាត់ពី៧៥ មកដល់៧៦ ប៉ុណ្ណឹងទេ ដើម្បីភ្ជាប់សំណួរហ្នឹងតែមួយហើយសួរថា ឯកសារហ្នឹងលោកមានបានទទួលទេ? អាហ្នឹងជាសំណួររបស់ខ្ញុំ។

**ឆ៖** សូមអរគុណលោកមេធាវី។ បើសិនជាលោកមេធាវីបានសួរខ្ញុំ ដោយមានលក្ខណៈច្បាស់លាស់ នោះខ្ញុំអាចឆ្លើយជូនដោយមានលក្ខណៈច្បាស់លាស់ ហើយនិងជាប្រយោជន៍សម្រាប់លោកមេធាវីនិងកូនក្តីរបស់លោកផងដែរ។ ក្នុងបញ្ហានេះ ខ្ញុំបានជម្រាបពីខាងដើម តាំងពីថ្ងៃម្សិលមិញ ហើយរហូតមកដល់ព្រឹកមិញនេះ គឺខ្ញុំបាននិយាយអំពីអាណត្តិរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលយើងធ្វើការប្រមែប្រមូលឯកសារនេះគឺសំដៅទៅលើឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យ និងឯកសារដែលពាក់ព័ន្ធទៅនឹងរបបកម្ពុជាប្រជាធិបតេយ្យ។

**ស៖** ខ្ញុំគ្រាន់ ខ្ញុំនៅតែមិនច្បាស់ចម្លើយរបស់លោកដដែល។ កម្ពុជាប្រជាធិបតេយ្យមានន័យថាពីឆ្នាំណាដល់ឆ្នាំណាលោកអាចមានឯកសារបញ្ជាក់ថា កម្ពុជាប្រជាធិបតេយ្យដែលលោកបានស្រាវជ្រាវនោះ កើតពីឆ្នាំណាដល់ឆ្នាំណាទេ?

**ឆ៖** លោកមេធាវីប្រហែលជាច្បាស់ជាងខ្ញុំ អំពីការកំណត់ពេលវេលា ហើយនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានេះ ក៏បានកំណត់ពេលវេលាច្បាស់លាស់ហើយផងដែរ។ ហើយខ្ញុំគិតថា ខ្ញុំដូចជាមិនចាំបាច់ដែលត្រូវឆ្លើយនៅក្នុងសំណួរនេះទេបាទ។

**ស៖** សំណួរមួយទៀត។ ចំពោះ ឌី.ស៊ី.ខេម មាន-- ខ្ញុំជឿថាសៀវភៅខ្មៅ លោកមានដែលឮឈ្មោះសៀវភៅខ្មៅទេ? សព្វថ្ងៃមាននៅតុលាការយើង ហើយខ្ញុំជឿថាសៀវភៅនេះចេញមកពី ឌី.ស៊ី.ខេម ដែរ តើពិត ឬមិនពិត?

**ឆ៖** ជាការត្រឹមត្រូវឯកសារនេះ គឺបោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលមិនមែនជាឯកសារកម្ពុជាប្រជាធិបតេយ្យទេ។

**ស៖** សៀវភៅខ្មៅនេះ នៅក្នុងសៀវភៅហ្នឹង ខាងក្រោយបំផុត មានអ្នកថតចម្លងផ្ញើមកពីអាមេរិក។ ឃើញសរសេរចំណងជើង ហើយខ្ញុំបានទាក់ទងអ្នកហ្នឹងផ្ទាល់អត់មានចម្លើយ តើលោកមាន-- សៀវភៅខ្មៅលោកមានរក្សាឯកសារដើមទេ ឬក៏លោកបានថតចម្លងពីកន្លែងណា?

[១១:៥៣:១៨]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវី! អ្ហឹ! លោកសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក អាប់ឌុលឡាក់ ថាវីក៖**

សូមអរគុណលោកប្រធាន។ ខ្ញុំលើកឡើងដោយសង្ខេប។ មេធាវីអាចយោងទៅលើឯកសារដែលយើងហៅថា ជាសៀវភៅខ្មៅ ដែលក្នុងនេះវាពាក់ព័ន្ធទៅនឹងសម័យកម្ពុជាប្រជាធិបតេយ្យ។ ឯកសារលេខ D135.1 ថាតើមេធាវីកំពុងតែយោងទៅលើឯកសារនេះ ឬក៏យ៉ាងណា? វាគឺជាឯកសារបោះពុម្ពផ្សាយដោយកម្ពុជាប្រជាធិបតេយ្យ ឬក៏គាត់យោងទៅលើឯកសារមួយទៀត ដែលមិនមែនបោះពុម្ពដោយរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ?

**ប្រធានអង្គជំនុំ៖**

សូមសហព្រះរាជអាជ្ញាបញ្ជាក់ អ្ហឹ!នែ៎ មេធាវី សុន អរុណ បញ្ជាក់អំពីអត្តសញ្ញាណនៃលេខឯកសារដែលយកមកសួរនេះ។ ឥឡូវនេះ ការសួរដេញដោយនេះដូចជាមានការភ័ន្តច្រឡំ ដោយសារលើកជាទូទៅ សូមលោកបញ្ជាក់អំពីអត្តសញ្ញាណឯកសារឲ្យច្បាស់លាស់ ហើយបើអាចធ្វើបានបញ្ចាំងឯកសារនេះនៅលើកញ្ចក់អេក្រង់ទូរទស្សន៍ ដើម្បីសាក្សីនិងភាគីដទៃទៀត បានពិនិត្យមើលជាមុន មុន

នឹងឆ្លើយ។

**លោក សុន អរុណ៖**

សូមអរគុណលោកប្រធាន។ ឯកសារដែលខ្ញុំបានបញ្ជាក់ពីរឿងសៀវភៅខ្មៅ គឺជាឯកសារដូចលោកព្រះរាជអាជ្ញា គាត់មានប្រសាសន៍ហ្នឹងត្រឹមត្រូវហើយ មានតែមួយហ្នឹងគត់។

**ប្រធានអង្គជំនុំ៖**

ឈប់! ឥឡូវដូចជាអាចភ័ន្តច្រឡំមកបញ្ហានេះ។ លោកព្រះរាជអាជ្ញាបានលើកឡើងថា ឯកសារនេះបោះពុម្ពឡើងដោយ រៀបចំឡើងដោយរបបកម្ពុជាប្រជាធិបតេយ្យ។ ប៉ុន្តែខាងសាក្សីបានឆ្លើយថា ឯកសារហ្នឹងមិនមែនទេ គឺរៀបចំឡើងដោយ ស៊ី.ឌី.ខេម។ អ៊ីចឹងបញ្ហានេះខុសគ្នា ដោយសារបញ្ហាឯកសារអាចមានការភ័ន្តច្រឡំទៅលើឯកសារពាក្យថា "សៀវភៅខ្មៅ" ហ្នឹងអាចមានច្រើន ទំនងជាអាចមានច្រើនឯកសារ។ អ៊ីចឹងហើយបានបញ្ជាក់បញ្ហានេះឲ្យបានច្បាស់លាស់ ពីព្រោះបញ្ហាសៀវភៅខ្មៅនេះជាឯកសារសំខាន់ ដែលជាផ្នែកមួយដែលពាក់ព័ន្ធនឹងឯកសារភស្តុតាងត្រូវដាក់ដេញដោលដែរ។ ពីព្រោះនៅក្នុងសំណុំរឿង០០១ ក៏មានការដេញដោលពាក់ព័ន្ធនឹងសៀវភៅខ្មៅនេះដែរ។ អ៊ីចឹងមិនមែនរឿងធម្មតាទេ បានន័យថា រឿងហ្នឹងគឺត្រូវតែបញ្ជាក់ឲ្យបានច្បាស់លាស់។

ឥឡូវសូមឲ្យលេខអត្តសញ្ញាណ លេខឯកសារ ដើម្បីបន្តការសួរដេញដោលចំណុចនេះឲ្យបានច្បាស់លាស់មុនពេលសម្រាក។

[១១:៥៦:១៨]

**លោក សុន អរុណ៖**

បាទសូមអរគុណលោកប្រធានសាថ្មី។ បើតាមខ្ញុំដឹង នៅក្នុង*ហ្វាយឡេប* ឯកសារដែលបញ្ជាំងពីរឿងសៀវភៅខ្មៅ គឺមានតែមួយគត់ បើតាមខ្ញុំដឹង-- រកឃើញមក។ អ៊ីចឹង ខ្ញុំយកសៀវភៅខ្មៅហ្នឹងរឿងឯកសារមួយហ្នឹង យកមកសួរសាក្សី ដើម្បីឲ្យបញ្ជាក់ថា សំណៅដើមរបស់វានៅណា? ពីព្រោះអីពេលដែលខ្ញុំយកទៅបង្ហាញកូនក្តីខ្ញុំ នួន ជា គាត់បានប្រាប់ថា នេះជាសំណៅដើម-- អ្ហ៎! នេះជាឯកសារមួយដែលមានមែនកាលពីសម័យកម្ពុជាប្រជាធិបតេយ្យ។ ប៉ុន្តែគាត់ចង់បានសំណៅដើមមកវិញ។ ត្រង់ហ្នឹងខ្ញុំខំស្រាវជ្រាវ សួរអ្នកមានឈ្មោះនៅក្នុងសំណៅនៅក្នុង *ហ្វាយឡេប* ហ្នឹងទៅ គេអត់ឆ្លើយរហូតមកដល់ថ្ងៃនេះ។ ថ្ងៃនេះបានខ្ញុំសួរទៅខាងសាក្សី ថាខាង ឌី.ស៊ី.ខេម មានសំណៅដើមសៀវភៅហ្នឹងទេ។ នេះជាសំណួររបស់ខ្ញុំ។ សំដៅដើមលេខប៉ុន្មាន D135.1។

[១១:៥៧:៣៥]

**ប្រធានអង្គជំនុំ៖**

មន្ត្រីតុលាការបញ្ចាំងឯកសារ D135.1 នៅលើកញ្ចក់អេក្រង់ទូរស្សន៍។

*(ការបញ្ចាំងឯកសារនៅលើអេក្រង់ទូរទស្សន៍)*

[១១:៥៨:៣២]

**ប្រធានអង្គជំនុំ៖**

មានឯកសារជាភាសាខ្មែរទេ?

មន្ត្រីតុលាការដាក់ឯកសារ E3/23។

ឃើញនៅមន្ត្រីតុលាការ រកឃើញនៅ?

បញ្ចាំងនៅអេក្រង់ទូរទស្សន៍ឲ្យគាត់ពិនិត្យលើអត្តសញ្ញាណឯកសារនោះសិនមុននឹងដេញដោល។

លោកមេធាវីមើលចំណងនៅក្របមុខនៃឯកសារ ហើយបន្ទាប់មកទៀត គឺពិនិត្យមើលលេខឯកសារ តើឯកសារសៀវភៅហ្នឹងមែនទេដែលលោកមេធាវីលើកមកដេញដោលសួរសាក្សីនៅពេលនេះ?

[១២:០១:១៨]

**សួរដោយលោក សុន អរុណ៖**

**ស៖** ខ្ញុំមិនជា មិនអាចឆ្លើយថាឯកសារច្បាស់លាស់ទេ ពីព្រោះអីឯកសារឃើញលេខខុសគ្នាពីរតាមព្រះរាជអាជ្ញាឲ្យមក អាហ្នឹងខ្ញុំទទួលថាលេខ 135.1។ ប៉ុន្តែ ឯកសារដាក់សរសេរថា “សៀវភៅខ្មៅ” ហ្នឹងគឺមាននៅក្នុង *ហ្សាយឡេប* មែន។ ហើយសៀវភៅខ្មៅនេះ សំណួរមានតែមួយទេ ហើយស្រាលហើយខ្លីទេ គឺថាគ្រាន់តែចង់ដឹងថាឯកសារដើមរបស់សៀវភៅខ្មៅ គឺមានតែមួយគត់ក្នុងកម្ពុជាប្រជាធិបតេយ្យ អឺ!ថាលោកខាង ឌី.ស៊ី.ខេម ហ្នឹងមានឬគ្មាន? ហើយបើមានសំណៅដើមឬអត់? តែប៉ុណ្ណឹងទេសំណួររបស់ខ្ញុំ?

**ឆ៖** តាមដែលខ្ញុំអាចយល់បានអំពីសំណួររបស់លោកមេធាវី នៅពេលមុនដែលឈានមកដល់សៀវភៅខ្មៅ គឺលោកបាននិយាយអំពី “សៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ” ដែលសៀវភៅនេះមានពណ៌ខ្មៅដូចគ្នា ក្របវាខាងមុខពណ៌ខ្មៅដូចគ្នា ហើយលោកនិយាយអំពីការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនេះ។

ដូច្នេះ ទើបឲ្យមាន ទើបការយល់របស់ខ្ញុំអាចមានភ័ន្តច្រឡំដែរអំពីឯកសារ។ តើលោកមេធាវីសូម

បញ្ជាក់លោកមេធាវីម្តងទៀត ថាតើលោកមេធាវីចង់បញ្ជាក់ឯកសារណាមួយច្បាស់លាស់ ហើយពិតប្រាកដដើម្បីឲ្យខ្ញុំបាទបានឆ្លើយជូនលោកមេធាវីឲ្យបានច្បាស់លាស់កុំឲ្យមានមន្ទិលសង្ស័យ។

សូមអរគុណ។

[១២:០៣:១២]

**ស៖** សូមឆ្លើយទៅលោក ដារ៉ា ថាឯកសារដែលខ្ញុំនិយាយនេះ គឺឯកសារស៊ីសង្វាក់គ្នាជាមួយនឹងព្រះរាជអាជ្ញា គឺលោក D134-- លេខ135.1 សៀវភៅខ្មៅ។ ហើយសំណួររបស់ខ្ញុំអំមិញហ្នឹងខុសនឹងគ្នាដែលលោកសាក្សីមានប្រសាសន៍ថាពីរឿងសៀវភៅប្រវត្តិសាស្ត្រយកទៅបង្រៀនកូនក្មេង អាហ្នឹងរឿងមួយផ្សេងទេ មិនមែនចូលគ្នាទេ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះអ៊ីចេះ ដោយសារដល់ពេលម៉ោងត្រូវសម្រាកផង ហើយបញ្ហាសៀវភៅខ្មៅនេះ ដោយសារមានការភ័ន្តច្រឡំ ការសួរនាំ ហើយនិងឆ្លើយរបស់សាក្សី ដោយសារការសួរមិនច្បាស់ ដោយមានបញ្ហាសៀវភៅខ្មៅពីរខុសគ្នា ដែលអ្នកសួរគឺយល់ថាមានតែមួយទេ។ ចំណែកឯអ្នកឆ្លើយ គឺតាមចម្លើយរបស់គាត់គឺមានពីរ។ មួយ សៀវភៅរៀបចំឡើងដោយ ឌី.ស៊ី.ខេម។ មួយទៀត គឺសៀវភៅដែលមាននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលរៀបចំឡើង ហើយដែលមាននៅក្នុងសំណុំរឿង គ្រាន់តែខាងមេធាវីការពារក្តីចង់ដឹងថាតើមានតម្កល់ឯកសារដើមនៅ ឌី.ស៊ី.ខេម ដែរឬទេ? តែប៉ុណ្ណឹងទេ។ ចំណែកឯឯកសារដែលប្រើប្រាស់អេឡិចត្រូនិច ហ្នឹងគឺនៅក្នុងកម្មវិធី *ហ្សាយឡេប* ដែលប្រើប្រាស់នៅក្នុង អ.វ.ត.ក នេះគឺមានហើយ។ គាត់គ្រាន់តែបញ្ជាក់ថាបញ្ហាហ្នឹង គឺតើខាង ឌី.ស៊ី.ខេម រក្សាទុកឯកសារដើមនៅ ឌី.ស៊ី.ខេម ដែរឬទេ អ៊ីចឹងមែនទេលោកមេធាវី?

**លោក សុន អរុណ៖**

សូមអរគុណលោកប្រធានណាស់ ត្រឹមត្រូវហើយ ខ្ញុំមិនបានពន្យល់ក្បោះក្បាយអ៊ីចឹងទេ ប៉ុន្តែចំណុចគំនិតរបស់ខ្ញុំ គឺប៉ុណ្ណឹង។ ហើយខ្ញុំបន្តទៅទៀត គឺខ្ញុំអស់សំណួរ មានតែប៉ុណ្ណឹងទេ មានតែសហការីរបស់ខ្ញុំនឹងមានបន្តក្រោយ បើមានពេលវេលា។ សូមអរគុណ។

[១២:០៥:២២]

**ប្រធានអង្គជំនុំ៖**

តើលោក ដារ៉ាពៅ អាចឆ្លើយនឹងសំណួរនេះបានទេ? ឬក៏ចាំពិនិត្យឯកសារហ្នឹងសិន ដើម្បីផ្ទៀង

ផ្ទាត់នៅចម្លើយចៀសវាងការភ័ន្តច្រឡំ ដូចលោកឆ្លើយអម្បាញ់មិញហ្នឹង គឺមានការភ័ន្តច្រឡំឆ្ងាយគ្នាមែនទែនរវាងសៀវភៅខ្មៅនេះ។

**លោក វ៉ាន់ថាន់ ពៅដារ៉ា៖**

សូមជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំស្នើសុំមើលឯកសារហ្នឹងជាក់ស្ដែងសិន ទើបខ្ញុំអាចពន្យល់បាន។ ខ្ញុំសូមបញ្ជាក់បន្ថែមលោកប្រធានអម្បាញ់មិញ បាទ ខ្ញុំអត់មានការភ័ន្តច្រឡំទេ ព្រោះខ្ញុំបានឆ្លើយថា សៀវភៅប្រវត្តិកម្ពុជាប្រជាធិបតេយ្យនេះមានបោះពុម្ពនៅមជ្ឈមណ្ឌលឯកសារកម្ពុជា។ ខ្ញុំបានឆ្លើយដល់ប៉ុណ្ណឹងទៀត ខ្ញុំអត់មានការភ័ន្តច្រឡំទេ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណណាស់ ដើម្បីច្បាស់លាស់មេធាវីការពារក្ដី នួន ជា លោក សុន អរុណ គឺសំណួរអំមិញមិនទាន់ជាក់ច្បាស់នៅឡើយទេ។ អ៊ីចឹងសូមត្រៀមនូវឯកសារដើម្បីបង្ហាញគាត់ នៅពេលដែលគាត់ត្រឡប់មកវិញ សំណួរចាត់ទុកជាសំណួរចុងក្រោយដើម្បីឲ្យគាត់ឆ្លើយបញ្ជាក់ ដោយបង្ហាញអត្តសញ្ញាណ ឯកសារហ្នឹងច្បាស់លាស់ ដើម្បីឲ្យគាត់ឆ្លើយនឹងសំណួរអម្បាញ់មិញនេះ។

[១២:០៦:៤៣]

**លោក សុន អរុណ៖**

អរគុណលោកប្រធានណាស់ ខ្ញុំនឹងបង្ហាញឯកសារហ្នឹង ដោយមានសំណៅជូននៅពេលចូលត្រឡប់មកវិញ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះដល់ពេលសមល្មមនឹងសម្រាកពិភាក្សាថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកដើម្បីពិភាក្សាថ្ងៃត្រង់ ចាប់ពីពេលនេះទៅរហូតដល់ម៉ោងមួយកន្លះរសៀលនេះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយមន្ត្រីតុលាការសម្របសម្រួលដល់សាក្សី ដើម្បីឲ្យគាត់មានវត្តមាននៅក្នុងបន្ទប់សវនាការនេះ បានមុនពេលអង្គជំនុំជម្រះចូលមកកាន់អាសនៈ។

អនុរក្សមន្ទីរឃុំឃាំងឲ្យនាំខ្លួនជនជាប់ចោទទាំងពីររូបទៅកាន់បន្ទប់សម្រាកនៅខាងក្រោម ហើយនិងឲ្យនាំគាត់មកកាន់បន្ទប់សវនាការនេះវិញ នៅរសៀលនេះឲ្យបានមុនម៉ោងមួយ និងសាមសិបនាទី។

សូមសម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១២:០៧ នាទី ដល់ម៉ោង ១៣:៣១នាទី)*

[១៣:៣១:៥២]

**ប្រធានអង្គជំនុំ៖**

សូមអង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ កាលពីព្រឹកមិញ យើងមុននឹងសម្រាក យើងបានជម្រាបជូនទៅមេធាវីជាតិការពារក្ដីឲ្យលោក នួន ជា ដើម្បីរៀបចំនូវឯកសារសៀវភៅខ្មៅ ដោយបង្ហាញអំពីអត្តសញ្ញាណឯកសារ និងអាចបង្ហាញនៅលើអេក្រង់ទូរទស្សន៍ ដើម្បីអង្គជំនុំជម្រះ និងភាគីដទៃទៀតបានពិនិត្យមើលឯកសារនោះ ហើយនិងតាំងសំណួរ ដែលគាត់អះអាងថា ជាសំណួរចុងក្រោយ។ ហើយអង្គជំនុំជម្រះ សូមរំឭកផងដែរថា ឯកសារនោះគឺ កាលពីដើមឡើយនៅក្នុងរឿង គឺឯកសារ D135.1 ហើយអង្គជំនុំជម្រះបានប្ដូរចំណាត់ថ្នាក់ឯកសារនោះពី D135.1 ទៅជាឯកសារ E3/23 វិញ។ ហើយសូមពិនិត្យមើលកថាខណ្ឌ៥ ឯកសារ E159។ នេះជា ទំនងជាឯកសារនេះដែលជាឯកសារសៀវភៅខ្មៅ នៅក្នុងសំណុំរឿងក្ដីរបស់យើងនេះ។

សូមខាងមេធាវីជាតិការពារក្ដីលោក នួន ជា បញ្ជាក់អំពីអត្តសញ្ញាណឯកសារនេះ មុននឹងតាំងសំណួរចំពោះសាក្សី។ សូមអញ្ជើញ!

[១៣:៣៣:៣៣]

**លោក សុន អរុណ៖**

ជាបឋមសូមអរគុណលោកប្រធាន។ ប៉ុន្តែមុននឹងខ្ញុំចូលដល់សាច់រឿងនេះ ខ្ញុំសូមលោកប្រធានអនុញ្ញាតឲ្យកូនក្ដីខ្ញុំបាទ នួន ជា ដោយគាត់អស់កម្លាំងពេកថ្ងៃរសៀល សូមឲ្យគាត់ចុះទៅស្ដាប់សវនាការនៅបន្ទប់ខាងក្រោម។ សូមអនុញ្ញាត ហើយពាក្យខ្ញុំបានដាក់ជូនទៅខាងក្រឡាបញ្ជីហើយ។

**ប្រធានអង្គជំនុំ៖**

ជាការលះបង់សិទ្ធិនៅក្នុងការចូលរួមផ្ទាល់ នៅអង្គជំនុំជម្រះនេះ ឬក៏យ៉ាងម៉េច? សូមលោកបង្ហាញភាពក្បោះក្បាយតាមលក្ខខណ្ឌនៃការណែនាំកន្លងមកឲ្យបានច្បាស់លាស់ ទាំងការនិយាយទាំងការសរសេរនូវលិខិតក្នុងការលះបង់សិទ្ធិ។

**លោក សុន អរុណ៖**

សូមជម្រាបសាជាថ្មី កូនក្ដីខ្ញុំ នួន ជា សុំលះបង់សិទ្ធិនៅស្ដាប់ផ្ទាល់នឹងសាលសវនាការ សុំទៅស្ដាប់នៅបន្ទប់ខាងក្រោមវិញ ដោយសារគាត់មាន-- អស់កម្លាំងពេកថ្ងៃរសៀលមិនអាចអង្គុយបាន។

[១៣:៣៤:៥៥]

**ប្រធានអង្គជំនុំ៖**

អង្គជម្រះយល់ព្រមតាមសំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលបានស្នើសុំតាមរយៈមេធាវីរបស់គាត់ ដោយលះបង់សិទ្ធិក្នុងការចូលរួមកិច្ចដំណើរការសវនាការដោយផ្ទាល់ នៅក្នុងបន្ទប់សវនាការនេះ ទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់នៅខាងក្រោមបន្ទប់សវនាការនេះតាមរយៈឧបករណ៍សោតទស្សន៍។ ហើយក្រុមមេធាវីការពារក្តី នួន ជា ត្រូវតែប្រគល់មកឲ្យអង្គជំនុំជម្រះភ្លាមនូវលិខិតលះបង់សិទ្ធិចូលរួមនៅសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការ ដោយចុះហត្ថលេខា ឬផ្តិតម្រាមដៃយ៉ាងជាក់ច្បាស់ពីជនជាប់ចោទផង។ ហើយបង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទរូបនេះ អាចបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទ នួន ជា ទៅកាន់បន្ទប់ខាងក្រោម ដែលរៀបចំទុកជាស្រេចនូវឧបករណ៍សោតទស្សន៍សម្រាប់គាត់។

[១៣:៣៥:៥៥]

**លោក សុន អរុណ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមបន្ត ហើយបញ្ចប់នូវសំណួររបស់ខ្ញុំ។ សំណួរចុងក្រោយបំផុតហ្នឹងនិយាយអំពី "សៀវភៅខ្មៅ" ពីព្រឹកមិញខ្ញុំបាននិយាយអំពី "សៀវភៅខ្មៅ" ប៉ុន្តែដល់ខ្ញុំឆែកឲ្យច្បាស់លាស់ទៅ សៀវភៅនេះបើក្នុងភាសាអង់គ្លេស គេហៅថា "ប្លេក ផេបភ័រ"។ នៅតុលាការមុនដំបូងបាន តាមខ្ញុំដឹងមានតែ"ប្លេក ផេបភ័រ" ហ្នឹងទេ ដែលមានលេខដូចលោកប្រធានបានមានប្រសាសន៍អំមិញអ៊ីចឹង D135.1 និងក្រោយមក ខាងតុលាការសាលាដំបូងដូរលេខទៅជា E3/23។ ហើយបើអនុញ្ញាតខ្ញុំសូមបញ្ចាំងស្លាយជូនឲ្យមើលនៅក្នុងទូរទស្សន៍។ សូមអស់។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត សូមអញ្ជើញ!

*(ការបញ្ចាំងឯកសារនៅលើអេក្រង់ទូរទស្សន៍)*

មានជាភាសាខ្មែរទេ?

**សួរដោយលោក សុន អរុណ៖**

ភាសាខ្មែរគឺ បើតាមខ្ញុំដឹងមកថាមានបកប្រែជាភាសាខ្មែរដាក់ក្នុង *ហ្សាយឡោហ៍*ដែរ។ មានឈ្មោះ

ថា “សៀវភៅខ្មៅ” លេខដូចគ្នា។

[១៣:៣៧:៣៤]

**ស៖** ត្រង់នេះ ខ្ញុំចង់សួរថា ឯកសារនេះមកពី ឌី.ស៊ី.ខេម ឬក៏មិនមែនទេ?

**លោក វ៉ាន់ថាន់ ដារ៉ាពៅ៖**

**ឆ៖** សូមជម្រាបលោកមេធាវី គឺឯកសារនេះមាននៅមជ្ឈមណ្ឌលឯកសារកម្ពុជា។

**ស៖** មានសំណៅដើម ឬក៏កូពី?

**ឆ៖** ទាក់ទងនឹងសំណៅដើម ខ្ញុំបាទ សូមជម្រាបលោកមេធាវីថា បើសិនជាសំណៅដើមនោះនឹងមិនមានលេខ ចុះលេខឯកសារជា “D” នៅលើឯកសារទេ បើសិនជាសំណៅដើម។

**ស៖** នៅៗក្នុងឯកសារនេះដូចជាមិនមានលេខពី ឌី.ស៊ី.ខេម ទេ មានតែលេខពី អូ.ស៊ី.អាយ.ជេ ហើយនិងលេខមកពីតុលាការជាន់ដំបូងយើងនេះ អាហ្នឹងមួយ។ ទីពីរ ពេលដែល ឌី.ស៊ី.ខេម បានទទួលឯកសារនេះជាភាសាអង់គ្លេស ឬភាសាខ្មែរ បកប្រែជាភាសាខ្មែរថា “សៀវភៅខ្មៅ” ហើយ។

**ឆ៖** ខ្ញុំអាចថានៅក្នុងច្បាប់ដើម គឺសៀវភៅ ប្លេក ផេភ័រ នេះជាភាសាអង់គ្លេសបាទ។

**លោក សុន អរុណ៖**

សូមអរគុណណាស់។ ខ្ញុំដូចជាមិនមានសំណួរអីទៅចំពោះសៀវភៅខ្មៅនេះតទៅទៀតទេ សូមអរគុណលោកប្រធានណាស់។ ហើយសហការីរបស់ខ្ញុំនឹងមានសំណួរតទៅទៀត សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណមេធាវី។ សូមអញ្ជើញមេធាវីអន្តរជាតិការពារក្ដី នួន ជា។

[១៣:៣៩:២២]

**លោក ហ្សាស្តេ ប៉ៅ៖**

សូមអរគុណលោកប្រធាន។ មុននឹងខ្ញុំចាប់ផ្ដើមសំណួររបស់ខ្ញុំៗ មានចំណុចមួយសូមលើកជាមួយអង្គជំនុំជម្រះសាលាដំបូង ដោយមិនចំណាយពេលវេលាច្រើនពីពេលវេលារបស់យើងខ្ញុំ។ ខ្ញុំសូមការណែនាំពីអង្គជំនុំជម្រះថា តើខ្ញុំអាចប្រើសេចក្ដីថ្លែងការណ៍ដែលចម្លើយរបស់សាក្សីផ្សេងទៀតបានទេ ដើម្បីសាកសួរមកសាក្សីរូបនេះ? នេះជាជំហររបស់មេធាវីការពារក្ដីក្រុម នួន ជា ដែលថា ព័ត៌មានលម្អិតដែលយើងទទួលបាន គឺខ្ញុំទទួលបានពីចម្លើយរបស់សាក្សីចំនួនប្រាំមួយ ដើម្បីលើកមកសួរសាក្សីរូបនេះ។

[១៣:៤០:០៨]

បើសិនជាយើងខ្ញុំចង់បញ្ជាក់អំពីព័ត៌មានទាំងអស់នេះ ដើម្បីឲ្យយល់បានច្បាស់អំពីមុខងាររបស់ ឌី.ស៊ី.ខេម។ ដូច្នេះយើងខ្ញុំចង់សូមយោងទៅលើចម្លើយរបស់សាក្សីទាំងនេះ ដែលមាននៅក្នុងសំណុំរឿងរួចទៅហើយ ដើម្បីបង្ហាញអំពីជំហរពិតប្រាកដរបស់ក្រុមយើងខ្ញុំ។ ហើយដែលភាគីដទៃទៀតមិនបានដឹងថា តើចម្លើយសារភាពទាំងនេះនិយាយអំពីអ្វីនោះទេ? ហើយខ្ញុំចង់ដឹងអំពីចម្លើយពិតប្រាកដ ពីសាក្សីរូបនេះ។ ដោយខ្ញុំមិនលើកឲ្យចំឈ្មោះទេ ហើយមិនបង្ហាញនូវអត្តសញ្ញាណឲ្យបានច្បាស់លាស់នៅក្នុងបន្ទប់សវនាការនេះទេ។ ហេតុដូច្នេះឯងបានជាខ្ញុំសុំការណែនាំពីអង្គជំនុំជម្រះថា តើខ្ញុំអាចសួរទៅលើចំណុចទាំងអស់នេះបានឬក៏អត់?

*(ចៅក្រមពិភាក្សាគ្នា)*

[១៣:៤៤:០៥]

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវីអន្តរជាតិ!

អង្គជំនុំជម្រះសូមការបញ្ជាក់ពីលោកឡើងវិញឲ្យបានច្បាស់លាស់ បំណងនៃការដែលលោកលើកយក ដកស្រង់នូវចម្លើយរបស់សាក្សីដទៃទៀត ដែលមាននៅក្នុងសំណុំរឿងមកសួរដេញដោលចំពោះសាក្សីរូបនេះ តើលោកអាចឲ្យរហស្សនាមនៃសាក្សីទាំងនោះមកដល់អង្គជំនុំជម្រះបានដែរឬទេ? នេះជាបញ្ហាមួយ មុននឹងអង្គជំនុំជម្រះពិនិត្យសម្រេចលើបញ្ហានេះ លុះត្រាតែលោកដាក់ឲ្យនូវរហស្សនាមជាក់លាក់នៃសាក្សី ដែលប្រើ នឹងប្រើរហស្សនាមជាមុនសិន។

[១៣:៤៤:៥៨]

បញ្ហាទីពីរ ចំពោះចម្លើយសាក្សីដែលជាប្រធានមជ្ឈមណ្ឌលឯកសារកម្ពុជា ទំនងជានឹងត្រូវបានកោះហៅគាត់មកផ្តល់សក្ខីកម្មបន្ថែមទៀត ពីព្រោះតាមការសម្រេចរបស់អង្គជំនុំជម្រះគឺសាក្សីរូបនោះគឺមាននៅក្នុងបញ្ជីគ្រោងទុក នៃការកោះហៅមកផ្តល់សក្ខីកម្ម នៅចំពោះមុខអង្គជំនុំជម្រះរួចហើយដែរហើយ។ អ៊ីចឹងប្រសិនបើពាក់ព័ន្ធនឹងកំណត់ហេតុចំពោះសាក្សីរូបនោះ គឺអង្គជំនុំជម្រះមិនអនុញ្ញាតទេ ហើយទុកពេលវេលាសួរដេញដោលរូបនោះ នៅក្នុងអំឡុងពេលដែលអង្គជំនុំជម្រះនឹងកោះអញ្ជើញគាត់មកផ្តល់សក្ខីកម្ម។

ចំពោះសាក្សីផ្សេងទៀតដែលលោកមានបំណងលើកមក-- លើកកំណត់ហេតុ ដកស្រង់កំណត់

ហេតុមកសួរដេញដោលសាក្សីនេះ តើលោកអាចឲ្យរហស្សនាមសាក្សីទាំងនោះបានទេ? អំមិញប្រាំមួយនាក់ បើដកម្នាក់ចេញអាចនៅប្រាំនាក់។

[១៣:៤៦:៣១]

**លោក ហ្សាស្តើ ប៉ោះ**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមអភ័យទោសប្រសិនណាជាខ្ញុំមិនច្បាស់ ក្នុងចំណោមសាក្សីទាំងប្រាំមួយនេះ គឺថាខ្ញុំអាចផ្តល់រហស្សនាមទៅបាន លើកលែងតែម្នាក់ចេញ។ ប៉ុន្តែខ្ញុំសូមបញ្ជាក់ថា អត្តសញ្ញាណនេះគឺថា នៅក្នុងបន្ទប់សវនាការនេះ ប្រហែលជាគេអាចនឹងដឹងហើយ។

**អ្នកបកប្រែ៖**

អ្នកបកប្រែសូមកែប្រែ គឺថា--

*(ចៅក្រមពិភាក្សាគ្នា)*

[១៣:៤៨:២៤]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យលោកមេធាវី ដកស្រង់នូវចម្លើយសាក្សីដទៃទៀត មកសួរសាក្សីរូបនេះទេ បើលោកចង់សួរគឺសួរនៅពេលណា ដែលកោះហៅសាក្សីនោះ មកចំពោះមុខអង្គជំនុំជម្រះតែប៉ុណ្ណោះ។ ហើយលោកមេធាវី គឺសូមផ្តង់នូវបញ្ហាស្មារតីរបស់លោក ដើម្បីក្នុងការសួរដេញដោលដោយចំណាយពេលវេលា ហើយនិងឲ្យបានតាមអ្វីដែលបានបែងចែក ហើយនិងឲ្យមានប្រសិទ្ធភាព យើងបានណែនាំរួចហើយនៅក្នុងកិច្ចដំណើរការគឺពិនិត្យបញ្ហាទូទៅ ស្តីពីវិធីសាស្ត្រនៃការទទួលឯកសារការបែងចែកប្រភេទឯកសារ និងដំណើរការរក្សាឯកសាររបស់មជ្ឈមណ្ឌលឯកសារ និង/ឬ ប្រភេទឯកសារផ្សេងមួយចំនួនទៀត ដែលពាក់ព័ន្ធនៅក្នុងកិច្ចដំណើរការសវនាការរបស់យើងនេះ ជាពិសេសគឺដំណាក់កាលកិច្ចដំណើរការនៅសំណុំរឿង ០០២/១។

[១៣:៤៩:៣៧]

**លោក ហ្សាស្តើ ប៉ោះ**

សូមអរគុណលោកប្រធានចំពោះការបញ្ជាក់នេះ។ ខ្ញុំដឹងថា អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យខ្ញុំលើកមកសួរនេះ ប៉ុន្តែនេះប្រហែលជាដោយសារបញ្ហានៃការបកប្រែ។ ប៉ុន្តែខ្ញុំបានស្តាប់ថា ការសួរទៅនាយកមជ្ឈមណ្ឌលឯកសារកម្ពុជានេះ គឺលោក យុ ឆាំង វាអាចពាក់ព័ន្ធទៅនឹងនីតិវិធីកំពុងតែសាកសួរនេះ។

ហេតុដូច្នេះហើយបានថា តើខ្ញុំអាចប្រើប្រាស់ចម្លើយរបស់យុ ឆាំង ឬក៏អត់នោះ។ ហើយក្រុមរបស់ខ្ញុំយល់ថា សាក្សីរូបនេះគឺមិនមានរហស្សនាមសម្រាប់រូបគាត់នោះទេ។

សូមអរគុណ។

*(ចៅក្រមពិភាក្សាគ្នា)*

[១៣:៥១:២០]

**ប្រធានអង្គជំនុំ៖**

សូមផ្ដល់ប្រគល់ភារកិច្ចទៅលោក ហ្សង់ម៉ាក ដើម្បីបញ្ជាក់បន្ថែមពីបញ្ហានេះឲ្យបានច្បាស់លាស់ក្រែងលោមានបញ្ហាបកប្រែភាសា។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ជាបឋម ខ្ញុំសូមបញ្ជាក់អំពី ទាក់ទងទៅនឹងភាគីការពារក្ដីរបស់លោក នួន ជា តើលោកនៅតែប្រកាន់គោលជំហរក្នុងការស្ដាប់ចម្លើយរបស់លោក យុ ឆាំង ដែរឬទេ? ប្រសិនជានេះ ថាចង់ធ្វើយ៉ាងដូច្នេះ គឺថាហាក់ដូចជាសមស្របជាង ក្នុងការលោកប្រើប្រាស់សេចក្ដីថ្លែងការណ៍របស់គាត់ ដើម្បីចោទសំណួរទៅគាត់ផ្ទាល់តែម្ដង ជាជាងនឹង គឺថាចោទសំណួរទៅនឹងសាក្សីដែលនៅក្នុងបន្ទប់នេះ។ នេះគឺថាដែលយើងធ្វើអនុវត្តគ្រប់សាក្សីទាំងអស់គឺថា យើងប្រើសក្ខីកម្មរបស់គាត់ ដើម្បីចោទសំណួរទៅគាត់ផ្ទាល់។ តើលោកអាចបញ្ជាក់ជូនអង្គជំនុំជម្រះបានដែរឬទេថា តើលោកចង់ប្រកាន់គោលជំហររបស់លោកដែលថា ចង់ឲ្យលោក យុ ឆាំង មកផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់នេះ?

**លោក ហ្សាស្ដើ ប៉ោ៖**

សូមអរគុណលោកចៅក្រមឡាវែន៍។ ជំហររបស់ក្រុម នួន ជា គឺថានៅចង់សួរ លោក យុ ឆាំង ក្នុងឋានៈជាសាក្សី ដែលយើងខ្ញុំសូមស្នើថា ចម្លើយរបស់គាត់នៅក្នុងសំណុំរឿងក៏អាចឲ្យក្រុមយើងខ្ញុំសួរទៅដល់សាក្សីដទៃទៀតនោះដែរ ដែលនេះជាផ្នែកដ៏សំខាន់នៃ របស់មេធាវីការពារក្ដី ក្នុងការសួរចម្លើយសាក្សីម្នាក់ទៀត ទៅសាក្សីម្នាក់ទៀត ថាតើវាអាចនឹងសមស្រប ស៊ីសង្វាក់គ្នាឬក៏អត់នោះ។ យើងខ្ញុំនៅតែចង់យកចម្លើយរបស់ យុ ឆាំង មកសួរសាក្សីរូបនេះដដែល។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ដូច្នេះ ខ្ញុំគិតថា គឺថាវាច្បាស់ហើយ អ៊ីចឹងពុំមានការប្រែប្រួល គឺថា គោលជំហររបស់អង្គជំនុំជម្រះហ្នឹង គឺថាយើងមិនអាចយោងទៅលើសក្ខីកម្មរបស់សាក្សី ដែលថាយើងនឹងស្ដាប់នៅពេលក្រោយ

នោះទេ។ អ៊ីចឹង គឺថាយើងមិនអាចឆ្លើយតបទៅនឹងសំណើរបស់ក្រុមមេធាវីការពារក្តីបានទេ។

**លោក ហ្សាស្តើ ប៉ោ៖**

ខ្ញុំបានស្តាប់ច្បាស់ហើយ ខ្ញុំនឹងអនុវត្តទៅតាមការសម្រេចនេះ។ ដូច្នេះខ្ញុំសូមសង្ខេបសំណួររបស់ខ្ញុំទៅនឹងសាក្សីរូបនេះ ហើយបើសិនណាជាត្រូវការពេលវេលាបន្ថែមទៀត គឺថាខ្ញុំនឹងសាកសួរបន្ថែមទៀត។

*(ចៅក្រមពិភាក្សាគ្នា)*

**ប្រធានអង្គជំនុំ៖**

លោកក្រុមមេធាវីការពារក្តី នួន ជា នៅមានរយៈមួយម៉ោង មួយម៉ោងទៀត។

[១៣:៥៥:១២]

**សួរដោយលោក ហ្សាស្តើ ប៉ោ៖**

សូមអរគុណលោកប្រធាន។ លោក ដាវ៉ាពៅ សូមស្វាគមន៍ចំពោះវត្តមានរបស់លោកនៅទីនេះ។ ខ្ញុំបានស្តាប់ចម្លើយរបស់លោកពីម្សិលមិញ និងថ្ងៃនេះ ហើយខ្ញុំមានសំណួរដូចខាងក្រោម៖

**ស៖** សំណួរដំបូងរបស់ខ្ញុំ គឺទាក់ទងទៅនឹងគោលបំណង និងទិសដៅរបស់ ឌី.ស៊ី.ខេម ដែលលោកបានលើកពីគោលបំណង និងទិសដៅនេះក្នុងរយៈពេលពីរថ្ងៃនេះ។ ហើយបើខ្ញុំអាចលើកឡើងមួយចំនួនពាក់ព័ន្ធទៅនឹងព័ត៌មាន ពាក់ព័ន្ធទៅនឹងសម័យកម្ពុជាប្រជាធិបតេយ្យ នូវអ្វីដែលបានកើតឡើងក្នុងអំឡុងពេលនេះ ហើយក៏លោកក៏បានលើកឡើងថា ការផ្សះផ្សា និងការអភ័យទោស គឺថាក៏ជាការគោលបំណងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។

[១៣:៥៦:០៦]

ដូច្នេះខ្ញុំសួរថាតើ ឌី.ស៊ី.ខេម មានគោលបំណង ឬក៏ទិសដៅណាផ្សេងទៀតដែរ?

**លោក វ៉ាន់ថាន់ ដាវ៉ាពៅ៖**

**ឆ៖** សូមបញ្ជាក់ថា នៅពេលដែលខ្ញុំនិយាយថា ទាក់ទងទៅដល់ការផ្សះផ្សា និងការអត់ឱននេះ គឺខ្ញុំបាននិយាយទៅដល់គម្រោងនៃការងារមួយ គឺការបណ្តុះបណ្តាល និងបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យទៅដល់សិស្សានុសិស្ស។

**ស៖** សូមអរគុណលោក។ សំណួរនេះនៅតែបន្តទៅទៀត ថាតើលោកអាចផ្តល់នូវគោលបំណងផ្សេងទៀត ដែល ឌី.ស៊ី.ខេម អាចមានទេ ទាក់ទងទៅនឹងការងាររបស់លោកនេះ?

**ឆះ** ខ្ញុំបាទយល់ថា គោលបំណងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា គឺដូចខ្ញុំបានជម្រាបរយៈមួយកន្លងមករួចមកហើយ។

**សះ** អរគុណលោក។ ថាតើ ឌី.ស៊ី.ខេម ដែលមានគោលបំណងណាមួយចង់ឱ្យ នួន ជា ទទួលបាននូវការផ្តន្ទាទោសទេ?

**ឆះ** ខ្ញុំបាទមកទីនេះដូចលោកប្រធានអង្គជំនុំជម្រះបានកោះហៅ គឺឲ្យមកឆ្លើយបំភ្លឺទាក់ទងទៅនឹងឯកសារ។ ហើយសំណួររបស់លោកហាក់បីដូចជាចង់ឲ្យខ្ញុំឆ្លើយទៅនឹងអ្វី ដែលផ្សេងដែលមិនមែនជាកម្មវត្ថុរបស់អ្វីដែលលោកប្រធានចៅក្រមធ្វើការកោះហៅមកធ្វើការបំភ្លឺ។

[១៣:៥៨:១០]

**សះ** ខ្ញុំសូមលើកឡើងដោយក្តីគោរពថា នេះមិនមែនសម្រាប់លោកជាអ្នកសម្រេចទេ គឺសម្រាប់អង្គជំនុំជម្រះជាអ្នកសម្រេច។ វិធីសាស្ត្រដែល ឌី.ស៊ី.ខេម បានប្រើប្រាស់ ដើម្បីប្រមូលឯកសារ គឺបញ្ជាក់ច្បាស់ហើយ។ ដូច្នេះខ្ញុំសូមឲ្យលោកឆ្លើយនូវសំណួរនេះ ដែលពាក់ព័ន្ធដោយផ្ទាល់ទៅនឹងមធ្យោបាយ របៀបដែល ឌី.ស៊ី.ខេម ប្រមូលនូវឯកសារ និងភស្តុតាង។ ថាតើ ឌី.ស៊ី.ខេម ដែលមានលើកឡើងនូវជំហររបស់ខ្លួន ដែលចង់ឲ្យ នួន ជា ទទួលបាននូវការផ្តន្ទាទោសដែរឬទេ?

*(ចៅក្រមពិភាក្សាគ្នា)*

**ប្រធានអង្គជំនុំះ**

សំណួរនេះសាក្សីមិនបាច់ឆ្លើយទេ ពីព្រោះសំណួរចង់ឲ្យសាក្សីឆ្លើយជាការសន្និដ្ឋាននូវគំនិតផ្ទាល់ខ្លួនមិនអាចឲ្យដំណើរការនៅក្នុងកិច្ចដំណើរការរបស់អង្គជំនុំជម្រះបានទេ។ សូមមេធាវីផ្លង់នូវសំណួរដែលសួរ ចៀសវាងឲ្យសាក្សីធ្វើសេចក្តីសន្និដ្ឋាន ឬក៏បង្ហាញពីការយល់ដឹងជាបុគ្គលរបស់ខ្លួនពាក់ព័ន្ធនឹងរឿងក្តី។

[១៤:០០:០០]

**លោក ហ្សាស្តើ ប៉ោះ**

លោកប្រធាន ប្រសិនជាលោកអនុញ្ញាត គឺខ្ញុំសួរសាក្សីរូបនេះអំពីជំហរដែលអង្គការនេះបានប្រកាន់ឡើងទាក់ទងទៅនឹងយថាភាព ក៏ដូចជាភាពអាចទទួលយកបាន ក៏ដូចតម្លៃនៃភស្តុតាងដែលកើតចេញពីអង្គការឯកជននេះ។ ហេតុដូច្នេះហើយ ខ្ញុំសួរថា តើដើម្បីចង់ដឹងថាតើអង្គការឯកជនមួយនេះអព្យាក្រឹត ឬក៏អត់ ហើយមានរបៀបវារៈច្បាស់លាស់ឬអត់? ហើយគោលបំណងមួយដែលអង្គការនេះ

បានលើកឡើង គឺទាក់ទងទៅនឹងការនាំបុគ្គលទាំងឡាយមកធ្វើការផ្តន្ទាទោស។ អង្គការបែបនេះត្រូវពិចារណា សេចក្តីថ្លែងរបស់អង្គការបែបនេះត្រូវតែថ្លែងក្នុងលក្ខណៈមួយអព្យាក្រឹត ហើយដោយសារចំណុចនេះវាពាក់ព័ន្ធទៅនឹងភាពលម្អៀង ទាក់ទងទៅនឹងការប្រមូលនូវឯកសារ ក៏ដូចជាសេចក្តីសម្រេច ក៏ដូចជាភស្តុតាងមួយចំនួនទៀត ដែលសុទ្ធតែជា-- ដែលអង្គការនេះគឺថាមិនប្រមូលភស្តុតាងដោះបន្ទុកនេះទេ។ ហេតុដូច្នេះឯងថា តើខ្ញុំចង់សាកសួរ ចង់ដឹងថាតើមានភាពលម្អៀងមែនឬក៏អត់នោះ។ ដើម្បីវាឆ្លើយបញ្ជាក់នៅនឹងសេចក្តីថ្លែងរបស់អង្គការនេះ។

ហេតុដូច្នេះឯង គឺសាក្សីរូបនេះជាតំណាងឲ្យអង្គការនេះ ជាតំណាងឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយការចោទសួរបែបនេះ គឺថាវាមានការពាក់ព័ន្ធ។

[១៤:០១:៣៥]

**ប្រធានអង្គជំនុំ៖**

សំណួរនេះ គឺមិនឲ្យសាក្សីមិនបាច់ឆ្លើយទេ ពីព្រោះសំណួរសំដៅឲ្យសាក្សីចម្លើយធ្វើសេចក្តីសន្និដ្ឋាន ឬក៏ការឆ្លើយដោយគំនិតអត្តនោម័តិរបស់សាក្សី ទៅនឹងបញ្ហាវាយតម្លៃទៅលើសំណុំរឿង ដែលវាខុសពីមុខងាររបស់សាក្សី។ ប្រសិនបើអស់លោកអស់សំណួរ គឺយើងនឹងប្រគល់នាទីនេះទៅឲ្យមេធាវីផ្សេងទៀតបន្តនឹងការសួរ។

**លោក ហ្សាស្តេី ប៉ោ៖**

សូមអរគុណលោកប្រធាន ខ្ញុំសូមសួរបន្តទៅទៀត។ នៅពេលនេះ ខ្ញុំចង់យោងទៅលើការបោះពុម្ពផ្សាយមួយដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលក្នុងនោះគឺយុទ្ធសាស្ត្រដាក់លាក់នៅក្នុងឆ្នាំ២០០៩ និង២០១១ របស់ ឌី.ស៊ី.ខេម។ ដូច្នេះហើយ ខ្ញុំសូមអនុញ្ញាតពីអង្គជំនុំជម្រះបង្ហាញនៅលើអេក្រង់។ ឯកសារនេះមាននៅជាសាធារណៈនៅតាមប្រព័ន្ធគេហទំព័រ។ ដូច្នេះហើយ ខ្ញុំសូមបង្ហាញតាមអេក្រង់។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត សូមអញ្ជើញ!

**សួរដោយលោក ហ្សាស្តេី ប៉ោ៖**

សូមអរគុណ។ ខ្ញុំសូមអាននូវអ្វីដែលអាននៅក្នុងនេះ ខ្ញុំសូមដកស្រង់៖ “នៅចន្លោះឆ្នាំ២០០៩ និង២០១១ ឌី.ស៊ី.ខេម គឺមានបេសកកម្មរបស់ខ្លួន ដើម្បីធ្វើឲ្យមានការចងចាំនិងការផ្សះផ្សា។ យើងប្រមូលនូវឯកសារប្រឆាំងទៅនឹង-- អំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងបទប្រល័យអំពើពូជសាសន៍ ហើយ

ធ្វើការអប់រំប្រជាជនកម្ពុជាអំពីប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហម"។

**ស៖** ដូច្នេះ ខ្ញុំចង់សួរទៅកាន់លោកថា តើលោកអាចបញ្ជាក់បានដែរឬទេ ដូចដែលបានបង្ហាញតាមរយៈឯកសារនេះ។ ការប្រមែប្រមូលនៃឯកសារភស្តុតាងពាក់ព័ន្ធទៅនឹងអំពើប្រល័យពូជសាសន៍ គឺជាគោលបំណងមួយរបស់ ឌី.ស៊ី.ខេម តើមែនដែរឬទេ?

**ឆ៖** តាមដែលខ្ញុំមើលទៅលើឯកសារនេះ គឺជាឯកសារដែលមិនមែននៅក្នុងសំណុំរឿងដែលមានត្រូវចោទសួរដេញដោល ហើយដែលមាននៅក្នុង មានការកោះអញ្ជើញឱ្យមកធ្វើការបំភ្លឺទេ។ បើសិនជាមានការណែនាំផ្សេងយ៉ាងម៉េច ខ្ញុំបាទនឹងរង់ចាំការណែនាំពីលោកប្រធានចៅក្រម។ សូមអរគុណ។

**លោក ហ្វាស្តើ ប៉ោ៖**

ខ្ញុំសូមធ្វើការឆ្លើយតបទៅនឹងការលើកឡើងរបស់សាក្សី លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញសហព្រះរាជអាជ្ញា!

[១៤:០៥:០០]

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធានខ្ញុំសូមលើកឡើងដោយខ្លីៗ។ ពាក់ព័ន្ធទៅនឹងសំណួរដែលសួរទៅកាន់សាក្សី ពីអង្គជំនុំជម្រះ និងខាងសហព្រះរាជអាជ្ញា រួមទាំងខាងដើមបណ្តឹងរដ្ឋប្បវេណីផងដែរ អំពីអាណត្តិ និងការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជានេះ។ ដូច្នេះ យើងខ្ញុំសូមជំទាស់ការតាំងសំណួរទាំងឡាយដែលពាក់ព័ន្ធទៅនឹងបេសកកម្មរបស់ ឌី.ស៊ី.ខេម។ យើងខ្ញុំមិនឯកភាពជាមួយនឹងខាងមេធាវីការពារក្តីនោះទេ ដែលថាដោយសារតែ ឌី.ស៊ី.ខេម ផ្តោតការងាររបស់ខ្លួនទៅលើការងារជាក់លាក់ដូច្នេះ។ ការផ្តល់ឯកសាររបស់ខាង ឌី.ស៊ី.ខេម មិនអាចទុកចិត្តបាន និងមិនមានភាពអព្យាក្រឹត។ ដូច្នេះ ខ្ញុំសូមឱ្យអង្គជំនុំជម្រះបង្គាប់ទៅដល់មេធាវីការពារក្តី សួរសំណួរជាទូទៅពាក់ព័ន្ធទៅនឹងបេសកកម្ម និងអាណត្តិការងាររបស់ ឌី.ស៊ី.ខេម។ សូមអរគុណ។

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:០៦:៣៩]

**ប្រធានអង្គជំនុំ៖**

សាក្សីពិនិត្យមើលឯកសារនៅលើអេក្រង់នេះមើល ហើយតើលោកអាចឆ្លើយនឹងសំណួររបស់

មេធាវីបានដែរទេ?

**លោក វ៉ាន់ថាន់ ដាវ៉ាពៅ៖**

អរគុណលោកប្រធាន។ នៅក្នុងឯកសារនេះជាឯកសារ ជា*ផូស្ទ័រ* ដែលបោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជា។

**សួរដោយលោក ហ្សាស្តេ ប៉ោ៖**

**ស៖** សូមអរគុណ។ ខ្ញុំបានដឹងចំណុចហ្នឹង ក៏ប៉ុន្តែសំណួររបស់ខ្ញុំគឺថា តើលោកអាចបញ្ជាក់ដែរឬទេ ការប្រមូលភស្តុតាងបទអំពើប្រល័យពូជសាសន៍នេះ គឺជាគោលបំណងមួយរបស់ ឌី.ស៊ី.ខេម ដូចដែលបង្ហាញនៅក្នុង*ផូស្ទ័រ* នេះ តើពិតជាត្រឹមត្រូវដែរឬទេ? សូមឲ្យលោកបញ្ជាក់។

**ឆ៖** បាទ ជាការយល់ដឹង និងការធ្វើការងារកន្លងមករបស់ខ្ញុំរយៈពេល១៧ឆ្នាំ នេះគឺគោលបំណងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា គឺការប្រមែប្រមូលចងក្រងឯកសារ ទាក់ទងទៅនឹងរបបកម្ពុជាប្រជាធិបតេយ្យ ឬអំពីរបបកម្ពុជាប្រជាធិបតេយ្យក្នុង-- ដើម្បីបម្រើដល់ការចងចាំ ហើយនិងការ-- និងប្រវត្តិសាស្ត្រនៃរបបកម្ពុជាប្រជាធិបតេយ្យ។

[១៤:០៨:១៣]

**ស៖** សូមអរគុណ។ ដូច្នេះគោលបំណងមួយនោះ ក៏ដើម្បីជួយជំរុញដល់ការចោទប្រកាន់ទៅដល់លោក នួន ជា ហើយក៏មានគោលបំណងក្នុងការប្រមែប្រមូល នៅក្នុងការប្រមូលភស្តុតាង។ ដូច្នេះខ្ញុំអាចចាត់ទុកថា ចំណុចអម្បាញ់មិញនេះគឺជា គោលបំណងមួយក្នុងចំណោមគោលបំណងធំៗហ្នឹង។ តើមែនដែរឬទេ?

**ឆ៖** នៅមជ្ឈមណ្ឌលឯកសារកម្ពុជា យើងមិនដែលប្រើពាក្យថា ភស្តុតាង គឺយើងប្រមូលព័ត៌មាន ឬឯកសារ ហើយមជ្ឈមណ្ឌលឯកសារកម្ពុជា ក៏មិនធ្វើការវិភាគទៅលើឯកសារដែរ។ ដូច្នេះវាអាស្រ័យទៅលើអ្នកដែលប្រើប្រាស់ឯកសារទាំងអស់នោះ នៅក្នុងការធ្វើការវិភាគ។

**ស៖** សូមអរគុណ។ ខ្ញុំឃើញនៅក្នុង*ផូស្ទ័រ* ហ្នឹងមានពាក្យថា ភស្តុតាង ដែលបានសរសេរនៅក្នុងហ្នឹង ក៏ប៉ុន្តែខ្ញុំសូមចូលទៅដល់ចំណុចមួយទៀត ដែលពាក់ព័ន្ធទៅនឹងគម្រោងនៃការចាប់ឲ្យទទួលខុសត្រូវ។ លោកបានលើកឡើងហើយថា លោកបានចូលរួមការងារគម្រោងឲ្យមានការទទួលខុសត្រូវនៅក្នុងការងាររបស់ ឌី.ស៊ី.ខេម នោះ តើមែនដែរឬទេ?

**ឆ៖** បាទជាការត្រឹមត្រូវ។

[១៤:០៩:២៨]

**ស៖** តើសកម្មភាពការងាររបស់លោកនៅក្នុងគម្រោងនេះ គឺជាអ្វីដែរ? ហើយធ្វើអ្វីខ្លះ? សូមឲ្យលោកធ្វើការពន្យល់លម្អិតបន្ថែមបន្តិចមក។

**ឆ៖** បាទ សូមអរគុណ។ នៅក្នុងគម្រោងនេះ គឺខ្ញុំបានចូលរួមនៅក្នុងការធ្វើបទសម្ភាសន៍ទៅតាមឯកសារដែលមាននៅមជ្ឈមណ្ឌលឯកសារកម្ពុជា គឺទាក់ទងទៅនឹងឯកសារប្រវត្តិរូបនេះបាទ។

**ស៖** សូមអរគុណ លោកអាចពន្យល់បន្ថែមបន្តិចទៀតអំពីគោលបំណងការ-- នៃគម្រោងជំរុញឲ្យមានការទទួលខុសត្រូវ តើមានគោលបំណងអ្វីដែរ សូមលោកពន្យល់បន្តិចមក?

**ឆ៖** នៅក្នុងគោលបំណងនៃគម្រោងនេះគឺសំខាន់ គឺចុះសម្ភាស ដើម្បីប្រមូលនូវព័ត៌មានទាំងឡាយដែលទាក់ទងទៅនឹងរបបកម្ពុជាប្រជាធិបតេយ្យ និងបទពិសោធន៍ដែលបុគ្គលនោះបានឆ្លាប់ឆ្លងកាត់នៅរបបនោះ។

**ស៖** នៅពេលដែលលោកប្រមែប្រមូលព័ត៌មាន តើលោកមានបំណងប្រើប្រាស់ព័ត៌មាននោះដោយរបៀបណាដែរ នៅពេលដែលលោកប្រមែប្រមូលព័ត៌មានទាំងអស់នោះ?

**ឆ៖** សូមជម្រាបលោកមេធាវី ក្នុងគោលបំណងដើម្បីឲ្យសាធារណជនបានប្រើប្រាស់នូវអ្វីដែលបាន ដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានប្រមែប្រមូលនិងចងក្រង។

[១៤:១១:១៥]

**ស៖** តើមានបំណងផ្សេងក្រៅពីហ្នឹងទេ នៅពេលប្រមែប្រមូលព័ត៌មានទាំងអស់នោះ?

**ឆ៖** វាអាស្រ័យទៅលើការប្រើប្រាស់ព័ត៌មាននោះ។

**ស៖** តើលោកអាចជម្រាបដែរឬទេ អំពីការប្រើ-- អាស្រ័យទៅលើការប្រើប្រាស់ដែលអាចគេអាចយកទៅប្រើប្រាស់នោះ ដែលវាពាក់ព័ន្ធនឹងផែនការប្រមែប្រមូលព័ត៌មានដោយ ឌី.ស៊ី.ខេម នោះ?

**ឆ៖** បាទ ខ្ញុំអាចជម្រាបបានគឺថា មានសៀវភៅជាច្រើនដែលបោះពុម្ពដោយប្រើប្រាស់នូវព័ត៌មានទាំងអស់នេះ។

**ស៖** តើមានការប្រើប្រាស់ណាផ្សេងទេ ដែល ឌី.ស៊ី.ខេម ថាប្រមូលព័ត៌មាន ដើម្បីបម្រើការប្រើប្រាស់ផ្សេងពីហ្នឹង?

**ឆ៖** បាទ សូមអរគុណ។ តាមដែលខ្ញុំបានដឹង និងចងចាំ គឺមានការប្រើប្រាស់ជាច្រើន ហើយខ្ញុំមិនអាចបញ្ជាក់បានជាក់លាក់ត្រង់បញ្ហានេះ។

**សៈ** ការប្រើប្រាស់មួយនៅក្នុងហ្នឹង គឺដើម្បីផ្ដល់ជាភស្តុតាង ឬក៏ព័ត៌មាន ជាឧទាហរណ៍ដល់ អ.វ.ត.ក "អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា" ដើម្បីធ្វើការជំនុំជម្រះលោក នួន ជា មែនដែរ ឬទេ?

[១៤:១២:៤៧]

**ឆៈ** តាមដែលខ្ញុំបានធ្វើកិច្ចការងារនេះផ្ទាល់ គឺបទសម្ភាសនេះត្រូវបានស្នើសុំដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែរ។

**សៈ** ខ្ញុំហាក់ដូចជាមិនយល់ចម្លើយរបស់លោក ប៉ុន្តែខ្ញុំចង់សួរថា អ.វ.ត.ក បានស្នើសុំឯកសារពី ឌី.ស៊ី.ខេម ប្រាកដមែន។ ប៉ុន្តែសំណួររបស់ខ្ញុំចង់សួរថា តើ ឌី.ស៊ី.ខេម ប្រមូលព័ត៌មានទាំងឡាយនោះ គឺដើម្បីធ្វើយ៉ាងណាផ្ដល់ជូន និងប្រគល់ជូន អ.វ.ត.ក តើពិតជាដូច្នេះដែរឬទេ?

**ឆៈ** ខ្ញុំបានជម្រាបពីខាងដើមហើយថា ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជា គឺត្រូវបានជាឯកសារដែលត្រូវបាន ដែលអាចប្រើប្រាស់ដោយសាធារណជន។ អ៊ីចឹង នៅពេលដែលសាធារណជនធ្វើសំណើសុំឯកសារណាមួយ គឺយើងធ្វើការផ្ដល់ជូនតាមការស្នើសុំ។ ជាក់ស្ដែងដូចជា មានការស្នើសុំពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា យើងបានផ្ដល់ជូនតាមសំណើ។

[១៤:១៤:០៦]

**សៈ** សូមអរគុណចំពោះចម្លើយ ប៉ុន្តែខ្ញុំសូមសួរបំភ្លឺទៅលើប្រធានបទដែលខ្ញុំសូមបង្ហាញលោកទៅលើឯកសារមួយដែលមាននៅគេហទំព័រ ឌី.ស៊ី.ខេម ដែលក្នុងនោះជាការជំរុញឲ្យទទួលខុសត្រូវជា *ហ្វេកស៊ីត* ដូច្នេះហើយខ្ញុំសូមអនុញ្ញាតពីលោកប្រធាន ដើម្បីបង្ហាញលើអេក្រង់នូវឯកសារនោះដែលវាបង្ហាញអំពីទិដ្ឋភាពទូទៅនៃគម្រោងជំរុញឲ្យមានការទទួលខុសត្រូវ។ សូមអនុញ្ញាត!

**ប្រធានអង្គជំនុំ៖**

អនុញ្ញាត សូមអញ្ជើញ!

[១៤:១៤:៥៣]

**សួរដោយលោក ហ្សាស្តើ ប៉ោះ**

**សៈ** លោក ដារ៉ា ប្រសិនបើខ្ញុំមើលទៅលើកថាខណ្ឌទីពីរ ខ្ញុំនឹងអានវា ដើម្បីឲ្យច្បាស់ទាំងអស់គ្នា។ គោលបំណងនេះគឺពាក់ព័ន្ធដោយផ្ទាល់ទៅនឹងរឿងក្ដីដាក់បន្ទុកទៅលើមេដឹកនាំខ្មែរក្រហម ដែលនៅរស់រានមានជីវិតនៅ អ.វ.ត.ក ហើយវាផ្ដល់ជាវិធីក្នុងការបង្ហាញអំពីខ្សែចង្វាក់នៃការទទួលខុសត្រូវ

និងការអនុវត្តនៃរបបរាយការណ៍ រួមទាំងលក្ខណៈស្ថាប័នរបស់ ឌី.ស៊ី.ខេម ដែលអាចជួយឲ្យបុគ្គលជាមេដឹកនាំនោះ ត្រូវបានយកមកកាត់ទោស ដើម្បីទទួលខុសត្រូវចំពោះអំពើសាហាវឃោរឃៅ ដែលប្រព្រឹត្តនៅក្នុងរបបនោះ។ អ៊ី.ស៊ី.ស៊ី.ស៊ី បានដកស្រង់នូវចំណុចរកឃើញទាំងអស់នេះមួយចំនួនផងដែរ។ ដូច្នេះហើយ ខ្ញុំសូមសួរថា គម្រោងនៃជំរុញឲ្យមានការទទួលខុសត្រូវនោះ គឺដើម្បីធ្វើយ៉ាងណាជំរុញឲ្យមានការចាប់យកមេដឹកនាំទទួលខុសត្រូវ មេដឹកនាំជាន់ខ្ពស់ទាំងអស់នោះមកទទួលខុសត្រូវ។

ដូច្នេះ ខ្ញុំសូមសួរថាតើគម្រោងមួយនេះ គឺមានគោលបំណងផងដែរ ដើម្បីធ្វើយ៉ាងណាចាប់យកមេដឹកនាំទាំងអស់នោះយកមកឲ្យទទួលខុសត្រូវចំពោះអំពើទាំងអស់ ឬចំពោះអ្វីដែលបានកើតឡើង។ តើមានដែរឬទេ?

[១៤:១៦:០៨]

**ឆៈ** ពាក់ព័ន្ធទៅនឹងកិច្ចការនៃការជំរុញឲ្យមានការទទួលខុសត្រូវ ជាឈ្មោះរបស់គម្រោងនេះ គឺខ្ញុំផ្ទាល់ គឺបានចុះទៅធ្វើការសម្ភាសនិងប្រមែប្រមូលព័ត៌មាន ហើយព័ត៌មាននេះត្រូវបានប្រើប្រាស់តាមការស្នើសុំដោយសាធារណជន ឬក៏ដោយអង្គជំនុំជម្រះវិសាមញ្ញ តាមការស្នើសុំបាទ។

**សៈ** ខ្ញុំយល់ថា ខាងលោកហ្នឹងក៏កំពុងតែស្វែងរកភស្តុតាងដែលជាភស្តុតាងដាក់បន្ទុកទៅលើលោក នួន ជា ចំពោះឧក្រិដ្ឋកម្មទាំងឡាយដែលបានប្រព្រឹត្តនៅតាមទីកន្លែងផ្សេងៗផងដែរ។ ដូច្នេះហើយ នេះគឺជាគោលបំណងមួយនៃគម្រោងរបស់ ឌី.ស៊ី.ខេម ដែលត្រូវផ្តល់ភស្តុតាងទាំងឡាយ ដើម្បីធ្វើការដាក់បន្ទុកទៅកាន់លោក នួន ជា តើមានដែរឬទេ?

**ឆៈ** យើងបានផ្តល់ឯកសារនេះដល់គ្រប់ភាគីទាំងអស់ ដែលមានការចង់ប្រើប្រាស់នូវឯកសារនេះ ហើយបានបើកដោយទូលំទូលាយនៅក្នុងការស្នើសុំយកឯកសារនេះមកប្រើប្រាស់។

[១៤:១៧:៣២]

**សៈ** ដូចជាមិនឆ្លើយទៅនឹងសំណួររបស់ខ្ញុំទេ ក៏ប៉ុន្តែខ្ញុំសួរបន្តទៀត ដោយសារតែពេលវេលាវាកំពុងតែដើរទៅមុខ។ ដូច្នេះ ហើយព័ត៌មានដែល ឌី.ស៊ី.ខេម បានប្រមូលបាននោះ គឺយើងបាននិយាយក្នុងរយៈពេលមួយថ្ងៃ ពីរថ្ងៃកន្លងរួចមកហើយ ក៏ប៉ុន្តែខ្ញុំសូមឲ្យលោកសួរឆ្លើយអំពីបញ្ជាកម្រងសំណួរដែលសម្រាប់យកទៅសម្ភាសនោះ តើវាយ៉ាងម៉េចដែរ កម្រងសំណួរហ្នឹង?

**ឆៈ** ប្រសិនបើលោកអាចបង្ហាញអំពីកម្រងសំណួរនោះបាន ខ្ញុំនឹងអាចឆ្លើយទៅតាមចំណុចនីមួយៗបាន ឲ្យបានច្បាស់លាស់បាទ។

[១៤:១៨:១៦]

**ស៖** ខ្ញុំចង់បង្ហាញលោក ខ្ញុំនឹងធ្វើការបង្ហាញ ដូច្នេះហើយ ខ្ញុំសូមឲ្យលោកប្រធានបង្ហាញនូវកម្រងសំណួរដែលមាននៅក្នុងសំណុំរឿង ឯកសារលេខ D155.4 ឯកសារនេះមានលេខ ERN 00291445 អត់មានជាភាសាខ្មែរ និងបារាំងទេ វាមានតែជាភាសាអង់គ្លេសតែប៉ុណ្ណោះ។ នេះគឺជាទំព័រដំបូងនៃកម្រងសំណួរហ្នឹង តើលោកចាំទេ មើលទៅស្គាល់កម្រងសំណួរហ្នឹងដែរឬទេ?

**ឆ៖** បាទ ត្រឹមត្រូវ ខ្ញុំចាំបាន។

**ស៖** តើលោកអាចជម្រាបទេ សំណួរហ្នឹងគេយកទៅប្រើប្រាស់សួរយ៉ាងម៉េចនៅក្នុង ឌី.ស៊ី.ខេម ដោយ ឌី.ស៊ី.ខេម នោះ?

**ឆ៖** បាទ តាមពិតនេះជាអ្វីដែលខ្ញុំឃើញនៅលើអេក្រង់នេះ គឺតែទំព័រខាងមុខ ហើយមិនឃើញមានជា ព័ត៌មានដល់ទៅកម្រងសំណួរទេ។

**ស៖** ខ្ញុំអាចផ្តល់ជាឯកសារក្រដាសមួយច្បាប់ជូនដល់លោក ដើម្បីឲ្យលោកងាយមើល។

**ស៖** ដូច្នេះ ខ្ញុំចង់សួរឲ្យលោកពន្យល់ជូនយើងខ្ញុំ តើ ឌី.ស៊ី.ខេម ប្រើប្រាស់សំណួរទាំងអស់នេះដើម្បីអ្វី? ហើយដោយរបៀបណាដែរ?

**ឆ៖** ការប្រើប្រាស់សំណួរទាំងឡាយ ដែលមាននៅក្នុងកម្រងនៃសំណួរដើម្បីចុះធ្វើការសម្ភាសនេះ គឺដើម្បីទទួលបាននូវព័ត៌មានទាក់ទងនឹងរបបកម្ពុជាប្រជាធិបតេយ្យ ក៏ដូចជាព័ត៌មានដែលអ្នកដែលត្រូវផ្តល់បទសម្ភាសនេះ ធ្លាប់បានឆ្លងកាត់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

**ស៖** ចំណងជើងហាក់ដូចជាច្បាស់លាស់ហើយដែលថា ជាគោលការណ៍ណែនាំសម្រាប់បទសម្ភាសស្តីអំពីប្រវត្តិសាស្ត្រ តើត្រឹមត្រូវដែរឬទេ?

[១៤:២០:៥៥]

**ឆ៖** នៅក្នុងនេះ ព័ត៌មានដែលយើងទទួលនេះ គឺវាអាស្រ័យទៅលើអ្នកដែលផ្តល់បទសម្ភាសឲ្យយើងផងដែរ។

**ស៖** នេះគឺជាឯកសារកម្រងសំណួរដែលលោកបានផ្តល់ជូនអ្នកស៊ើបអង្កេតរបស់ខាងក្រុមលោក នៅពេលដែលគាត់ចុះទៅសម្ភាសតាមទីកន្លែង តើមែនដែរឬទេ?

**ឆ៖** ជាការត្រឹមត្រូវ។

**ស៖** នៅពេលដែលយើងមើលលើកឯកសារនេះ ខ្ញុំហាក់មានលក្ខណៈចម្លែក និងងឿងឆ្ងល់

ដោយរបៀបដែលឯកសារនេះបានរៀបចំដូច្នេះ ហើយនិងផ្នែកតូចៗមួយចំនួនក៏ធ្វើឲ្យខ្ញុំងឿងឆ្ងល់ផងដែរ។ ហើយសូមឲ្យសហការីរបស់ខ្ញុំ តាម-- អូសតាមមកខ្ញុំចំណុចទីមួយនោះ គឺទំព័រទីមួយ ពាក់ព័ន្ធទៅនឹងអំពើមនុស្សឃាត ហើយទំព័រទីពីរ គឺមានចំណុចមួយដែលពាក់ព័ន្ធទៅនឹងអំពើទារុណ្ណកម្ម នៅក្នុងទំព័រទីបី មានផ្នែកតូចមួយពាក់ព័ន្ធទៅនឹងការធ្វើទុក្ខបុកម្នេញផ្នែកសាសនា ហើយនៅក្នុងទំព័រទីបួនមានផ្នែកតូចដែលពាក់ព័ន្ធទៅនឹងទ្រព្យសម្បត្តិវប្បធម៌ ការបំផ្លាញទ្រព្យសម្បត្តិវប្បធម៌ ហើយនៅក្នុងទំព័រទីប្រាំ គឺពាក់ព័ន្ធទៅនឹងអំពើប្រល័យពូជសាសន៍ ស្ដីអំពីការបង្ការកុំឲ្យមានការបង្កកំណើត ហើយចំណុចមួយទៀតគឺបទប្រល័យពូជសាសន៍ អំពីលក្ខខណ្ឌនៃជីវិត បទប្រល័យពូជសាសន៍ស្ដីអំពីការជម្លៀសដោយបង្ខំទៅលើកុមារ។ ទំព័រទី៥ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គឺពាក់ព័ន្ធទៅនឹងអំពើធ្វើឲ្យទៅជាទាសករ។ ទំព័រទី៩ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទាក់ទងទៅនឹងការជម្លៀស ហើយចំពោះទំព័រទី១០ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិទាក់ទងទៅនឹងការដាក់ក្នុងពន្ធនាគារ។

[១៤:២២:៥៨]

ហើយនៅក្នុងទំព័រខាងក្រោមទៀត ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិអំពីអំពើរំលោភសេពសន្ថវៈ។ ខ្ញុំឈប់ត្រឹមនេះសិនទៅ ដោយសារតែវាមានច្រើនណាស់ ដែលវាពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មសង្គ្រាមទៅលើការចាប់ចំណាត់ខ្មាំង ឧក្រិដ្ឋកម្មសង្គ្រាមពាក់ព័ន្ធទៅនឹងការបដិសេធមិនជំនុំជម្រះដោយយុត្តិធម៌ទៅលើជនស៊ីវិល ឧក្រិដ្ឋកម្មសង្គ្រាមពាក់ព័ន្ធទៅនឹងការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ។

ចំណុចទាំងអស់ដូចដែលខ្ញុំបានលើកឡើងនេះ គឺជាចំណុចគោលការណ៍ណែនាំដោយ ឌី.ស៊ី.ខេម សម្រាប់ទៅសម្អាសកំណត់ត្រាប្រវត្តិសាស្ត្រ។ ដូច្នេះ នៅពេលដែលខ្ញុំមើលឯកសារនេះ ហាក់ដូចជាឯកសារនេះ មិនមែនជាគោលបំណងណែនាំសម្រាប់ការសម្អាសប្រវត្តិសាស្ត្រនោះទេ។ ហើយព័ត៌មាននោះ ក៏មិនអព្យាក្រឹតផងដែរ។

[១៤:២៣:៥២]

ចំពោះខ្ញុំ វាហាក់ដូចជាឯកសារប្ដឹងមួយសម្រាប់ធ្វើការចោទប្រកាន់បុគ្គលណាមួយជាក់លាក់។ ដូច្នេះហើយក្រុមមេធាវីការពារក្ដី នួន ជា គឺយល់ថា ឌី.ស៊ី.ខេម កំពុងតែធ្វើការបង្កើត និងកសាងមូលដ្ឋានសម្រាប់ការដាក់បន្ទុកក្នុងការចោទប្រកាន់។ នេះវាមិនអាចឲ្យយើងគិតថា វាជាការស្រាវជ្រាវដោយយុត្តិធម៌ និងដោយអព្យាក្រឹតនោះទេ។ នៅពេលដែលយើងមើលទិដ្ឋភាពទូទៅនៃកម្រងសំណួរទាំងអស់នេះ តើលោកឯកភាពជាមួយនឹងការវាយតម្លៃដូច្នេះដោយក្រុមមេធាវីការពារក្ដីរបស់យើងខ្ញុំដែរឬទេ?

**ឆៈ** ចំពោះអ្វីដែលលោកមេធាវីបានលើកឡើងនេះ គឺជាអ្វីដែលយើងអ្នកដែលទៅធ្វើបទសម្ភាសនេះ សួរបានលុះត្រាតែអ្នកផ្តល់បទសម្ភាសឱ្យយើងបាននិយាយដល់បញ្ហានេះ ទើបយើងមានការសួរបន្តទៅទៀតបាន។ បើមិនដូច្នេះ យើងខ្ញុំមិនសួរ មិនមានលក្ខណៈសួរបែបនេះទេ។

[១៤:២៥:០០]

**សៈ** សូមអរគុណលោក ដារ៉ា។ ក៏ប៉ុន្តែខ្ញុំនិយាយអំពីការរៀបចំបង្កើតឯកសារនៅក្នុងហ្នឹង ការបង្កើតឯកសារហ្នឹងវាហាក់ដូចជាមិនមែនក្នុងគោលបំណងសម្ភាសដើម្បីប្រវត្តិសាស្ត្រនោះឡើយ។ វាជាគោលបំណងវំពឹងថា ចង់ឱ្យមានការចោទប្រកាន់កាត់ទោសទៅដល់មេដឹកនាំកម្ពុជាប្រជាធិបតេយ្យ។ ប្រសិនបើយើងមើលទំព័រ១៩នៃឯកសារដដែលនេះ វាជាគោលការណ៍ណែនាំសម្រាប់បទសម្ភាសប្រវត្តិសាស្ត្រ ហើយទម្រង់បែបបទដែលគេរៀបចំឯកសារនេះនៅលើអេក្រង់ គឺលោកប្រហែលជាអាចមើលឧបសម្ព័ន្ធ ដែលនៅក្នុងឧបសម្ព័ន្ធនោះ គឺលើកឡើងចំណងជើងសរសេរថា “បទល្មើសដែលមាននៅក្នុងលក្ខន្តិកៈ ឬក៏ច្បាប់ សេចក្តីព្រាងច្បាប់របស់តុលាការខ្មែរក្រហម”។ ដូច្នេះហើយនៅពេលដែលលោកមើលចំណងជើងនេះ តើលោកយល់ថា មេធាវីការពារក្តី នួន ជា គិតថា នៅពេលដែលមានមើលឯកសារហ្នឹង គឺ ឌី.ស៊ី.ខេម ព្យាយាមបង្កើតជាមូលដ្ឋានដើម្បីចង់ក្រងជាចម្លើយ ព័ត៌មានដាក់បន្ទុកក្នុងការចោទប្រកាន់នៅក្នុងរឿងក្តីនេះដែរឬទេ? តើលោកយល់ដូចយើងខ្ញុំដែរឬទេ?

[១៤:២៦:២៩]

**ឆៈ** បាទ នៅក្នុងការប្រមែប្រមូលឯកសារ និងព័ត៌មាន គឺយើងមាន លោកមេធាវីប្រហែលជាអាចចងចាំបាននូវអ្វីដែលខ្ញុំបានជម្រាបអំពីគោលបំណងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជានោះ គឺយើងបានផ្តល់ទៅដល់ជនទាំងឡាយណា ដែលចង់រកយុត្តិធម៌ជូនដល់អ្នករស់រានមានជីវិតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ អ៊ីចឹងឱ្យព័ត៌មាននេះ មិនមែនបម្រើតែផ្នែកប្រវត្តិសាស្ត្រទេ គឺបម្រើដល់ជនទាំងឡាយណា ដែលមានបំណងចង់ស្វែងរកយុត្តិធម៌សម្រាប់អ្នករស់រានមានជីវិតផងដែរ។

[១៤:២៧:២២]

**សៈ** សូមអរគុណចំពោះចម្លើយរបស់លោក។ ខ្ញុំទុកចំណុចហ្នឹងមួយបន្តិចសិន ហើយខ្ញុំនឹងសួរនៅពេលក្រោយ។ នៅពេលនេះខ្ញុំកំពុងតែកាយមើលសំណួររបស់ខ្ញុំពាក់ព័ន្ធទៅនឹងអំពើល្មើស ដែលខ្ញុំសួរបន្ថែមទៀត។ ខ្ញុំក៏ចង់សួរលោកនូវសំណួរមួយចំនួនពាក់ព័ន្ធទៅនឹងចំណេះដឹងផ្ទាល់ខ្លួនរបស់លោក។ មុនពេលដំណាក់កាលការបង្កើតតុលាការនេះ តើលោកធ្លាប់មានចូលរួមនៅក្នុងកិច្ចប្រជុំរវាងតំណាងមក

ឌី.ស៊ី.ខេម ជាមួយនឹងខាងការិយាល័យសហព្រះរាជអាជ្ញានៅទីនេះដែរឬទេ?

**ឆ៖** ខ្ញុំបានធ្វើកិច្ចការងារនេះ ដោយមានការ-- នៅពេលដែលមានការស្នើសុំឯកសារ គឺយើងបានសួរនាំអំពីៗការបញ្ជីឯកសារ បើសិនជាមានការងឿងឆ្ងល់ ហើយយើងបានជួបនឹងសហព្រះរាជអាជ្ញានៅពេលដែលមកទទួលឯកសារម្តងៗ។

[១៤:២៨:៤៣]

**ស៖** ខ្ញុំសូមសួរសំណួរជាក់លាក់មួយចំនួន មុនពេលដែល ឌី.ស៊ី.ខេម បានប្រគល់ឯកសារមកកាន់ការិយាល័យសហព្រះរាជអាជ្ញា។ តាមចំណេះដឹងរបស់លោក ថាតើគេមានរៀបចំកិច្ចប្រជុំរវាង ឌី.ស៊ី.ខេម និងការិយាល័យសហព្រះរាជអាជ្ញាទេ ដែលគេរៀបចំជាលក្ខណៈកិច្ចប្រជុំ លក្ខណៈឯកជនផ្ទាល់រវាងស្ថាប័នទាំងពីរហ្នឹង? តើដែលមានអ៊ីចឹងទេ?

**ឆ៖** សូមលោកមេធាវីបញ្ជាក់យ៉ាងឲ្យច្បាស់បន្តិច ថាតើជាស្ថាប័ន និងស្ថាប័នប្រជុំយ៉ាងដូចម្តេច? ឬក៏យ៉ាងម៉េច? សូមលោកមេធាវីបញ្ជាក់សំណួរនេះឡើងវិញឲ្យមានលក្ខណៈច្បាស់លាស់ហើយសាមញ្ញដែលយល់បាន។ បាទ សូមអរគុណ។

[១៤:២៩:៤០]

**ស៖** សូមអភ័យទោសលោក ដារ៉ា ខ្ញុំនឹងសួរឲ្យបានច្បាស់។ តាមដែលលោកដឹងមុនពេលដែលឯកសារទាំងឡាយប្រគល់ជូនដល់ការិយាល័យសហព្រះរាជអាជ្ញា ថាតើនៅពេលនោះមានការរៀបចំប្រជុំរវាងអ្នកតំណាងមកពីខាង ឌី.ស៊ី.ខេម ជាមួយនឹងអ្នកតំណាងរបស់ការិយាល័យសហព្រះរាជអាជ្ញាដែរឬទេ?

**ឆ៖** នៅក្នុងការចងចាំរបស់ខ្ញុំ គឺថាដោយសារខ្ញុំត្រូវបានមជ្ឈមណ្ឌលចាត់តាំងឲ្យធ្វើជាអ្នកទំនាក់ទំនងមកអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បើសិនជាមានការនៅក្នុងការងារផ្តល់ឯកសារនេះ ហើយមានពេលខ្លះ គឺយើងបានរៀបចំជាការប្រជុំសម្រាប់ឲ្យមន្ត្រីណាមួយ ឬក៏និស្សិតដែលមកធ្វើកម្មសិក្សានៅមជ្ឈមណ្ឌលឯកសារកម្ពុជា មកធ្វើការជួបជាមួយនឹងមន្ត្រីនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

[១៤:៣១:០៥]

**ស៖** ប្រហែលជាបញ្ហា មានបញ្ហាបកប្រែហើយ ប៉ុន្តែលោកមិនទាន់ឆ្លើយសំណួរខ្ញុំនៅឡើយទេ តាមដែលលោកដឹង ថាតើធ្លាប់មានការប្រជុំរវាងតំណាងរបស់ការិយាល័យសហព្រះរាជអាជ្ញា និង

តំណាង ឌី.ស៊ី.ខេម ដែរឬទេ មុននឹងបញ្ជូនឯកសារពី ឌី.ស៊ី.ខេម មកឲ្យការិយាល័យសហព្រះរាជអាជ្ញា?

**ឆ៖** ខ្ញុំសូមបញ្ជាក់ឲ្យបានច្បាស់លាស់ គឺថានៅក្នុងការផ្តល់ជូនឯកសារដល់ការិយាល័យសហព្រះរាជអាជ្ញានេះ គឺយើងបានផ្តល់តាមការស្នើសុំ ហើយមានបញ្ជីឯកសារបានមកដល់មជ្ឈមណ្ឌលឯកសារកម្ពុជា ហើយយើងបានផ្តល់ឯកសារនេះទៅតាមបញ្ជីឯកសារដែលបានផ្តល់មក ហើយបញ្ជីនេះគឺមាននៅក្នុងនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា លោកអាចរកមើលបាន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញៗសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក អាប់ឌុលឡាក់ ថាវីក៖**

លោកប្រធាន មេធាវីការពារក្តី គឺថាមានរយៈពេលយ៉ាងវែង ខ្ញុំថាបើសិនណាជាគាត់លើកសំណួរឲ្យបានជាក់លាក់ទាក់ទងទៅនឹងការរៀបចំទៅនឹងដីកាបញ្ជូនរឿងឲ្យស៊ើបសួរ ហើយទាក់ទងទៅនឹងការដាក់ឯកសារ។ ដោយសារថាមានការដាក់ឯកសារជាច្រើន សុំឲ្យបង្ហាញនូវកាលបរិច្ឆេទផងថាតើឯកសារណាខ្លះ ដែលបានទទួលពីមជ្ឈមណ្ឌលឯកសារកម្ពុជាដាក់ចូលទៅក្នុងដីកាបញ្ជូនរឿងឲ្យស៊ើបសួរអីហ្នឹង។ ដោយសាររយៈពេលនេះ គឺថាមានរយៈមកប្រាំឆ្នាំហើយ។

**លោក ហ្សាស្តើ ប៉ោ៖**

លោកសហព្រះរាជអាជ្ញា ខ្ញុំ ជាពិតហើយ អន្តរាគមន៍របស់លោកដែលលោកចង់ឲ្យបញ្ជាក់ខ្ញុំនិយាយអំឡុងពេលអ្វីខ្លះនោះ។ ហើយសហការីរបស់ខ្ញុំកំពុងតែមើល តើលោកអាចបញ្ជូនកាលបរិច្ឆេទមកឲ្យខ្ញុំវិញ ថាតើលោកទទួលបានឯកសារពី ឌី.ស៊ី.ខេម មកឲ្យការិយាល័យសហព្រះរាជអាជ្ញាដំបូងបំផុតនៅថ្ងៃណាខែណាដែរ?

**ប្រធានអង្គជំនុំ៖**

ជំទាស់របស់សហព្រះរាជអាជ្ញាមិនមានប្រសិទ្ធភាពទេ។ អ៊ីចឹងមេធាវីអាចសួរបាន នេះជាវិធីសាស្ត្រ ជាបច្ចេកទេសនៅក្នុងការសួរដេញដោលពាក់ព័ន្ធទៅនឹងកិច្ចដំណើរការរបស់ ឌី.ស៊ី.ខេម ទាំងមូល នៅក្នុងនោះគឺមានទំនាក់ទំនងកិច្ចការរវាង ឌី.ស៊ី.ខេម ជាមួយនឹង អ.វ.ត.ក។ ចំណែកឯការតទល់គ្នារវាងមេធាវីអំពីការបង្ហាញឯកសារជាក់លាក់នេះ នោះមិនមែនជាភារកិច្ចរបស់សហព្រះរាជអាជ្ញាទេ ជារឿងរបស់អង្គជំនុំជម្រះ។

សូមផ្តល់វេទិកាមេធាវីបន្តសំណួរ។ ហើយសាក្សីអាចឆ្លើយជាក់លាក់ឲ្យចំនឹងសំណួរដែលសួរ សួរថាមានកិច្ចប្រជុំដែលទេកន្លងមក ចាប់ពីចាប់ផ្តើម អ.វ.ត.ក មក រវាងលោក ឬក៏តំណាងរបស់លោកនៅក្នុងតំណាងរបស់ ឌី.ស៊ី.ខេម ជាមួយនឹងសហព្រះរាជអាជ្ញា មាន ឬអត់? បើមានប៉ុន្មានដង? ពេលណាខ្លះ? នេះជាចម្លើយដែលតបទៅនឹងសំណួរ ហើយបើអត់ថាអត់ទៅ ដូចជាចប់ហើយ។

[១៤:៣៥:២០]

អញ្ជើញលោកមេធាវី ហើយលោកមានពេលខ្លីទេ ក្រែងលោលោកត្រូវគិតផងដែរ អំពីការប្រើប្រាស់ពេលវេលារបស់លោកឲ្យមានប្រសិទ្ធភាព។ តិចដល់ពេលអស់ពេល ហើយលោកមកតវ៉ាថាលោកត្រូវការពេលទៀត អង្គជំនុំជម្រះមិនឲ្យទេ។ នេះនិយាយគ្នាឲ្យបានដឹងច្បាស់ជាមុន ព្រោះអង្គជំនុំជម្រះបានកំណត់ពេលវេលារួចហើយ ភាគីផ្សេងៗទៀតក៏បានកំណត់ដូចគ្នា។

**លោក ហ្សាស្តេី ប៉ោ៖**

សូមអរគុណ លោកប្រធាន ខ្ញុំប្រហែលជាមានច្រឡំការបកប្រែ ប៉ុន្តែសំណួរផ្ទាល់តែម្តង ដែលលោកប្រធានបានសួររបស់គាត់ គឺខ្ញុំចង់ឲ្យ-- ចង់ស្តាប់សំណួរនេះម្តងទៀត។

**ប្រធានអង្គជំនុំ៖**

លោកអាចតាំងសំណួរនេះសាជាថ្មីម្តងទៀត ក្រែងលោសាក្សីភ្លេចនូវសំណួរដែលលោកសួរ ហើយសាក្សីត្រូងត្រាប់ស្តាប់ ហើយរង់ចាំឆ្លើយតប។

**សួរដោយលោក ហ្សាស្តេី ប៉ោ៖**

**ស៖** លោក ដាវ៉ាពៅ សំណួររបស់ខ្ញុំគឺថា មានកិច្ចប្រជុំណាមួយរវាងតំណាងរបស់ការិយាល័យសហព្រះរាជអាជ្ញា និងតំណាងរបស់ ឌី.ស៊ី.ខេម ដែរឬទេ មុននឹងបញ្ជូនឯកសារពី ឌី.ស៊ី.ខេម មកឲ្យការិយាល័យសហព្រះរាជអាជ្ញាហ្នឹង?

[១៤:៣៦:៥៥]

**ឆ៖** បាទ សូមអរគុណលោកមេធាវី ទាក់ទងទៅនឹងការប្រជុំ បើសិនជាលោកមេធាវីសួរថាតើរូបខ្ញុំផ្ទាល់នេះបានជួបប្រជុំពិភាក្សាជាមួយនឹងក្រុមសហព្រះរាជអាជ្ញានោះទេ គឺខ្ញុំបានឆ្លើយ ខ្ញុំអាចឆ្លើយបានថា គ្មានទេ បាទ។

**ស៖** លោក ដាវ៉ាពៅ គឺថាសូមអរគុណចម្លើយនេះ នៅតែមិនជាចម្លើយនៅឡើយដែរ ខ្ញុំមើលនាឡិកាទៅ ខ្ញុំចង់អស់ពេលហើយ។ ដូច្នេះ ខ្ញុំ-- ចម្លើយដែលសាក្សីផ្តល់មកឲ្យនេះ គឺមិនចំចំណុចនៅ

ឡើយទេ ប្រហែលជាដោយសារបកប្រែ ឬក៏យ៉ាងណា ប៉ុន្តែខ្ញុំមានការកត់សម្គាល់។ ខ្ញុំសូមសួរឲ្យងាយជាងនេះទៅទៀត តើមជ្ឈមណ្ឌលឯកសារកម្ពុជាដែលមានផ្ដល់បញ្ជីឯកសារជាក់លាក់ណាមួយមកឲ្យការិយាល័យសហព្រះរាជអាជ្ញា ដើម្បីយកមកធ្វើការចោទប្រកាន់លោក នួន ជា ដែរឬទេ តាមដែលលោកដឹងកន្លងមកនេះ?

**ឆៈ** ខ្ញុំបាទ សូមធ្វើការបញ្ជាក់ឲ្យបានច្បាស់លាស់គឺថា រៀងរាល់ឯកសារដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានផ្ដល់មកការិយាល័យសហព្រះរាជអាជ្ញា គឺបានមកអំពីការស្នើសុំ ដែលមានបញ្ជីឯកសារប៉ុន្មានដែលត្រូវស្នើសុំ ហើយមជ្ឈមណ្ឌលឯកសារកម្ពុជាឆ្លើយតបទៅវិញ ទៅតាមបញ្ជីនោះ។ ហើយមានលិខិតប្រគល់ និងទទួលយ៉ាងច្បាស់លាស់ ហើយមានការចុះហត្ថលេខាផ្ទាល់ដោយខ្ញុំបាទថែមទៀតផង។

[១៤:៣៨:៥៧]

**សៈ** នៅតែមិនទាន់ជាចម្លើយតបទៅនឹងសំណួរខ្ញុំនៅឡើយ ខ្ញុំបានកត់សម្គាល់ ហើយខ្ញុំមើលនាឡិកាទៅគឺថា ខ្ញុំត្រូវតែរូតរះទៅមុខទៀត។ ខ្ញុំមិនចង់សួរសំណួរនេះទេ ដោយសារគាត់មិនបានឆ្លើយឲ្យចំៗទៅនឹងសំណួររបស់ខ្ញុំ។ សូម្បីតែមិននឹងឆ្លើយថា ខ្ញុំមិនដឹងទេ ដូច្នេះខ្ញុំសូមបន្តទៅទៀត។ លោកបានលើកឡើងកាលពីម្សិលមិញ និងថ្ងៃនេះថា នៅពេលដែលឯកសារចូលមកលោកបានរៀបចំចាត់ចែងឯកសារទាំងអស់នោះដោយដាក់ថា តើនោះចូលមកនៅថ្ងៃណា? ខែណា? តើមែនទេ?

**ឆៈ** ចំពោះឯកសារ ដោយឯកសារមានចំនួនច្រើនសន្ធឹកសន្ធាប់យ៉ាងដូច្នេះ ខ្ញុំមិនអាចចងចាំបានថា ថ្ងៃណាមួយជាក់លាក់ដែលឯកសារមួយណាចូលមកមជ្ឈមណ្ឌលឯកសារកម្ពុជា។ ប៉ុន្តែលោកមេធាវីអាចរកបានអំពីប្រភពនៃពេលវេលា ឯកសារដែលចូលមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈការធ្វើបញ្ជីឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។

[១៤:៤០:១០]

**សៈ** សូមអរគុណច្រើន គឺខ្ញុំសូមសួរថាតើលោកបានរៀបចំឯកសារទាំងអស់នេះដោយដាក់ជាថ្ងៃខែចូលមកនៅថ្ងៃខែណាឆ្នាំណា ហើយនិងមកពីប្រភពណា? តើដូច្នេះមែនទេ?

**ឆៈ** ជាការត្រឹមត្រូវ។

**សៈ** តើលោកធ្លាប់រៀបចំនូវបញ្ជីឯកសារ ឬក៏ថតចម្លងនូវឯកសារទាំងអស់នោះដោយយោងទៅលើបុគ្គលណាម្នាក់ ដោយសំអាងទៅលើបុគ្គលណាម្នាក់ដែលពាក់ព័ន្ធទៅនឹង នួន ជា នេះដែរឬទេ?

**ឆ៖** ជាទូទៅ គឺឯកសារដែលយើងបានថតចម្លង បាទគឺយើងបានមើលឯកសារ ហើយយើងបានថតចម្លង ហើយមានឯកសារខ្លះដែលយើងឃើញមានជាចំណងជើង មាននៅលើឯកសារ ហើយមានឯកសារខ្លះ គឺមានឈ្មោះ អ៊ំ នួន, មានឈ្មោះ អ៊ំ វ៉ាន់ ដូចដែលមាននៅលើឯកសារ។

[១៤:៤១:៤៣]

**ស៖** អរគុណ តើ ឌី.ស៊ី.ខេម មានឯកសារ សំណុំឯកសារមួយហៅថា សំណុំឯកសារស្តីអំពី នួន ជា ឬឯកសារពាក់ព័ន្ធទៅនឹង នួន ជា ដែលប្រមូលមកពីកន្លែងណាមួយទេ?

**ឆ៖** ឯកសារទាំងអស់នេះត្រូវបានមានការប្រមែប្រមូលចងក្រង ដោយដាក់ចូលជាប្រភេទឯកសារផ្សេងៗគ្នា។ ដូចជា ខ្ញុំបានជម្រាបហើយថាមានឯកសារប្រភេទ “I” ដែលជាឯកសារប្រវត្តិរូប មានឯកសារ “D” ដែលជាឯកសារចម្រុះ បាទ។

**ស៖** តើប្រភេទឯកសារណាមួយ ក្នុងចំណោមឯកសារទាំងនោះមានប្រភេទឯកសារពាក់ព័ន្ធតែ នួន ជា ដែរឬទេ?

**ឆ៖** មានឯកសារខ្លះមានឈ្មោះ អ៊ំ នួន នៅលើឯកសារ ហើយមានឯកសារខ្លះអត់មានឈ្មោះ អ៊ំ នួន នៅលើឯកសារទេ តាមដែលខ្ញុំចងចាំបាន។

**ស៖** លោកមិនទាន់ឆ្លើយសំណួរខ្ញុំទេ ថាតើមានប្រភេទឯកសារជាក់លាក់ណាមួយនៅ ឌី.ស៊ី. ខេម វាអាចជាឯកសារនៅលើក្រដាស ឬក៏ឯកសារនៅក្នុងប្រព័ន្ធកុំព្យូទ័រ ដែលដាក់ឈ្មោះថា ឯកសារសម្រាប់តែ នួន ជា នោះដែរទេ?

[១៤:៤៣:៣២]

**ឆ៖** ដើម្បីឱ្យបានច្បាស់ ខ្ញុំបាទស្នើសុំលោកមេធាវីបង្ហាញនូវឯកសារហ្នឹងតែម្តង ដើម្បីខ្ញុំបានដឹង ថាតើឯកសារហ្នឹងយ៉ាងម៉េច? ហើយឯកសារមួយណាដែលលោកមេធាវីនិយាយសំដៅដល់បាទ។ សូមអរគុណ។

**ស៖** ខ្ញុំគិតថា ខ្ញុំមិនអាចធ្វើការជាមួយនឹង ឌី.ស៊ី.ខេម បានទេ។ ខ្ញុំមិនអាច ខ្ញុំគ្រាន់តែសួរតែប៉ុណ្ណឹង លោក-- គ្រាន់តែសួរថាតើលោកអាចបញ្ជាក់បានថាមានឯកសារសម្រាប់ នួន ជា ដែរឬអត់?

**ឆ៖** ខ្ញុំបានជម្រាបលោកមេធាវីរួចហើយ ថានៅពេលដែលយើងទទួលបានឯកសារ យើងបានអាន យើងបានពិនិត្យមើល យើងបានធ្វើការចុះលេខ ធ្វើការចងក្រងនេះ គឺតាមការយល់ដឹង ការធ្លាប់បានឃើញរបស់ខ្ញុំ គឺថានៅលើឯកសារមានឯកសារខ្លះមានដាក់ឈ្មោះ អ៊ំ នួន មានឯកសារខ្លះអត់មាន

ទេ។ ជាក់ស្ដែង ដូចជាឯកសារដែលបង្ហាញអំពីតេឡេក្រាម ទូរលេខ ដែលមានឃើញដាក់ថាចម្លងជូន អ៊ំ នួន។ នេះជាអ្វីដែលខ្ញុំបាន ធ្លាប់បានឃើញ និងបានធ្លាប់បានឃើញនិងបានពិនិត្យ នៅពេលដែលទទួលបានឯកសារ។

[១៤:៤៥:០៧]

**ស៖** លោកនៅតែមិនទាន់ឆ្លើយសំណួរខ្ញុំនៅឡើយ។ ខ្ញុំសូមបន្តទៅទៀត ទាក់ទងទៅនឹងនីតិវិធីរបស់ ឌី.ស៊ី.ខេម ដោយសារតែពេលវេលានៅសល់តិចតួច។ ដូច្នេះខ្ញុំចៀសវាងមិនលើកឡើងអំពីចម្លើយរបស់លោក យុ ឆាំង ទេ។ ប៉ុន្តែលោកបានលើកឡើងថា នៅពេលឯកសារចូលមកដល់ ឌី.ស៊ី.ខេម គឺថាមានការពិនិត្យល្អិតល្អន់ទៅលើឯកសារនោះ គឺទីមួយពិនិត្យ ថាតើឯកសារនីមួយៗដែលចូលមកមជ្ឈមណ្ឌល លោកពិនិត្យ មានពិនិត្យឯកសារនីមួយៗដែលចូលមកមជ្ឈមណ្ឌលឯកសារកម្ពុជាទេ?

**ឆ៖** ជាការត្រឹមត្រូវគឺខ្ញុំបានពិនិត្យមើលឯកសារ ដែលទទួលបានមកពីប្រភពផ្សេងៗ ហើយយើងពិនិត្យនេះ គឺដើម្បីបែងចែកឯកសារឲ្យទៅត្រូវទៅតាមប្រភេទនៃឯកសារ ដើម្បីធ្វើការចងក្រងនិងការចុះលេខឲ្យបានត្រឹមត្រូវ។

**ស៖** ខ្ញុំមានសំណួរមួយទៀត ខ្ញុំសួរម្ដងទៀត នៅពេលដែលឯកសារនោះបានមកដល់មជ្ឈមណ្ឌលឯកសារកម្ពុជា ថាតើលោក ដារ៉ាពៅ លោកមានបានពិនិត្យពិច័យមើលឯកសារនីមួយៗនោះដែរឬទេ?

**ឆ៖** ជាអ្នកចងក្រង និងចុះលេខឯកសាររួមជាមួយសហការី គឺយើងបានពិនិត្យមើលឯកសារនោះបាទ។

[១៤:៤៧:០៨]

**ស៖** ចាប់ពីពេលណាមក ដែលលោកបានឃើញឯកសារបែបនេះចូលមកមជ្ឈមណ្ឌលឯកសារកម្ពុជា ឬបានឃើញចាប់តាំងពីពេលបង្កើតមជ្ឈមណ្ឌលឯកសារកម្ពុជាមក?

**ឆ៖** សូមលោកព្រះរាជអាជ្ញាមេត្តានិយាយដល់ឯកសារមួយណា ឬក៏ជាឯកសារទូទៅនៅមជ្ឈមណ្ឌលឯកសារកម្ពុជាទាំងមូល ឬក៏យ៉ាងដូចម្ដេច? បាទ សូមលោកមេធាវីមេត្តាបញ្ជាក់ឲ្យបានច្បាស់លាស់។

**ស៖** តើមានឯកសារណាមួយបានចូលមកដល់មជ្ឈមណ្ឌលឯកសារកម្ពុជាដែរឬទេ?

**ឆ៖** តាមការបកប្រែខ្ញុំបានឮថា តើមានឯកសារណាមួយចូលមកមជ្ឈមណ្ឌលឯកសារកម្ពុជា

តើនេះជាអ្វីដែលជាសំណួរដែលលោកមេធាវីសួរឬក៏យ៉ាងដូចម្ដេច ឬក៏បញ្ហាបកប្រែបាទ?

[១៤:៤៨:២៤]

**ស៖** ខ្ញុំមិនដឹងថា តើលោកយល់សំណួរខ្ញុំ ឬអត់ទេ? ខ្ញុំសូមសួរសាជាថ្មីឡើងវិញ ចាប់តាំងពីលោកបានធ្វើការនៅ ឌី.ស៊ី.ខេម នៅក្នុងឆ្នាំ៩៥ តើខ្លួនលោកផ្ទាល់បានពិនិត្យគ្រប់ឯកសារទាំងអស់ដែលចូលមក ឌី.ស៊ី.ខេម នោះដែរឬទេ?

**ឆ៖** បាទ សូមអរគុណចំពោះការបញ្ជាក់យ៉ាងច្បាស់ យ៉ាងដូច្នេះបាទ។ នៅក្នុងឯកសារដែលទទួលបានគឺខ្ញុំបានជម្រាបរួចហើយថា មានសមាជិកជាបុគ្គលិកនៅក្នុងក្រុមធ្វើឯកសារទទួលបន្ទុកការចងក្រងឯកសារនេះជាច្រើននាក់។ ហើយខ្ញុំជាអ្នកទទួលបន្ទុក ហើយខ្ញុំបានពិនិត្យមើលឯកសារទាំងអស់មុននឹងធ្វើការចុះលេខ ដើម្បីកុំឲ្យមានឯកសារ-- ដើម្បីធានាថាការចុះលេខហ្នឹង មិនឲ្យមានការស្ទួនលេខ ឬក៏បែងចែកឯកសារមិនត្រូវទៅតាមប្រភេទរបស់ឯកសារ។

[១៤:៤៩:៣០]

**ស៖** សូមអរគុណនេះជាចម្លើយច្បាស់លាស់ហើយ។ នៅពេលឯកសារណាមួយចូលមកគឺថាលោកបានរៀបរាប់ថា លោកមានដាក់បញ្ចូលនៅក្នុងទិន្នន័យ ដោយយកព័ត៌មានដាក់បញ្ចូលទៅក្នុងទិន្នន័យ ហើយទាក់ទងទៅនឹងបញ្ជីនៃការរក្សាទុកឯកសារចាប់តាំងពីមជ្ឈមណ្ឌលនេះកកើតមកថាតើមានការរៀបចំជាបញ្ជីចាត់ថ្នាក់ឯកសារដែរទេ?

**ឆ៖** បាទ គឺពិតជាមានបញ្ជីដែលមានធ្វើចំណាត់ថ្នាក់ឯកសារដូចខ្ញុំបានរៀបរាប់រួចមកហើយ។

**ស៖** ខ្ញុំគិតថា វាអាចមកពីបញ្ហាបកប្រែ។ ខ្ញុំសូមសួរថា តើលោកមានរៀបចំជាបញ្ជីនៃអ្នកដែលជាអ្នកកាន់កាប់ឯកសារនេះដែរឬទេ នៅក្នុងមុនពេលមជ្ឈមណ្ឌលឯកសារកម្ពុជាបានទទួលឯកសារទាំងនេះ? លោកមានរៀបបញ្ជីអ្នកកាន់កាប់ឯកសារនោះពីមុននោះដែរឬទេ?

**ឆ៖** បាទ គឺមាន។ គឺមានបុគ្គលិកដែលធ្វើការផ្នែកឯកសារនេះជាមួយនឹងខ្ញុំបាទ គឺមានបាទ។

[១៤:៥១:០៦]

**ស៖** ដូច្នេះគ្រប់ឯកសារទាំងអស់ គឺថាលោកមានបញ្ជីអ្នកដែលធ្លាប់បានកាន់កាប់ឯកសារនេះមុន ឌី.ស៊ី.ខេម ទទួលបាននូវឯកសារទាំងនេះ? មែនទេ?

**ឆ៖** បាទ សូមលោកមេធាវីមេត្តាបញ្ជាក់សំណួរនេះម្តងទៀត ដោយខ្ញុំស្តាប់មិនបានច្បាស់លាស់ សូមម្តងទៀត។ សូមអរគុណ។

**ស៖** តើខ្ញុំត្រឹមត្រូវដែរឬទេ ខ្ញុំឮក្នុងពេលឮចម្លើយរបស់លោកថាឯកសារទាំងអស់នៅ ឌី.ស៊ី.ខេម គឺលោកមានព័ត៌មានថា អ្នកណាជាអ្នកគ្រប់គ្រងឯកសារនេះនៅមុនពេលដែល ឌី.ស៊ី.ខេម បានទទួលឯកសារទាំងនេះ?

[១៤:៥២:០៥]

**ឆ៖** នៅមជ្ឈមណ្ឌលឯកសារកម្ពុជា លោកអាចរកបានថាតើ មាន-- នៅមជ្ឈមណ្ឌលឯកសារកម្ពុជា គឺបុគ្គលដែលធ្វើការងារគឺមានកុងត្រានៅក្នុងការងារ ហើយលោកអាចរកបាននូវអ្នកដែលធ្វើការងារផ្នែកឯកសារនេះ ហើយមានជាកុងត្រានៅក្នុងការងារតែម្តងបាទ។

**ស៖** តើលោកមានព័ត៌មានថា គ្រប់ឯកសារទាំងអស់ នៅពេលណាឯកសារនេះត្រូវបានរកឃើញបន្ទាប់ពីសម័យកម្ពុជាប្រជាធិបតេយ្យ បន្ទាប់ពី១៩៧៩? តើលោកមានបញ្ជីហ្នឹងទេ? ថាលោករកឃើញមកពីណាៗទេ?

**ឆ៖** បាទ សូមលោកមេធាវីមេត្តាបញ្ជាក់សំណួរម្តងទៀត ព្រោះតាមការបកប្រែដូចជាមិនច្បាស់លាស់។ សូមចោទសំណួរម្តងទៀត។ បាទ សូមអរគុណ។

**ស៖** ចំពោះឯកសារដែលចូលមក ឌី.ស៊ី.ខេម តើលោកមានព័ត៌មានអាចដឹងអំពីការរក្សាទុកឯកសារ ដែលអាចបង្ហាញជូនអ្នកដែលមកស្រាវជ្រាវឯកសារទាំងអស់នេះនៅ ឌី.ស៊ី.ខេម ដែរឬទេ ដើម្បីឲ្យអ្នកមកស្រាវជ្រាវនោះដឹងថា រកឃើញនៅពេលណា? រកពីណាមក? ហើយអ្នកណាគេជាអ្នករកឃើញ ក្រោយពីការដួលរលំទៅនៃរបបខ្មែរក្រហមនោះ?

[១៤:៥៣:៥៣]

**ឆ៖** បាទ នៅក្នុង-- ទាក់ទងនឹងបញ្ហានេះ គឺថានៅក្នុងបញ្ជី យើងហៅថាបញ្ជីឯកសារទៅចុះ ដែលយើងបានដាក់បង្ហោះនៅលើគេហទំព័រនេះ គឺលោកអាចមើលទៅលើឯកសារនីមួយៗ ថាតើឯកសារមានប្រភពមកពីណា ហើយបានប្រមូល និងចងក្រងចូលមកដល់មជ្ឈមណ្ឌលឯកសារកម្ពុជានៅពេលណា យើងមានព័ត៌មានទាំងអស់នេះ។

**លោក ហ្សាស្តើ ប៉ោ៖**

សូមអរគុណ។ ខ្ញុំបានឃើញដែរគេហទំព័រ ក៏ប៉ុន្តែគេហទំព័រមិនបានបង្ហាញអំពីព័ត៌មានពាក់ព័ន្ធទៅនឹងការរក្សាកាន់កាប់ឯកសារ អ្នកណាគេជាអ្នកកាន់កាប់ពីមុន? ហើយរកឃើញនៅពេលណា? នៅពេលដែលខ្ញុំមើលនាឡិកា ខ្ញុំដឹងថា ពេលវេលាជិតអស់ហើយ។ ក៏ប៉ុន្តែមុនពេលដែលលោកប្រធានឲ្យខ្ញុំ

អង្គុយ ខ្ញុំសូមលើកជាកំណត់សង្កេតឃើញទូទៅ ដែលថាសំណួរមួយចំនួនដែលបានសួរកាលពីម្សិលមិញដោយអង្គជំនុំជម្រះសាលាដំបូង និងខាងសហព្រះរាជអាជ្ញាសំណួរទាំងអស់នោះ គឺមិនឆ្លើយឲ្យបានច្បាស់លាស់ ឬក៏មិនឆ្លើយទាល់តែសោះដោយសាក្សី។ ប្រហែលជាដោយសារបញ្ហាបកប្រែ ឬក៏យ៉ាងណា? យើងពេញចិត្ត យើងចង់ឮចម្លើយទាំងអស់នោះ ក៏ប៉ុន្តែដោយសារតែយើងមិនអាចសួរជាន់គ្នាបាន។

[១៤:៥៥:២៤]

ដូច្នេះហើយយើងមិនអាចសួរឡើងវិញ ហើយយើងក៏មិនមានចម្លើយឆ្លើយតបទៅនឹងសំណួរទាំងឡាយ ដែលបានសួរកាលពីម្សិលមិញ។ ហើយសំណួរដែលបានសួរនៅក្នុងថ្ងៃនេះផងដែរ ដែលពាក់ព័ន្ធទៅនឹងចម្លើយរបស់លោក ផាំង យុ ដែលមកផ្តល់ជូនតុលាការ គឺលោក នួន ជា នៅសូមរក្សាសិទ្ធិមេធាវីលោក នួន ជា សូមរក្សាសិទ្ធិសួរសំណួរដែលពាក់ព័ន្ធទៅនឹងចម្លើយរបស់គាត់ទៅកាន់លោក ផាំង យុ។ ហើយសំណួរទាំងឡាយនោះ វាអាចពាក់ព័ន្ធទៅនឹងយថាភាព និងការរក្សាទុកឯកសារ និងរបៀបដែល ឌី.ស៊ី.ខេម បំពេញការងារ និងដំណើរការងារស្ថាប័នរបស់ខ្លួន។

[១៤:៥៦:១៣]

ខ្ញុំជឿថា ចម្លើយទាំងអស់ត្រូវតែឆ្លើយជូនទៅនឹងសំណួរទាំងឡាយដែលមានដោយ យុ ផាំង។ ហើយយើងគិតថា បុគ្គលដែលជាក់លាក់ គាត់គួរតែផ្តល់ចម្លើយទាំងអស់នេះ។ ចំណុចទីបី គឺសំណួរដែលខ្ញុំសួរទៅកាន់សាក្សី ដែលខ្ញុំសូមឲ្យបង្ហាញអំពីខ្សែចង្វាក់នៃការរក្សា កាន់កាប់ឯកសារ អ្នកកាន់កាប់ឯកសារ គឺយើងមិនអាចទទួលបានចម្លើយបាននោះទេ។ ដូច្នេះហើយយើងខ្ញុំសូមឲ្យអង្គជំនុំជម្រះបង្គាប់ទៅ ឌី.ស៊ី.ខេម ផ្តល់នូវបញ្ជីឯកសារដែលបានផ្តល់ជូនទៅកាន់ការិយាល័យសហព្រះរាជអាជ្ញា និងការិយាល័យសហចៅក្រមស៊ើបអង្កេត ដែលក្នុងនោះក៏រួមទាំងបញ្ជីអ្នកកាន់កាប់ឯកសារ មុនពេលដែលឯកសារនេះរកបាន។ ហើយបញ្ជីនោះ អាចបង្ហាញអំពីព័ត៌មានដែលថា ឯកសារនោះរកបានពីពេលណា? រកបានពីទីណា? ដោយនរណា?

[១៤:៥៧:២០]

ដូច្នេះខ្ញុំសូមធ្វើសំណើរបស់ខ្ញុំត្រឹមចំណុចទាំងអស់នេះ។ ដូច្នេះដោយសារតែពេលវេលាមិនទាន់លោកប្រធានមិនទាន់ឲ្យខ្ញុំឈប់នៅឡើយទេ។ ដូច្នេះហើយខ្ញុំអាចបន្តសំណួររបស់ខ្ញុំបន្ថែមទៀត រហូតដល់អង្គជំនុំជម្រះបង្គាប់ឲ្យខ្ញុំឈប់សួរ។

**ប្រធានអង្គជំនុំ៖**

ឥឡូវបង្គាប់តែម្តងឲ្យឈប់ទៅ ពីព្រោះលើសម៉ោងបី*មីនុត*ហើយ។ ឈប់ត្រឹមហ្នឹង! ហើយដោយសារពេលវេលាសមល្មមនឹងសម្រាកដែរហើយ។ អ៊ីចឹងអង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទី ចាប់ពីពេលនេះទៅរហូតដល់ម៉ោងបី ម្ភៃនាទីសូមអញ្ជើញចូលវិញ ដើម្បីបន្តការស្តាប់សក្ខីកម្មសាក្សីរូបនេះ ដោយក្រុមមេធាវីការពារក្តីលោក អៀង សារី។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១៤:៥៩ នាទី ដល់ម៉ោង ១៥:២១នាទី)*

[១៥:២១:១០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ។

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណ គឺយើងដឹងថាយើងមានសាក្សីនៅក្នុងតុលាការនេះ។ មុនពេលយើងឈប់សម្រាកមេធាវី នួន ជា គាត់បានដាក់ពាក្យសុំអំពីការសំណើសុំបញ្ជីស្តីពីអ្នកដែលគ្រប់គ្រងឯកសារនៅ ឌី.ស៊ី.ខេម។ ការិយាល័យសហព្រះរាជអាជ្ញា សូមជំទាស់ទៅលើសំណើសុំបែបនេះ។ យើងគិតថា យើងមិនចំណាយពេលវេលាពីរ ឬក៏ច្រើនជាងបីនាទីក្នុងការឆ្លើយតបទៅនឹងសំណើរបស់មេធាវីការពារក្តី នួន ជា នោះទេ។ ដូច្នេះហើយគឺយើងខ្ញុំអាចលើកនៅពេលនេះក៏បាន ឬក៏នៅពេលណាដែលមួយដែលអង្គជំនុំជម្រះគិតថាសមស្រប។

**ប្រធានអង្គជំនុំ៖**

អញ្ជើញ!

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណច្រើនលោកប្រធាន ខ្ញុំនឹងនិយាយដោយខ្លី។ ពាក្យសុំរបស់មេធាវីការពារក្តីគឺបានធ្វើឡើងដោយផ្អែកទៅលើការសន្មតដែលថាត្រូវតែផ្តល់បញ្ជីនៃការរក្សាទុកឯកសារគ្រប់ឯកសារទាំងអស់នៅក្នុងតុលាការ។ នេះមិនមែនជាច្បាប់ដែលមាននៅចំពោះតុលាការនេះ ឬក៏នៅក្នុងក្របខ័ណ្ឌអន្តរជាតិ

នោះទេ។ ខ្ញុំសូមយោងទៅលើយុត្តិសាស្ត្រក្នុងរយៈពេលពីរនាទីបន្តិចទៀតនេះ។

លោកចៅក្រមបាននិយាយនៅក្នុងសំណុំរឿង០០១ រួចមកហើយនៅក្នុងកថាខណ្ឌទី៤១ និង៤២ ដែលក្នុងនោះ គឺឯកសារត្រូវតែបំពេញទៅតាមភាពជឿជាក់ និងបទដ្ឋានអប្បបរមានៃភាពទុកចិត្តបាននៃឯកសារ។ ចំណុចនេះ គឺមានសម្រេចនៅក្នុងឯកសារ E43/4 ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៩ អង្គជំនុំជម្រះបានបញ្ជាក់អំពីបទដ្ឋានអប្បបរមានៃភាពអាចទុកចិត្តបាននៃឯកសារ។ ហើយនៅក្នុងនោះ អង្គជំនុំជម្រះលើកឡើងថា ការពិនិត្យទៅលើយថាភាព និងការរក្សាទុកឯកសារដើម គឺវាទាមទារឲ្យធ្វើការផ្ទៀងផ្ទាត់។

[១៥:២៣:៥១]

ចំណុចនេះគឺសេចក្តីសម្រេចនោះ គឺវាស៊ីសង្វាក់គ្នាទៅនឹងយុត្តិសាស្ត្ររបស់តុលាការអន្តរជាតិដទៃទៀត នៅក្នុងរឿង *ហាជី ហាសាណូវិច* គឺរឿងក្តី IT01-47 គឺសេចក្តីសម្រេចចុះថ្ងៃទី២ ខែសីហា ឆ្នាំ២០០៤ នៅទីនោះ អង្គជំនុំជម្រះគិតថាឯកសារទទួលយកបាននៅពេលដែលមានការបង្ហាញជាបឋមថាវាអាចទុកចិត្តបាន។ នៅក្នុងសេចក្តីសម្រេចរឿងក្តី *ថាឌិក* លេខឯកសារ IT94-1-10 អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងផងដែរថា វិធីសាស្ត្រទៅលើឯកសារដែលបានលើកឡើងនៅក្នុងរឿងក្តីនោះ គឺមិនសមស្របនោះទេ សម្រាប់សាលាក្តីអន្តរជាតិដែលមានចៅក្រមវិជ្ជាជីវៈ។ ចំណុចនេះលើកឡើងនៅក្នុងកថាខណ្ឌ១៧។

[១៥:២៤:៥១]

នៅក្នុងរឿងក្តី *ឌីឡាលិក* ក្នុងសេចក្តីសម្រេចថ្ងៃទី១៩ ខែមករា ឆ្នាំ១៩៩៨ នៅត្រង់កថាខណ្ឌ២០ អង្គជំនុំជម្រះក៏បានបញ្ជាក់ច្បាស់ដូចគ្នាអំពីបទដ្ឋាននៃការពិនិត្យមើលជាបឋមតែប៉ុណ្ណោះ ដែលត្រូវពិនិត្យមើលទៅលើឯកសារ។ ត្រង់ចំណុចទាំងអស់នេះ *ប្លាសស្កិក* ដែលរឿងក្តីនៅចំពោះមុខ អាយ.ស៊ី.ធី.វ៉ាយ គឺ IT95/95 និង 14 សេចក្តីសម្រេចចុះនៅឆ្នាំ១៩៩៨ ត្រង់កថាខណ្ឌ១០ គឺមានលើកឡើងដូចគ្នា។ នៅក្នុងតុលាការ អាយ.ស៊ី.ធី.វ៉ាយ ដែលបានលើកឡើងអំពីខ្សែសង្វាក់នៃការរក្សាទុកឯកសាររឿងក្តី *ប្រលិក* IT03/68/T គឺជាសេចក្តីសម្រេចរបស់សាលាដំបូងនៅឆ្នាំ២០០៦ ដែលក្នុងនោះអង្គជំនុំជម្រះលើកឡើងអំពីចន្លោះប្រហោងនៅក្នុងការបង្ហាញភស្តុតាង។ ចំណុចនេះ គឺមាននៅក្នុងកថាខណ្ឌ២៨។

ជាសង្ខេបមក គឺយើងខ្ញុំសូមជំទាស់ទៅលើសំណើសុំរបស់លោកមេធាវី នួន ជា ដូចដែលមានភស្តុតាងនៅក្នុងសំណុំរឿង។ ហើយភស្តុតាងទាំងអស់នោះ គឺវាមានតម្រុយនៃការជឿទុកចិត្តបានរួច

ហើយ។ ដូច្នេះហើយវាមិនមានអ្វីដែលត្រូវឲ្យអង្គជំនុំជម្រះទាមទារបន្ថែមទៅលើការទទួលឯកសារនៅក្នុងក្របខ័ណ្ឌច្បាប់អន្តរជាតិ ឬក៏តុលាការអន្តរជាតិនោះទេ ជាពិសេសពាក់ព័ន្ធទៅនឹងការបង្កើត និងបង្ហាញនៅលើខ្សែសង្វាក់នៃការរក្សាទុកឯកសារទាំងអស់នោះ។ សូមអរគុណ។

[១៥:២៦:៣៩]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីការពារក្តី នួន ជា!

**លោក ហ្សាស្តេី ប៉ោ៖**

សូមអរគុណលោកប្រធាន ខ្ញុំនឹងនិយាយខ្លីជាងខាងសហព្រះរាជអាជ្ញាទៅទៀត។ ខ្ញុំគិតថា យើងបានលើកឡើងអំពីអង្គច្បាប់លើបញ្ហានេះកាលពីសប្តាហ៍មុន។ ជំហររបស់ភាគីនីមួយៗគឺច្បាស់លាស់ហើយ ខ្ញុំមិនលើកឡើងសាជាថ្មីទៀតនោះទេ។ ដូច្នេះ ជំហររបស់យើងនៅពេលនេះ គឺវាមានលក្ខណៈជាក់ស្តែងចំពោះចម្លើយរបស់សាក្សី ដែលបានលើកឡើងដោយសាក្សីរូបនេះនៅថ្ងៃម្សិលមិញ និងថ្ងៃនេះផងដែរ។ ការតាំងសំណួរទៅកាន់សាក្សីមានគោលបំណង ដើម្បីឲ្យបំភ្លឺទៅលើខ្សែសង្វាក់នៃការរក្សាទុកឯកសារដោយយើងត្រូវពិចារណាអំពីយថាភាព និងភាពទុកចិត្តបាននៃឯកសារដែលបានប្រមូលមកពី ឌី.ស៊ី.ខេម។ ជំហររបស់ខាងមេធាវីការពារក្តីគឺថា ការបញ្ជាក់បំភ្លឺទៅលើចំណុចនេះមិនបានឲ្យយើងឃើញនោះទេ។ ដូច្នេះមេធាវីការពារក្តីមិនអាចផ្ទៀងផ្ទាត់ថា ឯកសារមកពី ឌី.ស៊ី.ខេម នោះគឺវាអាចបំពេញទៅតាមលក្ខខណ្ឌអប្បបរមានៃភាពទុកចិត្តបាន និងយថាភាពទេនោះឡើយ។ ដូចដែលយើងបានលើកឡើងកាលពីសប្តាហ៍មុន ការស្តាប់លោក ឆាំង យុ អាចបំពេញទៅលើចន្លោះប្រហោងនេះបាន តាមការយល់ដឹងរបស់យើង។

[១៥:២៨:០៧]

ក្រោយពីដែលយើងស្តាប់សក្ខីកម្ម ឆាំង យុ គឺយើងនឹងដឹង។ ក៏ប៉ុន្តែនៅពេលនេះ នៅពេលដែលយើងស្តាប់សក្ខីកម្មមួយនេះរួចមកហើយ យើងនៅតែមិនច្បាស់លាស់ទៅលើប្រភព និងភាពទុកចិត្តបាននៃឯកសារ។ យើងគិតថា សាក្សីនេះគួរតែឆ្លើយបំភ្លឺឲ្យយើងឲ្យបានច្បាស់លាស់កាលពីម្សិលមិញ និងថ្ងៃនេះ។ ជំហររបស់លោក នួន ជា គឺមេធាវីការពារក្តី នួន ជា គឺនៅតែយល់ឃើញថា ចម្លើយដែលបានផ្តល់ជូននេះ គឺមិនទាន់ច្បាស់លាស់នៅឡើយ មិនអាចបញ្ជាក់បំភ្លឺឲ្យយើងបានយល់ទាំងអស់គ្នានោះទេ។

ដូច្នេះហើយ ទើបខ្ញុំស្នើបញ្ជីនៃរៀបរាប់ឈ្មោះអ្នកដែលរក្សាទុកឯកសារ។ ឌី.ស៊ី.ខេម គឺគាត់

មានបញ្ជីទាំងអស់នេះ ហើយអាចឆែកឯកសារទាំងអស់តាមប្រព័ន្ធកុំព្យូទ័របាន។ ខ្ញុំព្យាយាមសួរបំភ្លឺទៅលើចំណុចនេះ ក៏ប៉ុន្តែសាក្សីគាត់ខកខានមិនបានផ្តល់ចម្លើយមកកាន់យើង។ ដូច្នេះហើយមេធាវី នួន ជា គឺនៅតែមិនច្បាស់លាស់ ថាតើ ឌី.ស៊ី.ខេម មានព័ត៌មានពាក់ព័ន្ធទៅនឹងខ្សែសង្វាក់នៃការរក្សាទុកឯកសារដែរឬទេ? ហើយរកឃើញដោយនរណា? រកពីទីណាមក? ដោយបុគ្គលណា? នៅពេលណា?

[១៥:២៩:២៤]

ដូច្នេះហើយមេធាវីការពារក្តី នួន ជា នៅតែបញ្ជាក់ថា យើងនៅតែមិនយល់ច្បាស់លាស់តាមចម្លើយពីសាក្សីមកពី ឌី.ស៊ី.ខេម ដដែល។

សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ ជាកិច្ចបន្ត អង្គជំនុំជម្រះសូមផ្តល់វេទិកាទៅក្រុមមេធាវីការពារក្តីលោក អៀង សារី ដើម្បីមានឱកាសនៅក្នុងការសួរដេញដោលចំពោះសាក្សីរូបនេះ។

សូមអញ្ជើញ!

**លោក ម៉ៃខល កាណាវាស៖**

ជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម សាធារណជនទាំងក្នុងនិងក្រៅបន្ទប់សវនាការ។ តាមការអនុវត្តនៅថ្នាក់ជាតិ គឺថាបញ្ហាទាំងអស់នេះ គឺត្រូវផ្តល់ជូនឲ្យសាក្សី ហើយខ្ញុំទទួលយកនូវការលើកលែង ខ្ញុំមិនប៉ានក្រោកឈរធ្វើអន្តរាគមន៍ ឬរំខានទេ ប៉ុន្តែនេះគឺជាឱកាសមួយដែលត្រូវទទួលបានចម្លើយ ហើយប៉ុន្តែក្នុងពេលខាងមុខ គឺថាទីមួយដើម្បីជម្រាបជូនទៅដល់មន្ត្រីច្បាប់ដែលថាភាគីគឺថាត្រូវយកបញ្ហាមកលើកសួរនៅចំពោះមុខអង្គជំនុំជម្រះចំពោះសាក្សីណាម្នាក់នោះ។ ដូច្នេះ ខ្ញុំសូមត្រូវការពេលវេលាដប់ប្រាំ ទៅម្ភៃនាទី។ យើងចង់-- ពេលយើងសាកសួរទៅ យើងចង់ដឹងថាតើអ្នកណាមិនអាចឆ្លើយនឹងសំណួរណាបាននោះ។

មុននឹងខ្ញុំចាប់ផ្តើមសំណួររបស់ខ្ញុំ ខ្ញុំសូមសួរឲ្យសាក្សីចងចាំឡើងវិញតាមការស្បថរបស់ខ្លួនថានូវអ្វីដែលគាត់អាចឆ្លើយបាន និងអ្វីដែលគាត់មិនអាចឆ្លើយបាននោះ។

[១៥:៣១:០៨]

ជំហររបស់យើងខ្ញុំ លោកប្រធាន គឺថាសាក្សីរូបនេះ គឺថា ដូចជាមិនមានភាពស្មោះត្រង់ពេញលេញទេ។ ដូច្នេះ ខ្ញុំសូមថា គាត់នៅតែអាចនៅឲ្យធ្វើការសម្បថបានដដែល ដើម្បីឲ្យឆ្លើយឲ្យបាន

ទៀងត្រង់ ឲ្យបានស្មោះត្រង់ ឲ្យបានពេញលេញនោះ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះមិនធ្វើតាមសំណូមពររបស់លោកមេធាវីទេ ពីព្រោះសាក្សីរូបនេះបានស្បថរួច ហើយមុននឹងចូលមកដល់សក្ខីកម្ម។ ដូច្នេះ សូមមេធាវីបន្តការតាំងសំណួរតាមបច្ចេកទេសនិងវិធីសាស្ត្រ និងកម្មវត្ថុនៃបញ្ហាដែលកំណត់ឲ្យសួរដេញដោលសាក្សីរូបនេះ។ ហើយសូមលោកមេធាវីចំណាយពេលវេលាដ៏មានប្រសិទ្ធភាពនូវពេលវេលាដែលចែកឲ្យមួយម៉ោងកន្លះនេះ។

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** ខ្ញុំសូមសួរឡើងវិញ ដោយសំណួរងាយៗទៅកាន់សាក្សី។ សំណួរគឺថាតើ ឌី.ស៊ី.ខេម មានឯកសារជាក់លាក់ណាមួយសម្រាប់ជនជាប់ចោទ នួន ជា ទេ? មានឈ្មោះបញ្ជីឯកសារណាសម្រាប់ នួន ជា ឬក៏អត់? គ្រាន់តែឆ្លើយថា មាន អត់មាន ឬក៏ខ្ញុំមិនដឹងទេ?

[១៥:៣២:៥៩]

**ឆ៖** យើងមានបញ្ជីឯកសារដែលធ្វើការចងក្រងឯកសារជាច្រើន ហើយឯកសារនោះត្រូវបានបែងចែកទៅតាមប្រភេទរបស់វា។ នេះគឺជាអ្វីដែលខ្ញុំអាចឆ្លើយបានទៅនឹងសំណួររបស់លោកមេធាវី។

**ស៖** ដូច្នេះប្រសិនជាខ្ញុំ តាមខ្ញុំយល់គឺថាមិនមានបញ្ជីឯកសារមួយដាក់ឈ្មោះ ឧទាហរណ៍ថា បញ្ជីឯកសារសម្រាប់ នួន ជា, អៀង សារី, ខៀវ សំផន នេះគឺជាចម្លើយរបស់លោក គឺថាមិនមានឈ្មោះឯកសារបែបនេះសម្រាប់ជនជាប់បែបនេះនៅ ឌី.ស៊ី.ខេម ទេ មែនទេ?

**ឆ៖** ជាការត្រឹមត្រូវ។

**ស៖** សូមអរគុណ។ ឥឡូវខ្ញុំសូមចូលទៅប្រវត្តិរបស់លោកបន្តិច។ តាមខ្ញុំ គឺថាលោកមានអាយុ២៣ឆ្នាំ នៅពេលលោកចាប់ផ្តើមធ្វើការជាមួយ ឌី.ស៊ី.ខេម តើត្រឹមត្រូវទេ?

**ឆ៖** ខ្ញុំចូលធ្វើការងារនៅមជ្ឈមណ្ឌលឯកសារកម្ពុជានៅឆ្នាំ១៩៩៥ ហើយពេលនោះ ខ្ញុំ--

**ស៖** តើនៅពេលនោះ លោកមានអាយុប៉ុន្មានដែរ?

[១៥:៣៤:១៩]

**ឆ៖** ឆ្នាំ៩៥ គឺខ្ញុំមានអាយុម្ភៃ--

**សៈ** ខ្ញុំអត់បានស្តាប់ចម្លើយឮទេ តើលោកចាប់ផ្តើមធ្វើការជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជានៅពេលលោកមានអាយុប៉ុន្មាន? គឺគិតមើល លោកកើតនៅក្នុងឆ្នាំ១៩៧០។

**ធៈ** ខ្ញុំបាទធ្វើការព្យាយាមដកនូវឆ្នាំ ដែលក្នុងឆ្នាំ ខ្ញុំមានអាយុ៤០ឆ្នាំ ហើយឆ្នាំនេះគឺឆ្នាំ២០១២ យើងដក ដកទៅថាតើនៅក្នុងឆ្នាំ១៩៩៥ នេះដែលខ្ញុំចូលធ្វើការងារមានអាយុប៉ុន្មាន។

**សៈ** បើអ៊ីចឹងខ្ញុំសូមសួរឲ្យចំៗ ខ្ញុំនឹងធ្វើគណិតវិទ្យាជូនលោក គឺថាលោកកើតនៅ៧៤ ដកពី១៧មក ពេលនោះយើងនឹងឃើញតួរលេខហើយ លោកអាយុ ២៣ នេះតាមខ្ញុំដកឃើញថា អាយុលោកមានអាយុ២៣ នៅពេលនោះ ត្រឹមត្រូវទេ?

**សៈ** បើសិនជាលោកជួយធ្វើគណិតវិទ្យាឲ្យខ្ញុំយ៉ាងដូច្នេះ គឺថាជាការល្អប្រសើរម្យ៉ាងដែរ ហើយខ្ញុំគិតជាការត្រឹមត្រូវតាមដែលលោកដកលេខ។

**សៈ** លោកបញ្ជាក់ពីម្សិលមិញថា លោកបានចូលទៅរៀននៅសាកលវិទ្យាល័យនៅសហរដ្ឋអាមេរិកនៅពេលដែលលោកទៅរៀននៅសហរដ្ឋអាមេរិកមែនទេលោកពេលនោះ?

**ធៈ** ខ្ញុំបានទៅរៀននៅសហរដ្ឋអាមេរិកនៅសាកលវិទ្យាល័យ *ណូត្រឺដេម* ។

**សៈ** តើនៅពេលនោះលោកបានទទួលសញ្ញាប័ត្របរិញ្ញាប័ត្រជាន់ខ្ពស់មែនទេ?

[១៥:៣៦:៣២]

**ធៈ** ត្រឹមត្រូវ។

**សៈ** តើនៅពេលដែលលោកទៅរៀនសាលានោះ លោកទទួលអាហារូបករណ៍ហ្វូលប្រាយស៍ ឬក៏អត់ទេនៅពេលនោះ?

**ធៈ** គឺជាអាហារូបករណ៍ដែលផ្តល់ដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សរបស់សាកលវិទ្យាល័យ *ណូត្រឺដេម*។

**សៈ** ហើយថ្នាក់ដែលលោករៀននោះ គឺលោករៀនជាភាសាអង់គ្លេស មិនមែនជាភាសាខ្មែរទេមែនទេ?

**ធៈ** ជាការត្រឹមត្រូវបាទ។

**សៈ** ជាការ និយាយឲ្យចំទៅលោកអាចនិយាយអាចសរសេរ អាចស្តាប់ភាសាអង់គ្លេសបានមែនទេ?

**ធៈ** ជាការត្រឹមត្រូវបាទ។

[១៥:៣៧:៣៤]

**ស៖** នៅពេលដែលសហការីរបស់ខ្ញុំ មេធាវីការពារក្ដីសួរសម្រាប់ក្រុម នួន ជា សួរទៅគឺថា លោកយល់ភាសារបស់គាត់ជាភាសាអង់គ្លេស ឬក៏អត់?

**ឆ៖** នៅពេលដែលស្ដាប់ការសួរ គឺខ្ញុំស្ដាប់នៅក្នុង*អៀរហ្វូន*នេះជាភាសាខ្មែរ ដើម្បី-- ភាសាខ្មែរជាភាសាដើមកំណើតរបស់ខ្ញុំដែលខ្ញុំអាចជឿជាក់បានទាំងស្រុកជាជាងការជឿជាភាសាអង់គ្លេស។

**ស៖** លោកមានន័យថា លោកមិនអាចស្ដាប់ឮសំណួរទាំងអស់ គ្រប់សំណួរទាំងអស់ជាភាសាអង់គ្លេសមែនទេ?

**ឆ៖** ឮជាភាសាអង់គ្លេស តែមិនពេញលេញទេ ដោយសារតែយើងដាក់ក្នុងត្រចៀករបស់យើងនេះ ស្ដាប់ជាភាសាខ្មែរ។

**ស៖** មុនពេលលោកមកទីនេះ តើលោកមានបានជួបជាមួយមេធាវីសម្រាប់ នៅ ឌី.ស៊ី.ខេម សម្រាប់ឲ្យលោកផ្ដល់ចម្លើយមក-- នៅក្នុងតុលាការនេះដែរឬទេ?

**ឆ៖** នៅមជ្ឈមណ្ឌលឯកសារកម្ពុជាអត់មានមេធាវីទេបាទ។

**ស៖** តើមិនមានទីប្រឹក្សាច្បាប់នៅទីនោះទេ ឬ?

**ឆ៖** រហូតមកដល់ពេលនេះគឺអត់មានទីប្រឹក្សាច្បាប់ទេ ហើយខ្ញុំអត់បានជួបទីប្រឹក្សាច្បាប់ទេ។

**ស៖** តើមិនមានមេធាវីបរទេសណាមួយធ្វើការនៅ ឌី.ស៊ី.ខេម ទេឬ? ពីព្រោះតាមធម្មតាមានការដកស្រង់សម្ដីនៅក្នុងកាសែត ខេមបូឌា ដេលី ឬ ភ្នំពេញប៉ុស្ដិ៍ក៏មាន។

**ឆ៖** ពាក្យថា មេធាវីគឺសំដៅដូចមេធាវី ដូចលោកអ៊ីចឹង។ នៅមជ្ឈមណ្ឌលឯកសារកម្ពុជាមិនមានមេធាវីដូចលោកឈរនៅទីនេះទេ។

[១៥:៣៩:៣៤]

**ស៖** តើលោកមានពិគ្រោះជាមួយនរណាម្នាក់មុននឹងលោកមកផ្ដល់សក្ខីកម្មកាលពីម្សិលមិញហើយនិងថ្ងៃនេះដែរឬទេ? មានបានពិគ្រោះឬក៏អត់? ឬក៏មិនមានទេ? ឬក៏មិនអាចចាំទេ? សូមលោកឆ្លើយ?

**ឆ៖** ខ្ញុំមិនបានពិគ្រោះយោបល់ទេបាទ។

**ស៖** តើលោកមានពិគ្រោះយោបល់ ឬក៏ពិនិត្យមើលឯកសារណាឡើងវិញ ដើម្បីរៀបចំខ្លួនរបស់ខ្លួនមកផ្ដល់សក្ខីកម្មនៅកាលពីម្សិលមិញ និងថ្ងៃនេះដែរឬទេ?

**ឆ៖** អត់មានទេ។

**ស៖** តើលោកមានអនុវត្តទៅតាមនីតិវិធីកាលពីសប្តាហ៍មុនដែរឬទេ ទាក់ទងទៅនឹងភាពអាចទទួលយកបាននៃភស្តុតាងនោះ?

**ឆ៖** អត់មានទេបាទ នៅពេលនោះខ្ញុំបានធ្វើដំណើរទៅកាន់ស្រុកអន្លង់វែង។

**ស៖** ខ្ញុំបានដឹងថា លោកមិនមានការសន្ទនាគ្នាជាមួយនាយក ឌី.ស៊ី.ខេម នូវអ្វីដែលបានកើតឡើងនៅទីនេះកាលពីសប្តាហ៍មុន ក៏ដូចជាសក្ខីកម្មនៅក្នុងសប្តាហ៍មុន។ ប៉ុន្តែនៅក្នុងសារព័ត៌មាន គឺបានលើកឡើងពីអ្វីដែលលោកបានលើកឡើងកាលពីសប្តាហ៍មុននោះ?

**ឆ៖** សូមលោកមេធាវីជួយបង្ហាញអំពីសារព័ត៌មានមួយណា ដែលសរសេរយ៉ាងដូច្នេះ? ហើយ --

**ស៖** តើមានការសន្ទនាគ្នាជាមួយនាយក ឌី.ស៊ី.ខេម ទាក់ទងនឹងសក្ខីកម្មដែលត្រូវផ្តល់ថ្ងៃនេះ និងកាលពីម្សិលមិញដែរឬទេ? សូមឆ្លើយថា បាទ ទេ ឬក៏ខ្ញុំមិនអាចចាំបានទេ។

**ឆ៖** អត់មានទេបាទ។

**ស៖** កាលពីមុននេះ គឺថាមានការសួរថា តើមានអ្នកណាម្នាក់មកពីការិយាល័យសហព្រះរាជអាជ្ញាបានទៅកាន់ ឌី.ស៊ី.ខេម ទៅពិគ្រោះជាមួយ ឌី.ស៊ី.ខេម លោកបានឆ្លើយថា អត់មានទេ។ តើខ្ញុំស្តាប់ថា លោកឆ្លើយថា មិនមានការជួបគ្នាបែបនេះ ត្រឹមត្រូវទេ?

[១៥:៤១:៥៣]

**ឆ៖** ខ្ញុំបានឆ្លើយថា គឺក្រុមសហព្រះរាជអាជ្ញាមិនជួបខ្ញុំផ្ទាល់នៅ ឬការប្រជុំជាមួយខ្ញុំផ្ទាល់នៅមជ្ឈមណ្ឌលឯកសារកម្ពុជាទេ។ គឺសំដៅទៅពាក្យថា ការប្រជុំពិភាក្សា។

**ស៖** ខ្ញុំបានកត់សម្គាល់ឃើញថា មានទីប្រឹក្សាច្បាប់ម្នាក់ ឬក៏ថាជាអ្នកប្រឹក្សាណាម្នាក់ មានគឺឈ្មោះ ស៊្មីវ ហេដឌ័រ តើធ្លាប់ធ្វើនៅទីនោះ តើជាទីប្រឹក្សាម្នាក់សម្រាប់ ឌី.ស៊ី.ខេម ត្រឹមត្រូវទេ?

**ឆ៖** ជាការត្រឹមត្រូវ។ មានឈ្មោះនេះនៅក្នុងអង្គការលេខថែមទៀតផង។

[១៥:៤២:៤០]

**ស៖** ខ្ញុំដឹងថា គាត់មានឈ្មោះនៅក្នុងបញ្ជីបុគ្គលិក គឺថាគាត់ជាទីប្រឹក្សា។ គឺថាមានបញ្ជីមួយមានអង្គការលេខមួយដាក់ថា គាត់ជាទីប្រឹក្សា។ ត្រឹមត្រូវទេ?

**ឆ៖** ជាការត្រឹមត្រូវ។

**សៈ** ខ្ញុំដឹងថា នៅពេលមួយនោះ គឺលោកដឹងថា ស៊្វីរ ហេងឆ័រ បានធ្វើការនៅការិយាល័យសហព្រះរាជអាជ្ញារៀបចំដីកាបញ្ជូនរឿងឲ្យស៊ើបសួរសម្រាប់ករណី០០២។ តើលោកដែលបានជួបជាមួយលោក ស៊្វីរ ហេងឆ័រ នៅពេលដែលលោក ស៊្វីរ ហេងឆ័រ ហ្នឹង គាត់មកបម្រើការងារនៅការិយាល័យសហព្រះរាជអាជ្ញានោះ?

[១៥:៤៣:២៣]

**ឆៈ** ខ្ញុំបានជួបលោក ស៊្វីរ ហេងឆ័រ នៅពេលដែលលោកមកធ្វើការស្កេនឯកសារនៅមជ្ឈ-មណ្ឌលឯកសារកម្ពុជា។

**សៈ** ហើយនៅពេលនោះ គឺថាគាត់ជាតំណាងឲ្យការិយាល័យសហព្រះរាជអាជ្ញាមែនទេ?

**ឆៈ** ជាការត្រឹមត្រូវ ដោយលោកបានបង្ហាញអំពីដីការបស់សហចៅក្រមស៊ើបអង្កេត។

**សៈ** ការពិតជាសំណួរបន្ទាប់របស់ខ្ញុំទេ។ ហើយបន្ទាប់មក គឺថាគាត់ចាកចេញពីការិយាល័យសហព្រះរាជអាជ្ញា ទៅបំពេញការងារនៅការិយាល័យសហចៅក្រមស៊ើបអង្កេត។ លោកបានជ្រាបពីរឿងហ្នឹងទេ? ដំបូងគាត់ធ្វើនៅការិយាល័យសហព្រះរាជអាជ្ញា ចេញនៅពេលកំពុងចេញដីកាបញ្ជូនរឿងឲ្យស៊ើបសួរ ហើយបន្ទាប់មកគាត់មកការិយាល័យសហព្រះរាជអាជ្ញា។ តើលោក (សូមអធ្យាស្រ័យ) មកការិយាល័យសហចៅក្រមស៊ើបអង្កេត។ លោកជ្រាបរឿងនេះទេ?

[១៥:៤៤:២២]

**ឆៈ** បាទ ខ្ញុំជ្រាប។

**សៈ** នៅពេលដែលគាត់ធ្វើការឲ្យការិយាល័យសហព្រះរាជអាជ្ញា តើលោកមានជួបគាត់ទេ នៅពេលនោះក្នុងនាមជាតំណាងឲ្យការិយាល័យសហព្រះរាជអាជ្ញានោះ?

**ឆៈ** ខ្ញុំអត់បានជួបគាត់ទេ។

**សៈ** ចាប់ពីពេលគាត់ ខ្ញុំចង់បញ្ជាក់ឲ្យច្បាស់នៅក្នុងអំឡុងពេលទាំងមូលដែលលោក ស៊្វីរ ហេងឆ័រ បម្រើការងារនៅការិយាល័យសហព្រះចៅក្រមស៊ើបអង្កេត តាមដែលខ្ញុំដឹងគឺថាលោកមិនបានជួបគាត់ទេ ក្នុងឋានៈគាត់ជាតំណាងរបស់សហចៅក្រមស៊ើបអង្កេត។ តើត្រឹមត្រូវទេ?

**ឆៈ** សូមបញ្ជាក់សំណួរម្តងទៀត ថានៅក្នុងការិយាល័យសហចៅក្រមស៊ើបអង្កេត ឬក៏ការិយាល័យសហព្រះរាជអាជ្ញា។ សូមមេត្តាបញ្ជាក់កន្លែងហ្នឹងម្តងទៀត។

**សៈ** គឺនៅការិយាល័យសហចៅក្រមស៊ើបអង្កេត។

**ឆ៖** បាទ ដូចខ្ញុំបានជម្រាបអ៊ីចឹង ខ្ញុំបានជួបលោក ស៊ីវ ហេងឆ័រ នៅពេលដែលលោកមកធ្វើការស្កេនឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជា។

[១៥:៤៥:៥៨]

**ស៖** ហើយនៅពេលដែលគាត់ទៅ ឌី.ស៊ី.ខេម តើគាត់-- តើលោកមានការជួប ធ្វើការសន្ទនាជាមួយគាត់ដែរទេ?

**ឆ៖** ខ្ញុំបានយកឯកសារឲ្យគាត់ស្កេន គាត់បានសួរប្រាប់បង្ហាញនូវបញ្ជីឯកសារដែលគាត់ចង់ស្កេន ហើយខ្ញុំបានយកឯកសារនោះឲ្យធ្វើការស្កេន។

**ស៖** ប៉ុន្តែ ដូច្នេះមានន័យថាលោកមិនមានការនិយាយជាមួយគាត់ ឬក៏សន្ទនាជាមួយគាត់ពាក់ព័ន្ធទៅនឹងខ្លឹមសារនៃឯកសារណាមួយទេឬ?

**ឆ៖** បាទ មិនមានទេ គឺគ្រាន់តែយកឯកសារមកឲ្យលោក ស៊ីវ ហេងឆ័រ ធ្វើការស្កេន។

**ស៖** ត្រឡប់ទៅប្រវត្តិរបស់លោកវិញបន្តិច ទាក់ទងសំណួរមុនរបស់ខ្ញុំនោះ លោកមិនមែនជាអ្នកប្រវត្តិសាស្ត្រដែលទទួលការរៀនសូត្រឲ្យក្លាយទៅជាអ្នកប្រវត្តិសាស្ត្រទេ មែនទេ?

**ឆ៖** បាទ ជាការត្រឹមត្រូវ។

**ស៖** តើលោកបានគិតថា លោកជា គិតខ្លួនឯងថាលោកជាអ្នកវិភាគព័ត៌មានដែរឬទេ?

**ឆ៖** ខ្ញុំបានអានឯកសារជាច្រើន ហើយខ្ញុំបានគិតអំពីឯកសារហ្នឹងដែរ។

[១៥:៤៧:៣២]

**ស៖** ទាក់ទងទៅនឹងប្រវត្តិសិក្សារបស់លោក គឺលោកសិក្សាច្បាប់ ត្រឹមត្រូវទេ?

**ឆ៖** បាទ ជាការត្រឹមត្រូវ។

**ស៖** តើលោកអាចរៀបរាប់បន្តិចបានទេ តើលោកមានការទទួលការបណ្តុះបណ្តាលជាក់លាក់ណាមួយ ដែលទាក់ទងទៅនឹងការវិភាគឯកសារក្នុងការពិចារណាថា ឯកសារនេះមានយថាភាព ឬក៏យ៉ាងណានោះ?

**ឆ៖** ទាក់ទងទៅនឹងការបណ្តុះបណ្តាលឲ្យវិភាគទៅលើឯកសារនោះ គឺមិនមានទេបាទ។

**ស៖** ខ្ញុំកត់សម្គាល់ឃើញថា មួយថ្ងៃជាងមុននេះ គឺថា ឌី.ស៊ី.ខេម ជាពិសេសរូបលោកតែម្តងមិនបានវិភាគឯកសារទេ តើមែនទេ?

**ឆ៖** ជាការត្រឹមត្រូវ ខ្ញុំបាននិយាយយ៉ាងដូច្នេះមែន។

**ស៖** លោកអាចពន្យល់ខ្ញុំបានទេ ថាតើពាក្យថា “វិភាគ” មានន័យថាម៉េច លោកអាចពន្យល់ពាក្យ “វិភាគ”បានទេ?

**ឆ៖** ចំពោះការវិភាគ សម្រាប់ខ្ញុំបាទផ្ទាល់ដែលយល់ឃើញ គឺថាលុះត្រាតែយើងធ្វើការវិភាគទៅលើឯកសារ ថាតើឯកសារនោះមានដាក់កំហុស ឬក៏មានភាពចោទប្រកាន់ ឬក៏យ៉ាងម៉េច អានោះទើប ខ្ញុំយល់ថា នេះជាការវិភាគ។

**ស៖** អ្វីដែលលោកជម្រាបយើងនោះ គឺថាលោកមិនអានឯកសារដើម្បីថា តើមានឯកសារណាអាចជាឯកសារដាក់បន្ទុក ឬក៏ឯកសារហ្នឹងជាឯកសារដោះបន្ទុកនោះទេ មែនទេ?

**ឆ៖** ជាការអានឯកសារ គឺដើម្បីឲ្យបានដឹងថាតើឯកសារនោះ វាជាឯកសារដើម ឬក៏ជាឯកសារថតចម្លង ឬក៏ជាឯកសារនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ឬក៏ឯកសារទាក់ទងទៅនឹងរបបកម្ពុជាប្រជាធិបតេយ្យ។

[១៥:៥០:០៣]

**ស៖** ខ្ញុំមិននិយាយទៅលើអ្នកដទៃទេ គឺខ្ញុំផ្តោតតែលើរូបលោកម្នាក់ទេ។ ក្នុងការអានឯកសារ គឺលោកបានយល់ស្របថា គឺត្រូវមានការវិភាគណាមួយ ដើម្បីពិចារណាថា តើឯកសារនោះវាកើតឡើងនៅក្នុងសម័យនោះដើម្បីទទួលយកមកដាក់នៅក្នុង ឌី.ស៊ី.ខេម។ តើត្រឹមត្រូវទេ?

**ឆ៖** បាទ នេះជាការវាយតម្លៃមួយឲ្យដឹងថា តើឯកសារហ្នឹងយើងអាចប្រមូលមកត្រូវទៅតាមអាណត្តិរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែរឬក៏យ៉ាងណា?

**ស៖** ឥឡូវខ្ញុំកត់សម្គាល់ឃើញថា លោកប្រើពាក្យខុសគ្នា លោកប្រើពាក្យ “វាយតម្លៃ” តាមដែលខ្ញុំយល់លោកនោះ គឺពាក្យ "វាយតម្លៃ" ខុសពីពាក្យថា “វិភាគ”។ នេះតាមរបៀបដែលលោកគិតៗថា “ការវាយតម្លៃ” ហៅ *“អាសេស្សមិន”* នេះ និង “ការវិភាគ-- *អេណាលីស”* នេះខុសគ្នា។ តើលោកយល់ថាអ៊ីចឹងមែនទេ?

**ឆ៖** ជាការត្រឹមត្រូវ ខ្ញុំយល់ឃើញថាវាខុសគ្នា។

**ស៖** ខ្ញុំកត់សម្គាល់ឃើញថា ឌី.ស៊ី.ខេម បានចេញនូវអត្ថបទមួយចំនួន ទស្សនាវដ្តី ហើយតាមដែលខ្ញុំដឹងផ្ទាល់ គឺលោកខ្លួនផ្ទាល់ក៏បានចេញផ្សាយនូវទស្សនាវដ្តីនេះផងដែរ។ តើត្រឹមត្រូវទេ?

**ឆ៖** ខ្ញុំបានសរសេរអត្ថបទនៅក្នុងទស្សនាវដ្តីស្វែងរកការពិតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាផងដែរ។

[១៥:៥១:៣៩]

**ស៖** លោកមានចេញសរសេរអត្ថបទមួយចំនួនផ្សព្វផ្សាយនៅក្នុងទស្សនាវដ្ដីនោះត្រឹមត្រូវទេ?

**ឆ៖** បាទ ជាការត្រឹមត្រូវ។

**ស៖** ហើយអត្ថបទមួយចំនួនដែលលោកសរសេរនោះ គឺយោងទៅលើឯកសារដែលលោកបានអានរួចហើយ។ តើត្រឹមត្រូវទេ?

**ឆ៖** អត្ថបទខ្លះ គឺខ្ញុំបានសរសេរតាមការដែលយល់ដឹងរបស់ខ្ញុំ។

**ស៖** នៅពេលដែលលោកតាមការយល់ដឹងមានន័យថា លោកអានឯកសារ លោកពិចារណាថាឯកសារនោះវាចង់និយាយអំពីអ្វី? ហើយបន្ទាប់មកលោកធ្វើសេចក្ដីសន្និដ្ឋាន ហើយបន្ទាប់មកលោកសរសេរអត្ថបទចុះផ្សាយនៅក្នុងទស្សនាវដ្ដីនោះ។ តើលោកអាចត្រឹមត្រូវទេអ៊ីចឹង?

**ឆ៖** បាទ នេះជាការសរសេរអត្ថបទដែលមាន ដែលខ្ញុំបានធ្លាប់បានសរសេរ ហើយជាទម្រង់នៃការសរសេរអត្ថបទនេះតែម្ដង។

[១៥:៥២:៥១]

**ស៖** ឥឡូវខ្ញុំសូមសាកសួរលោកបន្ថែមទៅទៀត តើលោកយោងទៅលើប្រភពទីពីរ ប្រភពព័ត៌មានទីពីរ ឬក៏អត់ទាក់ទងទៅនឹងអ្នកប្រវត្តិសាស្ត្រ ឬអ្នកវិភាគនោះ? ឬក៏លោកចូលទៅមើលឯកសារដើមតែម្ដង វិភាគឯកសារហ្នឹងហើយ បន្ទាប់មកពិនិត្យទៅលើប្រភពទីពីរ ហើយបន្ទាប់មកទើបលោកចាប់ផ្ដើមសរសេរអត្ថបទរបស់លោក លោកធ្វើរបៀបនេះដែរឬទេ?

**ឆ៖** នេះជាការ-- ជាសំណួរដែលសួរដោយរៀងទូលំទូលាយបន្តិចដែលមិនបានយោងទៅលើសំណេរណាមួយរបស់ខ្ញុំជាក់លាក់ដែលខ្ញុំអាចមើលឃើញខ្លួនឯងបាន។

**ស៖** តើចំណុចត្រង់ណានៅក្នុងសំណួររបស់ខ្ញុំដែលខ្ញុំ លោកមិនយល់ ដើម្បីខ្ញុំឱ្យរៀបសំណួរឡើងវិញ។ ខ្ញុំនិយាយអំពីវិធីសាស្ត្រ អំពីយុទ្ធសាស្ត្ររបស់លោក ជាពិសេសទាក់ទងទៅនឹងអត្ថបទរបស់លោកតែម្ដង។ តើផ្នែកណានៃសំណួររបស់ខ្ញុំដែលលោកមិនយល់ ដែលលោកចង់ឱ្យខ្ញុំលើកឡើងម្ដងទៀតនោះ?

[១៥:៥៤:០៥]

**ឆ៖** ជាពិសេសគឺថានៅក្នុងការសរសេរអត្ថបទ។ ធម្មតានៅក្នុងការសរសេរអត្ថបទយើងមានវិធីសាស្ត្រផ្សេងៗនៅក្នុងការសរសេរ នៅក្នុងការយកព័ត៌មានសរសេរនៅក្នុងអត្ថបទ។ ដូច្នេះបើសិនជា

ខ្ញុំបានឃើញអត្ថបទរបស់ខ្ញុំសរសេរ នោះខ្ញុំអាចបញ្ជាក់ជូនប្រាប់លោកមេធាវីបាន។

**ស៖** ជាការល្អហើយលោកបានបញ្ជាក់ សូមខ្ញុំបញ្ជាក់ខ្ញុំផង ក្រែងលោខ្ញុំខុស ខ្ញុំមិនអាចនិយាយនូវអ្វីដែលចេញពីមាត់លោកទាំងអស់បានទេ។ ពីម្សិលមិញគឺឯកសារទាំងអស់នៅ ឌី.ស៊ី.ខេម គឺជាឯកសារដែលមានយថាភាពទាំងអស់។ ខ្ញុំប្រហែលជាអាចខុស បើខុស ចាំប្រាប់ខ្ញុំផង។ ជំហររបស់លោកបានលើកឡើងថា ឯកសារទាំងអស់នៅ ឌី.ស៊ី.ខេម គឺជាឯកសារដែលមានយថាភាព។ តើនេះ គឺជាសក្ខីកម្មដែលលោកបានឆ្លើយថាបែបនេះមែនទេ?

[១៥:៥៥:០១]

**ឆ៖** ជាការត្រឹមត្រូវ។

**ស៖** តើនេះជាការវាយតម្លៃ ឬខ្ញុំប្រើពាក្យរបស់លោក តើនេះជាការវាយតម្លៃដែលលោកធ្វើឡើង ឬក៏ជាការវិភាគរបស់អ្នកដទៃធ្វើឡើង។ នេះគឺជាចំណុចខុសគ្នាពីរ សូមលោកបញ្ជាក់។

**ឆ៖** បាទជាការធ្វើការវាយតម្លៃឲ្យដឹងថាតើឯកសារហ្នឹងមានយថាភាព ឬក៏យ៉ាងណា គឺយើងបានធ្វើយ៉ាងដូច្នេះ។

**ស៖** លោក នៅពេលលោកនិយាយថា "យើង" លោកនិយាយជាសមូហភាព គឺមានន័យថាតំណាងឲ្យ ឌី.ស៊ី.ខេម តែម្តង ឬក៏លោកនិយាយសម្រាប់លោករូបលោក និងអ្នកណាផ្សេងទៀតនោះ? តើពាក្យថា "យើង" នេះ សំដៅទៅលើអ្នកណា?

**ឆ៖** បាទព្រោះនៅក្នុងការចងក្រងឯកសារ គឺមានបុគ្គលិកផ្សេងទៀត ចូលរួមជា*ធីម* ជាក្រុម។

[១៥:៥៦:១១]

**ស៖** ប៉ុន្តែលោកបានស្បថហើយ ហើយខ្ញុំជាអ្នកសួរ លោកផ្តល់ចម្លើយមកឲ្យយើងខ្ញុំ។ អ៊ីចឹងលោកក្នុងនាមជាសក្សីដែលបានស្បថហើយ គឺថាលោកបានប្រាប់យើងខ្ញុំថា ឯកសារទាំងអស់នោះ គឺមានយថាភាពតាមការយល់ដឹងរបស់លោក។

**ឆ៖** ជាការពិត គឺតាមយល់ដឹងរបស់ខ្ញុំ។

**ស៖** តើលោកអាចចែករំលែកជាមួយយើងខ្ញុំបន្តិចទៀតបានទេ អំពីវិធីសាស្ត្រដែលលោកប្រើប្រាស់ផ្ទាល់ខ្លួន ឬក៏អ្នកដទៃទៀតក៏ថាបានដែរ ជាពិសេសទាក់ទងទៅនឹងឯកសារជាក់លាក់ណាមួយដែលថាឯកសារនោះមានយថាភាពនោះ?

**ឆ៖** បាទ ដូចជាខ្ញុំបានទៅធ្វើការប្រមូលឯកសារនៅបណ្ណសារដ្ឋានជាតិ។ នៅក្នុងនេះ គឺខ្ញុំបាន

អានមើលទៅលើឯកសារទាំងអស់នោះ ហើយចុងក្រោយគឺខ្ញុំបានស្នើសុំធ្វើការថតចម្លងឯកសារនោះ មកពីបណ្ណសារដ្ឋានជាតិដោយមានអ្នកគ្រប់គ្រងឯកសារដើមនៅបណ្ណសារដ្ឋានជាតិតែម្តង។

[១៥:៥៧:៣២]

**ស៖** ខ្ញុំសូមថយក្រោយទៅវិញ ហើយខ្ញុំរៀបសំណួររបស់ខ្ញុំឡើងវិញ។ ខ្ញុំមិនចង់សួរថាលោកទទួលឯកសារមកពីណានោះទេ លើកលែងតែផ្នែកមួយនៃចម្លើយណាមួយ គឺថាលោកចេញមកពីបណ្ណសារជាតិ ទទួលបានពីបណ្ណសារជាតិ ហើយបណ្ណសារនោះ គឺថាបញ្ជាក់ថាឯកសារហ្នឹងមានយថាភាព ដោយសារវាមកពីបណ្ណសារជាតិ។ តើនេះជាចម្លើយរបស់លោកមែនទេ?

**ឆ៖** នេះជាការឧទាហរណ៍ដែលជម្រាបជូនលោកមេធាវីថា របៀបនៃការធ្វើយថាភាពនៃឯកសារមួយ ឬក៏ឯកសារមួយប្រភេទដែលខ្ញុំបានទទួលឯកសារនេះផ្ទាល់។ ដែលខ្ញុំបានទៅប្រមូលឯកសារនេះផ្ទាល់។

[១៥:៥៨:២៦]

**ស៖** មុនពេលយើងនិយាយអ្វីដែលលោកបានធ្វើ ដោយសារម៉ោងជិតប្តួនហើយ ខ្ញុំសួរសំណួរចុងក្រោយ លោកប្រធាន គឺខ្ញុំសូមបន្តថ្ងៃស្អែក។ សូមលោករៀបរាប់មកឲ្យយើងខ្ញុំស្តាប់បន្តិចថា តើបណ្ណសារជាតិហ្នឹងជាអ្វីដើម្បីធានាថា ឯកសារដែលបណ្ណសារជាតិបានទទួលមករក្សាទុក ហើយចាត់ចំណាត់ថ្នាក់វា គឺជាឯកសារដែលមានយថាភាពនោះ?

**ឆ៖** បណ្ណសារជាតិ គឺជាកន្លែងផ្ទុកឯកសាររបស់ជាតិទាំងមូល ហើយដែលមានជាអនុក្រឹត្យត្រឹមត្រូវ ជាស្ថាប័នត្រឹមត្រូវ ជាស្ថាប័នជំនាញ។ នេះគឺជាអ្វីដែលខ្ញុំអាចរៀបរាប់ជូនបាន សម្រាប់លោកមេធាវី។

**ស៖** លោកប្រធាន ខ្ញុំសូមសួរបន្តបន្តិចទៀត គឺថា ខ្ញុំមិននិយាយអំពីការ ខ្ញុំនិយាយអំពីទស្សនៈរបស់បណ្ណសារដ្ឋានជាតិ គឺប្រសិនណាជាលោកដឹង លោកឆ្លើយថា ដឹង បើមិនដឹងឆ្លើយថា មិនដឹង។ តើការខិតខំប្រឹងប្រែងអ្វីខ្លះ បើលោកមានខិតខំប្រឹងប្រែង ឬក៏ ឌី.ស៊ី.ខេម ដើម្បី-- តើលក្ខណៈវិនិច្ឆ័យអ្វីខ្លះដែលបណ្ណសារដ្ឋានជាតិបានប្រើប្រាស់ដើម្បីវិនិច្ឆ័យថា ឯកសារនៅក្នុងអំឡុងពេលនេះ ដែលខ្លួនបានរក្សាទុកនោះ គឺមានយថាភាពនោះ?

**ឆ៖** ដូចខ្ញុំបានជម្រាបពីរឿយៗមកហើយថា នៅពេលដែលយើងធ្វើការវាយតម្លៃយថាភាពនៃឯកសារនោះ គឺយើងបានសួរនាំទៅអ្នកដែលគ្រប់គ្រងឯកសារនៅបណ្ណសារនោះថា តើឯកសារនេះ

ទទួលបានមកយ៉ាងម៉េច? ហើយទុកដាក់អីយ៉ាងម៉េច ជាដើម។

**ស៖** លោក យើងនិយាយអំពីបណ្ណសារដ្ឋានជាតិ យើងមិននិយាយអំពីបុគ្គលដទៃទេ។ ដូច្នេះ សូមឆ្លើយមកសំណួរខ្ញុំ។ ខ្ញុំនិយាយអំពីបណ្ណសារដ្ឋានជាតិ ខ្ញុំមិននិយាយអំពីអ្នកណាផ្សេងទេ។ តើលោក ឬក៏ ឌី.ស៊ី.ខេម ដែលចោទសួរទៅបណ្ណសារដ្ឋានជាតិថា តើបណ្ណសារដ្ឋានជាតិប្រើលក្ខណៈវិនិច្ឆ័យអ្វីខ្លះដើម្បីកំណត់ថា ឯកសារណាមួយមានយថាភាពនោះ? សូមឆ្លើយថា ខ្ញុំមានសួរ ខ្ញុំអត់បានសួរ ឬក៏ ខ្ញុំអត់ដឹងទេ។ មានតែបីចំណុចទេ សូមឆ្លើយចំណុចណាមួយក្នុងចម្លើយទាំងបីនេះ។

**ឆ៖** ដូចខ្ញុំបានជម្រាប ឆ្លើយយ៉ាងម៉េច មុននឹងអីចឹងគឺថា ខ្ញុំបានសួរអំពីយថាភាពនៃឯកសារនេះទៅអ្នកគ្រប់គ្រងនៅបណ្ណសារជាតិ នៅពេលដែលខ្ញុំទៅប្រមូលឯកសារបណ្ណសារជាតិ។

**លោក ម៉ែខល កាណាវាស៖**

លោកប្រធាន លោក លោកស្រីចៅក្រម ខ្ញុំគិតថាអាចនឹងបន្តសួរសំណួរជាក់លាក់មួយចំនួននៅព្រឹកថ្ងៃស្អែកទៀត ប្រហែលជាលោក សូមអរគុណច្រើនដោយសារថា ម៉ោងបួនល្ងាចទៅហើយ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណមេធាវី។ អរគុណលោកសាក្សី លោក ដាវ៉ាពៅ ហើយតាមកាលវិភាគក្នុងការស្តាប់សក្ខីកម្មរបស់លោក គឺតែពីរថ្ងៃទេ ប៉ុន្តែឥឡូវនេះអង្គជំនុំជម្រះដំណើរការទៅឃើញថា យឺតពេលប្រហែលជាមួយព្រឹកទៀតទើបចប់។ ដូច្នេះអង្គជំនុំជម្រះសូមអញ្ជើញលោកមកបន្តនូវការផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះនៅទីនេះ សម្រាប់មួយព្រឹកថ្ងៃស្អែកទៀត។

ឥឡូវនេះដល់ពេលសមល្មមនឹងសម្រាកហើយ ដូច្នេះអង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ ហើយសវនាការនឹងលើកទៅបន្តធ្វើនៅថ្ងៃស្អែកចាប់ពីម៉ោងប្រាំបួនព្រឹក។ ហេតុដូច្នេះ សាធារណជន និងភាគីជ្រាប។

អនុរក្សមន្ទីរឃុំឃាំងសូមនាំជនជាប់ចោទទាំងបីរូបត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញ ហើយឲ្យនាំពួកគាត់មកកាន់បន្ទប់សវនាការនេះ នៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន។

សូមអញ្ជើញសម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:០៣ នាទី)*